ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

# របាយការណ៍លទ្ធផលនៃការអង្កេតស្តីពី ការអនុវត្តការគ្រប់គ្រងសំរាម និងសំណល់រឹង នៅរដ្ឋបាលក្រុង ស្រុក




រៀបចំដោយ៖ សម្ព័ន្ធភាពជាតិក្រុមប្រឹក្សាមូលដ្ឋាន

និពន្ធដោយ៖ លោក មិន មុនី



ឧបត្ថម្ភដោយ៖ មូលនិធិខុនរ៉ាដអាដិនណៅអ៊ែរ ប្រចាំប្រទេសកម្ពុជា

# របាយការណ៍អង្កេតស្តីពី

## ការអនុវត្តការគ្រប់គ្រងសំរាម សំណល់រឹង

## ដោយរដ្ឋបាលក្រុង ស្រុក

រៀបរៀងដោយៈ សម្ព័ន្ធភាពជាតិសមាគមក្រុមប្រឹក្សា ក្រុង ស្រុក ខណ្ឌ ឃុំ សង្កាត់

និពន្ធដោយៈ លោក មិន មុនី, ទីប្រឹក្សាឯករាជ្យ

ឧបត្ថម្ភដោយៈ មូលនិធិខុនរ៉ាដអាដិនណៅអ៊ែរ ប្រចាំប្រទេសកម្ពុជា

# មាតិការឿង


**បញ្ជីពាក្យកាត់**

**សេចក្តីសង្ខេប ........ 1**

**ជំពូក ១ ប្រវត្តិដើម ........ 5**

១.១. ព័ត៌មានទូទៅ ........ 5

១.២. ព័ត៌មានទូទៅអំពីការគ្រប់គ្រងសំរាម សំណល់រឹង ក្នុងព្រះរាជាណាចក្រកម្ពុជា ........ 5

១.៣. វិធីសាស្ត្រនៃការសិក្សាស្រាវជ្រាវ/អង្កេត ........ 6

១.៤. ចំណុចខ្វះខាតនៃការអង្កេត ........ 7

**ជំពូក ២ លទ្ធផលនៃការអង្កេត ........ 8**

២.១. ក្របខ័ណ្ឌលិខិតបទដ្ឋានគតិយុត្ត (ការស្រាវជ្រាវលើលិខិតបទដ្ឋានគតិយុត្តកន្លងមក) ........ 8

២.១.១. លិខិតបទដ្ឋានគតិយុត្តថ្នាក់ជាតិ ........ 8

២.១.២. លិខិតបទដ្ឋានគតិយុត្តថ្នាក់ក្រុង ស្រុក ........ 10

២.២. ការអនុវត្តជាក់ស្តែង ........ 10

២.២.១. ស្ថានភាពទូទៅនៃការគ្រប់គ្រងសំរាម សំណល់រឹងនៅថ្នាក់ក្រុង ស្រុក ........ 10

២.២.២. តួនាទី និងការទទួលខុសត្រូវរបស់រដ្ឋបាលក្រុង ស្រុក ........ 12

២.២.៣. តួនាទី និងការទទួលខុសត្រូវរបស់ក្រុមហ៊ុនឯកជន ........ 14

២.២.៤. សង្ខេបអំពីតួនាទី និងការទទួលខុសត្រូវរបស់តួអង្គសំខាន់ៗមួយចំនួន ........ 15

២.៣. បែបបទនៃកិច្ចសហការ ........ 16

២.៣.១. ប្រភេទកិច្ចសន្យា ........ 16

២.៣.២. កិច្ចសហការជាមួយរដ្ឋបាលខេត្ត ........ 16

២.៣.៣. កិច្ចសហការជាមួយរដ្ឋបាលថ្នាក់ក្រោមជាតិផ្សេងទៀត ........ 17

២.៣.៤. កិច្ចសហការជាមួយក្រុមប្រឹក្សាឃុំ សង្កាត់នៅក្នុងដែនសមត្ថកិច្ចរបស់ខ្លួន ........ 17

២.៣.៥. កិច្ចសហការជាមួយក្រុមហ៊ុនឯកជនប្រមូលសំរាម សំណល់រឹង ........ 17

២.៣.៦. ជំនួយបច្ចេកទេស និងហិរញ្ញវត្ថុដែលក្រុង/ស្រុកទទួលបាន ........ 18

២.៤. ថវិកា និងការគណនាតម្លៃភាស៊ី ក្នុងការគ្រប់គ្រងសំរាម-សំណល់រឹង ........ 18

២.៤.១. ថវិកា និងប្រភពថវិកាក្នុងការគ្រប់គ្រងសំរាម-សំណល់រឹង ........ 18

២.៤.២. ការគណនាតារាងតម្លៃសម្រាប់ការគ្រប់គ្រងសំរាម សំណល់រឹង ........ 19

២.៤.៣. ការប្រមូលកម្រៃពីសេវាសំរាម សំណល់រឹង ........ 20

២.៤.៤. ផែនការពង្រីកសេវាគ្រប់គ្រងសំរាម សំណល់រឹង ........ 20

២.៥. ករណីសិក្សា ........ 21

២.៥.១. ករណីសិក្សា ១៖ ការគ្រប់គ្រងសំរាម សំណល់រឹង នៅក្រុងព្រះសីហនុ ........ 21

២.៥.២. ករណីសិក្សា ២៖ ការគ្រប់គ្រងសំរាមក្នុងក្រុងស្ទឹងត្រែង ........ 24

**ជំពូក៣ បញ្ហាប្រឈម ..... 27**

៣.១. ការគ្រប់គ្រងសំរាម សំណល់រឹងតាមបែបមជ្ឈការ..... 27

៣.២. លិខិតបទដ្ឋានគតិយុត្តមិនគ្រប់គ្រាន់ ឬមិនទាន់សមស្រប..... 28

៣.៣. យន្តការពង្រឹងការអនុវត្តលិខិតបទដ្ឋាននៅពុំទាន់មានប្រសិទ្ធិភាព ..... 29

៣.៤. កង្វះធនធានមនុស្ស និងហិរញ្ញវត្ថុ ..... 29

**ជំពូក៤ សេចក្ដីសន្និដ្ឋាន និងអនុសាសន៍..... 31**

៤.១. សេចក្ដីសន្និដ្ឋាន..... 31

៤.២. អនុសាសន៍ ..... 32

# បញ្ជីពាក្យកាត់

| | | |
|---|---|---|
| BoG | : | គណៈអភិបាលខេត្ត ( Board of Governors ) |
| C/S | : | ឃុំ/សង្កាត់ ( Commune/Sangkat ) |
| CINTRI | : | ក្រុមហ៊ុន ស៊ីនទ្រី ( ខាមបូឌា ) "CINTRI ( Cambodia ) Ltd" |
| CoM | : | ទីស្តីការគណៈរដ្ឋមន្ត្រី ( Council of Ministers ) |
| DoEF | : | មន្ទីរសេដ្ឋកិច្ច និងហិរញ្ញវត្ថុខេត្ត ( Department of Economy and Finance ) |
| GAEA | : | ក្រុមហ៊ុនហ្គាអៀ ( Global Action for Environmental Awareness ) |
| IPADE | : | Instituto de Promoción y Apoyo al Desarrollo |
| KAS | : | មូលនិធិខុនរ៉ាដ អាដិនណៅអ៊ែរ ( Konrad-Adenauer-Stiftung ) |
| M/D | : | ក្រុង/ស្រុក ( Municipality/District ) |
| MA | : | រដ្ឋបាលក្រុង ( Municipality Administration ) |
| MEF | : | ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ( Ministry of Economy and Finance ) |
| MoEnv | : | ក្រសួងបរិស្ថាន ( Ministry of Environment ) |
| MoI | : | ក្រសួងមហាផ្ទៃ ( Ministry of Interior ) |
| MRD | : | ក្រសួងអភិវឌ្ឍន៍ជនបទ ( Ministry of Rural Development ) |
| NCDD | : | គណៈកម្មាធិការជាតិសម្រាប់ការអភិវឌ្ឍតាមបែបប្រជាធិបតេយ្យនៅថ្នាក់ក្រោមជាតិ ( គជអប ) |
| NGO | : | អង្គការក្រៅរដ្ឋាភិបាល ( Non-Government Organization ) |
| NLC/S | : | សម្ព័ន្ធភាពជាតិសមាគមក្រុមប្រឹក្សា ក្រុង ស្រុក ខ័ណ្ឌ ឃុំ សង្កាត់<br>National League of Municipality Districts/Khans, Communes/Sangkats Councils |
| PA | : | រដ្ឋបាលខេត្ត ( Provincial Administration ) |
| PET | : | Polyethylene Terephthalate |
| RGC | : | រាជរដ្ឋាភិបាលកម្ពុជា ( Royal Government of Cambodia ) |
| SCARO | : | អង្គការស្ការ៉ូ ( Community Sanitation and Recycling Organization ) |
| SHV | : | ក្រុងព្រះសីហនុ ( Sihanoukville ) |
| SNA | : | រដ្ឋបាលថ្នាក់ក្រោមជាតិ ( Sub-National Administrator ) |
| WMU | : | ការិយាល័យគ្រប់គ្រងសំរាម-សំណល់រឹង ( Waste Management Unit ) |

# សេចក្តីសង្ខេប

ការតាំងចិត្តរបស់រាជរដ្ឋាភិបាលកម្ពុជា ក្នុងការផ្ទេរមុខងារគ្រប់គ្រងសំរាម និងសំណល់រឹងទៅឱ្យរដ្ឋបាលក្រុង ស្រុក លេខាធិការដ្ឋានគណៈកម្មាធិការជាតិសម្រាប់ការអភិវឌ្ឍតាមបែបប្រជាធិបតេយ្យនៅថ្នាក់ក្រោមជាតិ(**គ.ជ.អ.ប**)ដោយសហការជាមួយ**ក្រសួងបរិស្ថាន** បានពិនិត្យមើលឡើងវិញជាបន្តបន្ទាប់នូវលិខិតបទដ្ឋានគតិយុត្តទាំងឡាយ ទាក់ទងនឹងការគ្រប់គ្រងសំរាម និងសំណល់រឹង ព្រមទាំងបានស្នើទៅរាជរដ្ឋាភិបាលកម្ពុជាដាក់ចេញនូវអនុក្រឹត្យលេខ**១១៣អ.ន.ក្រ** ស្តីពី"ការគ្រប់គ្រងសំរាម និងសំណល់រឹងតាមទីប្រជុំជន"ក្នុងខែសីហា ឆ្នាំ២០១៥ កន្លងទៅនេះ។ ដើម្បីសិក្សា និងស្វែងយល់បន្ថែមអំពីលទ្ធភាពជាក់ស្តែងនៃអនុក្រឹត្យខាងលើនេះ នៅថ្នាក់ក្រោមជាតិ លេខាធិការដ្ឋាន**គ.ជ.អ.ប** និងសម្ព័ន្ធភាពជាតិសមាគមក្រុមប្រឹក្សា ក្រុង ស្រុក ខ័ណ្ឌ ឃុំ សង្កាត់ (NLC/S) ក្រោមជំនួយបច្ចេកទេសពី**មូលនិធិខុនរ៉ាដអាដិនណៅអ៊ែ (KAS)**ប្រចាំប្រទេសកម្ពុជា បានប្រមូលចងក្រងជាឯកសារនូវបទពិសោធន៍ និងមេរៀនសំខាន់ៗ អំពីការអនុវត្តជាក់ស្តែង និងបញ្ហាប្រឈមនានាក្នុងការគ្រប់គ្រងសំរាម និងសំណល់រឹង នៅតាមរដ្ឋបាលក្រុង ស្រុក នៃព្រះរាជាណាចក្រកម្ពុជា និងតាមបណ្តាប្រទេសមួយចំនួនក្នុងតំបន់ ដូចជាប្រទេសហ្វីលីពីន ឥណ្ឌូនេស៊ី ថៃ និងប្រទេសអាល្លឺម៉ង់ផងដែរ។

នៅកម្ពុជា នៅក្នុងអំឡុងខែកញ្ញា ឆ្នាំ២០១៥ NLC/S បានអង្កេតនៅតាមរដ្ឋបាលក្រុង ស្រុកចំនួន៣៦ ក្នុងចំណោមក្រុង ស្រុកសរុប១៨៥ទូទាំងប្រទេស លើការការគ្រប់គ្រងសំរាម និងសំណល់រឹងតាមទីប្រជុំជន។ រដ្ឋបាលក្រុង ស្រុក ដែលត្រូវបានជ្រើសរើសមកសិក្សាស្រាវជ្រាវនេះ ត្រូវបានបែងចែកជា៤តំបន់សំខាន់ៗ៖ តំបន់ឧស្សាហ៍កម្ម តំបន់ទេសចរណ៍ តំបន់ទីប្រជុំជន និងតំបន់ជនបទ។ មុននឹងបំពេញបញ្ជីសំណួរ ដែលនឹងត្រូវធ្វើជាក្រុម រវាងគណៈអភិបាល និងក្រុមប្រឹក្សារដ្ឋបាលក្រុង ស្រុកនោះ NLC/Sបានរៀបចំសិក្ខាសាលាពិគ្រោះយោបល់មួយដែលមានរយៈពេល១ថ្ងៃនៅរាជធានីភ្នំពេញ ដោយមានការចូលរួមពីមន្ត្រីជំនាញនៃរដ្ឋបាលក្រុង ស្រុកទាំង៣៦ខាងលើ។ ការរៀបចំសិក្ខាសាលាពិគ្រោះយោបល់នេះ គឺដើម្បីធានាថាមន្ត្រីជំនាញទាំងនោះបានយល់ដឹងច្បាស់លាស់អំពីបញ្ជីសំណួរ និងមានឱកាសពិភាក្សារាល់បញ្ហាផ្សេងៗដែលមាននៅក្នុងបញ្ជីសំណួរដែលពួកគាត់នឹងត្រូវយកទៅបំពេញជាមួយនឹងគណៈអភិបាល និងក្រុមប្រឹក្សាក្រុង ស្រុកនោះ។ រដ្ឋបាលក្រុង ស្រុកមានរយៈពេល១ខែ សម្រាប់ការបំពេញបញ្ជីសំណួរនេះ។ លទ្ធផលនៃការអង្កេតមានដូចខាងក្រោម៖

ប្រធានបទអំពីសំរាម និងបរិស្ថានក្នុងក្រុង ទីប្រជុំជន បានក្លាយជាបញ្ហាមួយក្នុងចំណោមបញ្ហាជាច្រើនកំពុងចោទឡើងគួរឱ្យកត់សម្គាល់ជារៀងរាល់នៅក្នុងព្រះរាជាណាចក្រកម្ពុជា ដែលជាទូទៅ ត្រូវបានគេលើកយកមកជជែកពិភាក្សាជាសាធារណៈទាំងនៅលើទំព័រសារព័ត៌មាន តាមប្រព័ន្ធផ្សព្វផ្សាយសង្គម និងក្នុងកិច្ចពិភាក្សាគោលនយោបាយ។ ដោយបានភ្ជាប់បញ្ហាសំរាមទៅនឹងការអភិវឌ្ឍផ្នែកនគរូបនីយកម្មដ៏គំហុក (ការអភិវឌ្ឍតាមទីប្រជុំជន) ការបន្ថយល្បឿនរីកចំរើនលើវិស័យនគរូបនីយកម្មនេះ ពុំមែនជាដំណោះស្រាយក្នុងការគ្រប់គ្រងសំរាម និងសំណល់រឹងនោះឡើយ។ តាមរយៈការអង្កេតនេះ គេបានរកឃើញបញ្ហាប្រឈមចម្បងៗជាច្រើន ដែលចាំបាច់ត្រូវយកមកពិចារណា ក្នុងការអនុវត្តមុខងារគ្រប់គ្រងសំរាម។ បញ្ហាប្រឈមធំៗទាំងនោះរួមមាន យន្តការគ្រប់គ្រងការងារបែបមជ្ឈការ លិខិតបទដ្ឋានគតិយុត្តមិនទាន់គ្រប់គ្រាន់ និងមិនទាន់សមស្រប ការពង្រឹងយន្តការច្បាប់ពុំទាន់មានប្រសិទ្ធភាព ព្រមទាំងបញ្ហាគ្រប់គ្រងធនធានមនុស្ស និងហិរញ្ញវត្ថុពុំមានភាពស័ក្តសិទ្ធនៅឡើយ។

មានលិខិតបទដ្ឋានគតិយុត្តមួយចំនួនពាក់ព័ន្ធនឹងការគ្រប់គ្រងសំរាម សំណល់រឹងទីប្រជុំជន ដែលយើងបានយកមកពិភាក្សាក្នុងការអង្កេតនេះ។ លិខិតបទដ្ឋានគតិយុត្តទាំងនោះមានដូចជា ប្រកាសអន្តរក្រសួងលេខ៨០រវាងក្រសួងមហាផ្ទៃ និងក្រសួងបរិស្ថានដែលកំពុងមានសុពលភាព ខណៈដែលការអនុវត្តអនុក្រឹត្យថ្មីលេខ១១៣ហាក់ដូចជានៅទ្រឹងនៅឡើយ។ មានរដ្ឋបាលក្រុង ស្រុកមួយចំនួនតូច បានប្រឹងប្រែងសាកល្បងអនុវត្តតាមខ្លឹមសារនៃអនុក្រឹត្យនេះ ប៉ុន្តែរដ្ឋបាលក្រុង ស្រុកទាំងនោះ បានជួបប្រទះនឹងបញ្ហានានាជាច្រើន ក្នុងការបកស្រាយខ្លឹមសារអនុក្រឹត្យ និងការកៀរគរការគាំទ្រនានា ពិសេសការគាំទ្រពីរដ្ឋបាលខេត្ត និងមន្ទីរសេដ្ឋកិច្ចនិងហិរញ្ញវត្ថុខេត្ត ដែលពីមុនអង្គភាពទាំងនេះធ្លាប់ជាអ្នកអនុវត្តកិច្ចការគ្រប់គ្រងសំរាមនេះ។ ក្នុងការចៀសវាងពីកំហុសឆ្គងផ្សេងៗក្នុងការអនុវត្តការងារគ្រប់គ្រងសំរាម និងសំណល់រឹងនេះ រដ្ឋបាលក្រុង ស្រុកភាគច្រើនសម្រេចរង់ចាំសេចក្តីណែនាំ និងបទបញ្ញានានា មុននឹងផ្តើមអនុវត្តការងារគ្រប់គ្រងសំរាមក្នុងមូលដ្ឋានរបស់ខ្លួន។ រាល់ចេតនាទាំងឡាយ សំដៅត្រៀមខ្លួនដោះស្រាយបញ្ហានានាពាក់ព័ន្ធការងារនេះ តែងជួបប្រទះភាពស្មុគស្មាញផ្សេងៗ។

ទោះបីយ៉ាងណាក៏ដោយ ការបង្កើតគោលនយោបាយ និងលិខិតបទដ្ឋានគតិយុត្តប្រកបដោយលក្ខណៈទូលំទូលាយ ក៏ជាកត្តាល្អមួយ ក្នុងការជំរុញឱ្យមានការបំផុសគំនិតផ្តួចផ្តើមនានាផងដែរ។ គោលនយោបាយ និងលិខិតបទដ្ឋានគតិយុត្តដែលមានលក្ខណៈទូលំទូលាយទាំងនេះ ពិតជាបានជំរុញបន្ថែមទៀតដល់រដ្ឋបាលក្រុង ស្រុក ឬរដ្ឋបាលថ្នាក់ក្រោមជាតិផ្សេងៗទៀត ដែលមានភាពសកម្ម ឱ្យកាន់តែប្រឹងប្រែងព្យាយាមសិក្សាស្វែងយល់នូវរាល់គោលនយោបាយ និងលិខិតបទដ្ឋានទាំងឡាយដែលមានស្រាប់។ មានន័យថា តាមរយៈការប្រឹក្សាយោបល់ល្អៗពាក់ព័ន្ធនឹងលិខិតបទដ្ឋាននានា រដ្ឋបាលក្រុង ស្រុកជាទូទៅ អាចនឹងមានឱកាស និងលទ្ធភាពបត់បែនខ្ពស់ក្នុងការអនុវត្តការងាររបស់ខ្លួនបាន។

មានការចុះកិច្ចសន្យាជាច្រើនសណ្ឋាន ជាមួយក្រុមហ៊ុនផ្តល់សេវាប្រមូលសំរាម ពិសេសរយៈពេលនៃកិច្ចសន្យាទាំងនោះ។ រដ្ឋបាលក្រុង ស្រុកជាច្រើន ដែលបានចូលរួមក្នុងការអង្កេតនេះ បាននិងកំពុងតែស្វះស្វែងរកដំណោះស្រាយ ចំពោះកិច្ចសន្យាជាមួយក្រុមហ៊ុនឯកជន តាមរយៈការបញ្ឈប់កិច្ចសន្យា ឬត្រូវប្តូរដែនសមត្ថកិច្ចគ្រប់គ្រងសំរាម (ពីរដ្ឋបាលខេត្ត មករដ្ឋបាលក្រុង ស្រុកវិញ)។ ចំពោះកិច្ចសន្យាដែលមានរយៈពេល១ឆ្នាំ និងឬ កិច្ចសន្យាដែលជិតអស់សុពលភាព ជម្រើសក្នុងការដោះស្រាយមានភាពទូលំទូលាយជាងកិច្ចសន្យារយៈពេលវែង ដែលផ្តល់លទ្ធភាពច្រើនដល់រដ្ឋបាលក្រុង ស្រុកច្រ ក្នុងការគ្រប់គ្រងសំរាម និងសំណល់រឹង។

របៀបនៃការអនុវត្តផ្សេងៗគ្នា បាននាំឱ្យរដ្ឋបាលក្រុង ស្រុកទាំងឡាយ ទទួលបានសមត្ថភាពយល់ដឹងផ្សេងៗផងដែរ(ដូចជាការសមត្ថភាពយល់ដឹងពីការរៀបចំដីកា ឬលិខិតបទដ្ឋាននៅមូលដ្ឋាននានា) ហើយភាពផ្សេងៗគ្នាទាំងនេះ ក៏បានផ្តល់លទ្ធផលខុសៗគ្នាផងដែរ (ជាក់ស្តែងដូចជា*ការធ្វើចំណាត់ថ្នាក់ទីក្រុងស្អាត* ការកៀរគរថវិកាបន្ថែមតាមរយៈការផលិតជីកំប៉ុស្តជាដើម)។ ទោះបីយ៉ាងណាក៏ដោយ កិច្ចខិតខំប្រឹងប្រែងក្នុងការរកដំណោះស្រាយផ្សេងៗ ព្រមគ្នានឹងឆន្ទះរបស់ប្រជាពលរដ្ឋក្នុងការបង់ប្រាក់កម្រៃសេវាសំរាម គឺជាឱកាសដ៏វិសេសវិសាល ដើម្បីពង្រឹងគុណភាព និងនិរន្តរភាពហិរញ្ញវត្ថុក្នុងការគ្រប់គ្រងសំរាម នាពេលខាងមុខ។ ដោយទទួលបានបទពិសោធន៍ ចំណេះដឹង និងធាតុចូលនានា ពីបណ្តាប្រទេសផ្សេងៗ រដ្ឋបាលក្រុង ស្រុក អាចនឹងកសាងសមត្ថភាពរបស់ខ្លួនបានយ៉ាងលឿន លើការអនុវត្តមុខងារគ្រប់គ្រងសំរាម សំណល់រឹង ប្រកបដោយ

ប្រសិទ្ធិភាព និងភាពស័ក្តសិទ្ធ។ ផ្អែកលើលទ្ធផលនៃការស្រាវជ្រាវ និងបញ្ហាប្រឈមមួយចំនួន ដែលបានរកឃើញ សម្ព័ន្ធភាពជាតិNLC/S សូមផ្តល់ជាអនុសាសន៍មួយចំនួនដូចខាងក្រោម៖

ការចងក្រងជាឯកសារអំពី "ការអនុវត្តល្អ" និងការប្រើប្រាស់នូវធនធានហិរញ្ញវត្ថុដែលផ្តល់ដោយរដ្ឋាភិបាលកម្ពុជានៅឆ្នាំ២០១៥ ក្រុមការងារអន្តរក្រសួង (រួមមានលេខាធិការដ្ឋាន គ.ជ.អ.ប ក្រសួងមហាផ្ទៃ ក្រសួងបរិស្ថាន និងក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ) គួរតែអនុវត្តចំណុចមួយចំនួនដូចខាងក្រោម៖

- សិក្សាឱ្យបានស៊ីជម្រៅអំពី "ការអនុវត្តល្អ" និងបញ្ហាប្រឈមនានាដែលមានកន្លងមក។ តាមរយៈការសិក្សាស្រាវជ្រាវនេះ គេគួរតែធ្វើការសិក្សាបន្ថែមអំពីការងារគ្រប់គ្រងសំរាមរបស់រដ្ឋបាលក្រុងស្ទឹងត្រែង ពោលគឺជាការរៀបចំការងារគ្រប់គ្រងសំរាមដោយការិយាល័យគ្រប់គ្រងសំរាម របៀបកំណត់ថ្លៃសេវាសំរាម ការកំណត់ដំណើរការ និងប្រសិទ្ធិភាពគ្រប់គ្រងសំរាមជាដើម។ ក្រៅពីនេះ នៅរដ្ឋបាលក្រុងស្ទឹងសែន និងក្រុងក្រចេះ ក៏សុទ្ធតែជាក្រុងដែលយើងគួរធ្វើការពិភាក្សាអំពីនីតិវិធីក្នុងការកំណត់និងការប្រមូលកម្រៃសេវាសំរាមផងដែរ។
- ការសិក្សាស្រាវជ្រាវបន្ថែមផ្សេងទៀតអំពីការអនុវត្តល្អក្នុងការគ្រប់គ្រងសំរាម ពីបណ្តារដ្ឋបាលថ្នាក់ក្រោមជាតិផ្សេងៗទៀត ក៏ជាឯកសារបន្ថែមទៀតសម្រាប់ពង្រឹងប្រសិទ្ធភាពនៃគ្រប់គ្រងសំរាមសំណល់រឹងនេះ។
- ប្រមូលផ្តុំនូវក្រុមការងារអន្តរក្រសួង ដែលមានមន្ត្រីជំនាញ មកពីលេខាធិការដ្ឋានគ.ជ.អ.ប ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ រតនាគាជាតិ ក្រសួងបរិស្ថាន និងក្រសួងមហាផ្ទៃ ដើម្បីផ្តល់ការគាំទ្រ និងសម្របសម្រួលដោះស្រាយឧបសគ្គនានា ដែលរដ្ឋបាលក្រុង ស្រុកកំពុងជួបប្រទះ ក្នុងការទូទាត់ចំណាយថវិកាឆ្នាំ២០១៥កន្លងមក។
- ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ និងក្រសួងបរិស្ថាន គួរផ្តល់ការណែនាំបន្ថែមដល់មន្ទីរជំនាញរបស់ខ្លួននៅតាមរាជធានី ខេត្ត ក្នុងការរៀបចំ និងការអនុវត្តផែនការសកម្មភាព និងថវិកា។

ក្នុងការលើកកម្ពស់ការងារគ្រប់គ្រងសំរាម សំណល់រឹងតាមបែបវិមជ្ឈការ សម្ព័ន្ធភាពជាតិNLC/S នឹងធ្វើការយ៉ាងជិតស្និទ្ធជាមួយក្រុមការងារអន្តរក្រសួង មកពីលេខាធិការដ្ឋានគ.ជ.អ.ប ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ រតនាគាជាតិ ក្រសួងបរិស្ថាន និងក្រសួងមហាផ្ទៃ ព្រមទាំងខិតខំប្រឹងប្រែងបញ្ចុះបញ្ចូលឱ្យមានការធ្វើវិមជ្ឈការដ៏ពិតប្រាកដមួយ ដោយផ្តល់សិទ្ធិសម្រេចនានាទៅឱ្យរដ្ឋបាលក្រុង ស្រុក ក្នុងការគ្រប់គ្រងកិច្ចការងារទាំងឡាយក្នុងមូលដ្ឋានរបស់ខ្លួន ដូចជាការគ្រប់គ្រងសំរាម និងបរិស្ថានក្រុងជាដើម។ ការខិតខំប្រឹងប្រែងបញ្ចុះបញ្ចូលនេះនឹងត្រូវផ្តោតទៅលើ៖

- ការលើកកម្ពស់ និងជំរុញយន្តការវិមជ្ឈការ (ទាំងការរៀបចំក្របខ័ណ្ឌគតិយុត្ត និងការអនុវត្ត)

សេចក្តីណែនាំនានាពាក់ព័ន្ធនឹងការអនុវត្តមុខងារគ្រប់គ្រងសំរាម ដែលបានផ្ទេរទៅឱ្យរដ្ឋបាលក្រុង ស្រុក មានសារសំខាន់ណាស់ ប៉ុន្តែត្រូវពិចារណាក្នុងការផ្តល់សិទ្ធិ និងលទ្ធភាពដែលអាចបត់បែនបាន ក្នុងការអនុវត្តកិច្ចការគ្រប់គ្រងសំរាម និងសំណល់រឹង ដោយរដ្ឋបាលក្រុង ស្រុក។ ភាពអាចបត់បែនបានទាំងនោះ រួម

មានការកំណត់ពីរបៀបក្នុងការប្រមូលសំរាម សំណល់រឹង ព្រមវិធីសាស្ត្រ និងរូបមន្តក្នុងការកំណត់កម្រៃសេវាប្រមូលសំរាមជាដើម ដែលជាយន្តការសមស្រប ដើម្បីពង្រឹងគណនេយ្យភាពរវាងអ្នកប្រើប្រាស់ និងអ្នកផ្តល់សេវាប្រមូលសំរាម។

ការអនុវត្តការធ្វើអធិការកិច្ច និងការធ្វើនីត្យានុកូលភាពរបស់ក្រុមការងារអន្តរក្រសួង តម្រូវឱ្យមានការពង្រឹងសមត្ថភាពឱ្យបានសមស្របសម្រាប់រដ្ឋបាលថ្នាក់ក្រោមជាតិ។ ក្នុងការគ្រប់គ្រងសំរាម សំណល់រឹង រដ្ឋបាលក្រុង ស្រុក ចាំបាច់ត្រូវមានការយល់ដឹងឱ្យបានពេញលេញអំពីខ្លឹមសារអនុក្រឹត្យលេខ១១៣ ប្រកាសអន្តរក្រសួងលេខ០៧៣ សារាចរណ៍លេខ៨០០ និងរាល់លិខិតបទដ្ឋានពាក់ពន្ធ័ផ្សេងៗទៀត សម្រាប់អនុវត្តមុខងារដែលបានផ្ទេរនាពេលថ្មីៗនេះ។ ក្នុងន័យនេះ ក្រសួង ស្ថាប័នថ្នាក់ជាតិ គួរផ្តល់ភាពងាយស្រួលដល់រដ្ឋបាលក្រុង ស្រុក ជួល និងប្រើប្រាស់អ្នកជំនាញពាក់ព័ន្ធ និង/ឬទទួលបានសេវាប្រឹក្សាយោបល់ក្នុងការអនុវត្តការងាររបស់ខ្លួន។

- **ធនធានមនុស្ស និងធនធានហិរញ្ញវត្ថុ**

សមត្ថភាពអនុវត្តការងាររបស់រដ្ឋបាលក្រុង ស្រុក ក៏មានសារសំខាន់ចាំបាច់ផងដែរ ដោយសារការប្រគល់មុខងារគ្រប់គ្រងសំរាម សំណល់រឹងទៅឱ្យរដ្ឋបាលក្រុង ស្រុក ត្រូវការជាចាំបាច់នូវការអភិវឌ្ឍធនធានមនុស្សតាមរដ្ឋបាលក្រុង ស្រុកនីមួយៗ។ ក្រសួង ស្ថាប័នថ្នាក់ជាតិ គួរអនុញ្ញាតិ្តឱ្យរដ្ឋបាលក្រុង ស្រុក បង្កើតអង្គភាពទទួលបន្ទុក និងអាចជ្រើសរើសអ្នកជំនាញនៅតាមមូលដ្ឋានរបស់ខ្លួន។ ចំពោះរដ្ឋបាលក្រុង ស្រុកណាដែលធ្វើការជាមួយក្រុមហ៊ុនឯកជន ក្នុងការប្រមូលសំរាម សំណល់រឹង រដ្ឋបាលក្រុង ស្រុកនោះ ចាំបាច់ត្រូវពង្រឹងតួនាទី ភារកិច្ចក្នុងការត្រួតពិនិត្យ តាមដាន និងវាយតម្លៃរបស់ខ្លួនឱ្យបានប្រសើរសំដៅពង្រឹងសមត្ថភាពមន្ត្រីជំនាញ ដែលត្រូវធ្វើការជាមួយក្រុមហ៊ុនឯនទាំងនោះ។ ការពង្រឹងសមត្ថភាពនេះទៀតសោត អាចធ្វើដោយមានការជ្រោមជ្រែងពី*សម្ព័ន្ធភាពជាតិ* NCL/S តាមរយៈការរៀបចំដាទស្សនៈកិច្ចសិក្សាទាំងនៅក្នុងប្រទេសទាំងបណ្តាប្រទេសនានាក្នុងតំបន់ដើម្បីស្វែងយល់បន្ថែមអំពីការអនុវត្តការគ្រប់គ្រងសំរាម-សំណល់រឹងនេះ។ អ្វីដែលគួរធ្វើបន្ទាប់នោះ គឺរដ្ឋបាលក្រុង ស្រុក ត្រូវមានធនធានហិរញ្ញវត្ថុរបស់ខ្លួន។ ខណៈដែលការងារគ្រប់គ្រងសំរាម សំណល់រឹង អាចផ្តល់ជាប្រភពប្រាក់ចំណូលផ្ទាល់សម្រាប់ក្រុង ស្រុក (ចំណូលបានតាមរយៈប្រាក់កម្រៃប្រមូលសំរាម ប្រាក់ពិន័យ ការកែច្នៃ និងប្រភពផ្សេងទៀត ជាដើម)នាពេលអនាគត ការគាំទ្រធនធានហិរញ្ញវត្ថុប្រចាំឆ្នាំពីរាជរដ្ឋាបាល នៅតែជារឿងចាំបាច់ដែលរាជរដ្ឋាភិបាលត្រូវយកចិត្តទុកដាក់។ ទំហំនៃការផ្ទេរថវិកាអន្តររដ្ឋបាល ចាំបាច់ត្រូវតែបែងចែកឱ្យមានសមាមាត្រស្មើគ្នា ផ្អែកលើរូបមន្តប្រកបដោយសមធម៌សម្រាប់ក្រុង ស្រុកដែលមានប្រភពចំណូលផ្ទាល់មានតិចតួច ដើម្បីធ្វើជាមូលដ្ឋានសម្រាប់បង្កើនទំហំថវិកាទទួលបានពីការផ្ទេរ។

**រាល់ខ្លឹមសារទាំងឡាយ ដែលមានក្នុងរបាយការណ៍នេះ គឺឆ្លុះបញ្ចាំងអំពីស្ថានភាពជាក់ស្តែង ទាំងក្នុងគ្រាធ្វើការអង្កេត នាខែកញ្ញា ឆ្នាំ ២០១៥ និងក្នុងពេលបញ្ចប់ការសរសេរ នៅចុងឆ្នាំ ២០១៥**

រាជធានីភ្នំពេញ, ខែឧសភា ឆ្នាំ ២០១៦

# ជំពូក ១ ប្រវត្តិដើម

## ១.១. ព័ត៌មានទូទៅ

ការខិតខំប្រឹងប្រែងដើម្បីលើកកម្ពស់ការផ្ទេរមុខងារទៅឱ្យរដ្ឋបាលក្រោមជាតិ លេខាធិការដ្ឋានគ.ជ.អ.ប សហការជាមួយក្រសួងបរិស្ថាន បាននិងកំពុងពិនិត្យមើលឡើងវិញ ទៅលើក្របខណ្ឌលិខិតបទដ្ឋានគតិយុត្ត នានាពាក់ព័ន្ធនឹងការគ្រប់គ្រងសំរាម សំណល់រឹង។ ជាលទ្ធផល រាជរដ្ឋាភិបាលកម្ពុជាបានអនុម័តអនុក្រឹត្យ លេខ១១៣ ស្តីពីការគ្រប់គ្រងសំរាម-សំណល់រឹងតាមទីប្រជុំជន កាលពីខែសីហា ឆ្នាំ២០១៥។ អនុក្រឹត្យនេះ មានគោលបំណងផ្ទេរមុខងារគ្រប់គ្រងសំរាម សំណល់រឹង ដែលក្រោមស្ថិតនៅក្រោមការគ្រប់គ្រងរបស់ក្រសួង បរិស្ថាន និងក្រោមការសម្របសម្រួលរបស់រដ្ឋបាលរាជធានី ខេត្ត ទៅឱ្យរដ្ឋបាលក្រុងស្រុកវិញ។

ដើម្បីស្វែងយល់ឱ្យកាន់តែច្បាស់អំពីស្ថានភាពជាក់ស្តែង របស់ភ្នាក់ងារអនុវត្តនៅថ្នាក់ក្រោមជាតិ លេខាធិការដ្ឋានគ.ជ.អ.ប សហការជាមួយនឹងNLC/S និងមូលនិធិKAS ប្រចាំប្រទេសកម្ពុជា បាននិងកំពុងតែ ធ្វើការប្រមូល និងចងក្រងបទពិសោធន៍ និងមេរៀនទាំងឡាយពាក់ព័ន្ធនឹងស្ថានភាពជាក់ស្តែង និងបញ្ហា ប្រឈមក្នុងការអនុវត្តការគ្រប់គ្រងសំរាម-សំណល់រឹង ដោយរដ្ឋបាលក្រុង ស្រុកក្នុងព្រះរាជាណាចក្រកម្ពុជា ព្រមទាំងពីបណ្តាប្រទេសមួយចំនួនទៀតដូចជាប្រទេសហ្វីលីពីន ថៃ វៀតណាម និងប្រទេសអាល្លឺម៉ង់ផងដែរ។

សម្រាប់ករណីប្រទេសកម្ពុជា គេបានរៀបចំបង្កើតជាបញ្ជីសំណួរសម្រាប់អង្កេតស្តីពីការអនុវត្តការ គ្រប់គ្រងសំរាម សំណល់រឹងដោយរដ្ឋបាលក្រុង ស្រុក។ លទ្ធផលនៃការអង្កេត រួមជាមួយនឹងបទពិសោធន៍ល្អៗ ដែលទទួលបានពីបណ្តាប្រទេសនានា នឹងមានសារប្រយោជន៍យ៉ាងសំខាន់ ដល់មន្ត្រីរៀបចំគោលនយោបាយ ទាំងនៅថ្នាក់ជាតិ ទាំងថ្នាក់ក្រោមជាតិ ក្នុងការរៀបចំនិងតាក់តែងគោលនយោបាយ លិខិតបទដ្ឋានផ្សេងៗពាក់ ព័ន្ធនឹងការគ្រប់គ្រងសំរាម សំណល់រឹង ឱ្យបានកាន់តែសមស្រប ពិសេសលិខិតបទដ្ឋានគតិយុត្ត និងគោល ការណ៍ណែនាំបច្ចេកទេសនានា សម្រាប់អនុវត្តអនុក្រឹត្យលេខ១១៣នេះ ដែលទើបដាក់ចេញថ្មីៗនេះ។

## ១.២. ព័ត៌មានទូទៅអំពីការគ្រប់គ្រងសំរាម សំណល់រឹង ក្នុងព្រះរាជាណាចក្រកម្ពុជា

ក្នុងពេលដែលវិស័យសេដ្ឋកិច្ច និងទេសចរណ៍មានការរីកចម្រើនយ៉ាងគំហុក ការគ្រប់គ្រងសំរាម សំណល់រឹង គឺជាបញ្ហាប្រឈមដ៏សំខាន់មួយដល់បរិស្ថាន ព្រមគ្នានឹងបញ្ហាប្រឈមសំខាន់ៗផ្សេងទៀត ដូចជា បញ្ហាអនាម័យ បញ្ហាគុណភាពទឹកនិងខ្យល់បរិយាកាស និងបញ្ហាបំពុលដីប្រើប្រាស់ជាដើម។

ក្នុងក្របខ័ណ្ឌនៃការអនុវត្តជាប្រចាំនូវគោលនយោបាយវិមជ្ឈការ និងវិសហមជ្ឈការរបស់រាជរដ្ឋាភិបាល កម្ពុជា ការគ្រប់គ្រងសំរាម សំណល់រឹង គឺជាកិច្ចការដ៏ចាំបាច់មួយ ក្នុងចំណោមការងារផ្សេងទៀត ដែលតម្រូវឱ្យ មានការពិនិត្យកែលម្អឡើងវិញ អំពីតួនាទី និងទទួលខុសត្រូវរវាងថ្នាក់រដ្ឋបាលនីមួយៗ ពាក់ព័ន្ធនឹងការ គ្រប់គ្រង និងផ្តល់ថវិកាលើការអនុវត្តកិច្ចការនេះ។ ក្នុងន័យនេះ រាជរដ្ឋាភិបាលកម្ពុជា នាពេលថ្មីៗនេះ ទើប បានអនុម័តអនុក្រឹត្យលេខ១១៣ ស្តីពីការគ្រប់គ្រងសំរាម សំណល់រឹងតាមទីប្រជុំជន ដែលពុំទាន់បានអនុវត្ត នៅឡើយ។

ជាក់ស្តែង ការគ្រប់គ្រងសំរាម សំណល់រឹង បានក្លាយជាកិច្ចការអាទិភាពរបស់រដ្ឋបាលថ្នាក់ក្រោមជាតិ ទោះបីក្នុងពេលវេលាខុសៗគ្នាក៏ដោយ អាស្រ័យតាមល្បឿននៃការរីកចម្រើនរបស់ទីក្រុង ទីប្រជុំជន។ ទីប្រជុំជនភាគច្រើនក្រៅពីរាជធានីភ្នំពេញ ការគ្រប់គ្រងសំរាម សំណល់រឹងដោយរដ្ឋបាលថ្នាក់ក្រោមជាតិ បាននិងកំពុងតែជួបប្រទះនូវបញ្ហាប្រឈមជាច្រើនក្នុងរយៈកាល១ទស្សវត្សន៍ចុងក្រោយនេះ ដែលរាជធានីភ្នំពេញធ្លាប់បានជួបបញ្ហាទាំងនេះមុនតំបន់ដ៏ទៃទៀត (ពោលគឺតាំងពីពាក់កណ្តាលទស្សវត្សន៍ឆ្នាំ១៩៩០)។ ម្យ៉ាងវិញទៀត គេសង្កេតឃើញថា ក្រុមហ៊ុនឯកជនហាក់ដូចជាអ្នកដែលបានផ្តួចផ្តើម និងបានទំនាក់ទំនងជាមួយស្ថាប័នរបស់រដ្ឋាភិបាល (ក្នុងការធ្វើកិច្ចសន្យាផ្តល់សេវាប្រមូលសំរាម)។ ការចុះហត្ថលេខាលើកិច្ចសន្យាទាំងនោះទៀតសោត ត្រូវបានធ្វើដោយសម្ងាត់ ដែលបណ្តាលឱ្យសាធារណៈជនមានការខឹងសម្បារ និងបានបន្ទោសអាជ្ញាធររដ្ឋាភិបាល ថាជាអ្នកបង្កើតបញ្ហា ចៀសជាងអ្នកជួយដោះស្រាយបញ្ហាទៅវិញ។

ចំពោះសកម្មភាពកែច្នៃប្រើប្រាស់ឡើងវិញ ជាទូទៅគេឃើញមានតែក្នុងទម្រង់ជាការកែច្នៃ ដែលមានលក្ខណៈក្រៅប្រព័ន្ធ ទាំងនៅក្នុង និងខាងក្រៅក្រុង ឬនៅតាមទីលានចាក់សំរាមជាដើម។ សំរាមដែលមានតម្លៃដូចជា ប្រភេទដបទឹកដែលអាចយកទៅកែច្នៃបាន (PET-bottles) វត្ថុធាតុជាអាលុយមីញ៉ូម ឬផ្លាស្ទិច ត្រូវបានញែក និងលក់ចេញទៅឈ្មួញកណ្តាល។ សំណល់ផ្សេងៗទៀត ត្រូវបានបោះចោលនៅទីលានចាក់សំរាមតាមជាយក្រុង ដោយគ្មានវិធានការការពារបរិស្ថានឡើយ។

## ១.៣. វិធីសាស្ត្រនៃការសិក្សាស្រាវជ្រាវ/អង្កេត

ដំបូងឡើយ យើងបានកំណត់យក ក្រុង ស្រុកចំនួន៤៦ ក្នុងចំណោមចំនួនក្រុង ស្រុកសរុប១៨៥ មកណែនាំបង្ហាញអំពីវិធីសាស្ត្រ និងខ្លឹមសារនៃការសិក្សាស្រាវជ្រាវនេះ។ ក្នុងចំណោមក្រុង ស្រុក ដែលបានកំណត់ទាំង៤៦ ខាងលើនេះ គឺមានក្រុងទាំង២៦ ក្នុងខេត្តទាំង២៤ រួមនឹងស្រុកចំនួន២០ក្នុងខេត្តចំនួន១២។ ការជ្រើសរើសស្រុកទាំង២០ នេះ គឺផ្អែកលើលក្ខណៈវិនិច្ឆ័យសំខាន់ៗដូចខាងក្រោម៖

- ស្រុកមានសក្តានុពល និងសកម្មភាពទេសចរណ៍
- ស្រុកមានសកម្មភាពសេដ្ឋកិច្ចឧស្សាហកម្មខ្លាំង
- ស្រុកនៅតំបន់ដាច់ស្រយាល

ក្រោយពីទទួលបានការពន្យល់បង្ហាញក្នុងសិក្ខាសាលាអំពីវិធីសាស្ត្រ និងខ្លឹមសារនៃការអង្កេត ដែលធ្វើឡើងនៅរាជធានីភ្នំពេញ ក្នុងខែកញ្ញា ឆ្នាំ២០១៥កន្លងមក គេបានកំណត់យកក្រុង ស្រុកចំនួន ៣៦ ឱ្យបំពេញបញ្ជីសំណួរ ក្នុងរយៈពេល១ខែ។ បញ្ជីសំណួរទាំងឡាយ ត្រូវបានផ្ញើមក*សម្ព័ន្ធភាពជាតិ* វិញនៅចុង ខែតុលា ឆ្នាំ២០១៥ សម្រាប់កំណត់លេខកូដ និងធ្វើការវិភាគទិន្នន័យ។

ដើម្បីបំពេញបន្ថែមលើកិច្ចការអង្កេតនេះ ការពិភាក្សាអំពីលទ្ធផលបឋម ជាមួយក្រុមពាក់ព័ន្ធតូចៗ (ទាំងថ្នាក់ជាតិ និងថ្នាក់ក្រុង ស្រុក) ត្រូវបានរៀបចំឡើង នៅរាជធានីភ្នំពេញនាថ្ងៃទី០៥ ខែវិច្ឆិកា ឆ្នាំ២០១៥ កន្លងទៅ។ លើសពីនេះទៅទៀត យើងក៏បានរៀបចំកិច្ចសម្ភាសន៍តាមដានបន្ថែមជាមួយនឹងប្រធានក្រុមប្រឹក្សាក្រុង គណៈអភិបាលក្រុងព្រះសីហនុ មន្ទីរបរិស្ថានខេត្ត និងគណៈអភិបាលខេត្តព្រះសីហនុផងដែរ។

## ១.៤. ចំណុចខ្វះខាតនៃការអង្កេត

ការអង្កេតនេះ ផ្តោតការយកចិត្តទុកដាក់តែទៅលើការចូលរួមរបស់រដ្ឋបាលក្រុង ស្រុកក្នុងកិច្ចការគ្រប់គ្រងសំរាម សំណល់រឹងតែប៉ុណ្ណោះ។ មានន័យថា ទាំងតួនាទី និងការអនុវត្តរបស់តួអង្គផ្សេងទៀត ដូចជារដ្ឋបាលខេត្ត មន្ទីរបរិស្ថានខេត្ត មន្ទីរសេដ្ឋកិច្ច និងហិរញ្ញវត្ថុខេត្ត ក្រុមប្រឹក្សាឃុំ សង្កាត់ និងវិស័យឯកជន ពុំត្រូវបានកំណត់ចូលក្នុងវិសាលភាពនៃការអង្កេតនេះឡើយ។

ម្យ៉ាងទៀត ការអង្កេតនេះ ពុំមែនជាការវាយតម្លៃលើការអនុវត្តការងាររបស់រដ្ឋបាលក្រុងស្រុក ពាក់ព័ន្ធនឹងការគ្រប់គ្រងសំរាម សំណល់រឹងនោះទេ។ ការអង្កេតនេះ គ្រាន់តែជាការប្រមូលព័ត៌មាននូវរាល់បញ្ហានានាទាក់ទងនឹងការអនុវត្តមុខងារនៃការគ្រប់គ្រងសំរាម សំណល់រឹង ដើម្បីជាការសិក្សា និងវិភាគបន្ថែមឱ្យបានកាន់តែស៊ីជម្រៅបន្ថែមទៀត។

ហេតុដូច្នេះ ការអង្កេតនេះ គ្រាន់តែផ្តល់ព័ត៌មានពាក់ព័ន្ធនឹងស្ថានភាពជាក់ស្តែងនៃការអនុវត្ត និងបញ្ហាប្រឈមនានាក្នុងការគ្រប់គ្រងសំរាម សំណល់រឹង ដោយរដ្ឋបាលក្រុង ស្រុក ដល់សម្ព័ន្ធភាពជាតិសមាគមក្រុមប្រឹក្សា ក្រុង ស្រុក ខណ្ឌ ឃុំ សង្កាត់ នៃព្រះរាជាណាចក្រកម្ពុជាតែប៉ុណ្ណោះ។

ព័ត៌មានទាំងនេះ នឹងផ្តល់ជាប្រយោជន៍ដល់គ្រប់ភាគីពាក់ព័ន្ធទាំងថ្នាក់ជាតិ និងថ្នាក់ក្រោមជាតិ ក្នុងការរៀបចំគោលនយោបាយ និងលិខិតបទដ្ឋានគតិយុត្តនានា ក្នុងពេលអនុវត្តអនុក្រឹត្យលេខ១១៣។

# ជំពូក ២ លទ្ធផលនៃការអង្កេត

## ២.១. ក្របខ័ណ្ឌលិខិតបទដ្ឋានគតិយុត្ត (ការស្រាវជ្រាវលើលិខិតបទដ្ឋានគតិយុត្តកន្លងមក)

### ២.១.១. លិខិតបទដ្ឋានគតិយុត្តថ្នាក់ជាតិ

ផ្អែកតាមលិខិតបទដ្ឋានគតិយុត្តថ្នាក់ជាតិ ការគ្រប់គ្រងសំរាម សំណល់រឹង ត្រូវបានរៀបចំតាក់តែងឡើងតាំងពីឆ្នាំ១៩៩៩ មកម្ល៉េះ។ អនុក្រឹត្យលេខ៣៦ របស់រាជរដ្ឋាភិបាល ដែលបានអនុម័តនាថ្ងៃទី២៧ ខែមេសា ឆ្នាំ១៩៩៩ ព្រមទាំងនឹងគោលការណ៍ណែនាំសម្រាប់អនុវត្តអនុក្រឹត្យនេះ ត្រូវបានដាក់ចេញ៥ខែក្រោយមក។ បន្ទាប់ពីការដាក់នូវអនុក្រឹត្យនេះ មានប្រកាសអន្តរក្រសួងលេខ៨០ រវាងក្រសួងមហាផ្ទៃ និងក្រសួងបរិស្ថានក្នុងឆ្នាំ២០០៣ ស្តីពីការគ្រប់គ្រងសំរាម សំណល់រឹង នៅថ្នាក់ខេត្ត ក្រុង ក៏ត្រូវបានយកមកពិភាក្សាជាឯកសារយោងក្នុងការអង្កេតនេះដែរ ហើយប្រកាសអន្តរក្រសួងនេះនៅតែមានសុពលភាពក្នុងអំឡុងពេលនៃការអង្កេតនេះ។

ប្រកាសអន្តរក្រសួងលេខ៨០ មានវិសាលភាពគ្របដណ្តប់សកម្មភាពគ្រប់គ្រងសំរាមសំណល់រឹងទាំងឡាយ ដោយរាប់បញ្ចូលទាំងការប្រមូល ការសម្អាត ការស្តុកទុកបណ្តោះអាសន្ន ការដឹកជញ្ជូន ការកែច្នៃ និងការបោះចោលសំរាម សំណល់រឹងគ្រប់ប្រភេទទាំងអស់។ ប្រកាសនេះ មានគោលបំណងលើកកម្ពស់ការទទួលខុសត្រូវរបស់អាជ្ញាធរមូលដ្ឋាន និងសមត្ថកិច្ចពាក់ព័ន្ធនានា ក្នុងការអនុវត្តវិធានការគ្រប់គ្រងសំរាម សំណល់រឹងនៅថ្នាក់ខេត្ត ក្រុង ប្រកបដោយប្រសិទ្ធភាពទូទាំងប្រទេស។ អាជ្ញាធរក្រុង ដែលប្រកាសអន្តរក្រសួងខាងលើនេះ និយាយសំដៅនោះ រួមមាន រាជធានីភ្នំពេញ ក្រុងព្រះសីហនុ ក្រុងកែប និងក្រុងប៉ៃលិន។ រហូតមកដល់បច្ចុប្បន្ន ក្រុងទាំងនោះដែលរៀបរាប់ខាងលើ ត្រូវបានគេប្តូរទៅជារាជធានី និងខេត្ត។

ជារួម ប្រកាសអន្តរក្រសួងលេខ៨០ ផ្តល់ទៅឱ្យអាជ្ញាធរដែនដី និងសមត្ថកិច្ចពាក់ព័ន្ធនានានូវតួនាទី និងការទទួលខុសត្រូវដូចខាងក្រោម៖

- ដាក់ធុងសំរាមឱ្យបានគ្រប់គ្រាន់ ដើម្បីធានានូវសោភ័ណភាព និងបរិស្ថានស្អាត
- ដាក់ស្លាកហាមចោលសំរាម និងអប់រំឱ្យមានការទុកដាក់សំរាម សំណល់រឹង ឱ្យបានត្រឹមត្រូវ
- រៀបចំ និងកំណត់ទីលានចាក់សំរាម សំណល់រឹងបណ្តោះអាសន្ន ឱ្យបានសមរម្យដោយគ្មានការរំខានដល់ចរាចរណ៍ សុខភាពសាធារណៈ សោភ័ណភាព និងសណ្តាប់ធ្នាប់សង្គម
- ប្រមូល សម្អាត និងដឹកជញ្ជូនសំរាម សំណល់រឹង ទៅបោះចោលឱ្យបានទៀងទាត់នៅទីលានចាក់សំរាម ដែលបានកំណត់ដោយអាជ្ញាធរដែនដី និងសមត្ថកិច្ចពាក់ព័ន្ធ
- ក្រុមប្រឹក្សាឃុំ សង្កាត់ ដោយមានកិច្ចសហការជាមួយស្ថាប័ន ឬអង្គភាពពាក់ព័ន្ធនានា ត្រូវអប់រំ និងផ្សព្វផ្សាយព័ត៌មានដល់សាធារណៈជន អំពីការទុកដាក់សំរាម សំណល់រឹង តាមរយៈវិធីសាស្រ្តប្រកបដោយអនាម័យ និងសុវត្ថិភាពបរិស្ថាន។ ដើម្បីកាត់បន្ថយការផលិតសំរាម សំណល់រឹង ក្រុមប្រឹក្សាឃុំ សង្កាត់ ត្រូវតែជំរុញ និងលើកទឹកចិត្តឱ្យមានសកម្មភាពកែច្នៃសំរាម ឬដំណើរការកែច្នៃសំរាមនៅក្នុងមូលដ្ឋានរបស់ខ្លួន។

- មន្ទីរបរិស្ថានខេត្ត ក្រុង និងការិយាល័យបរិស្ថានស្រុក ខណ្ឌ ត្រូវដើរតួនាទីជាសេនាធិការឱ្យអាជ្ញាធរមូលដ្ឋានក្នុងការរៀបចំផែនការគ្រប់គ្រង និងចូលរួមបង្កើតផែនការសកម្មភាព ក្នុងការប្រមូល ការស្តុកសំរាមបណ្តោះអាសន្ន ការដឹកជញ្ជូន និងការចាក់សំរាមក្នុងទីលានចាក់សំរាម ដោយត្រូវសហការ និងតាមដានការអនុវត្តផែនការទាំងនេះផងដែរ។ រាយការណ៍អំពីការអនុវត្តផែនការសកម្មភាពរបស់ខ្លួន អំពីការប្រមូល ការស្តុកទុកបណ្តោះអាសន្ន ការដឹកជញ្ជូន និងការចាក់សំរាមក្នុងទីលានចាក់សំរាម ដោយត្រូវផ្ញើរបាយការណ៍នេះទៅកាន់ក្រសួងមហាផ្ទៃ និងក្រសួងបរិស្ថាន ព្រមទាំងស្ថាប័នពាក់ព័ន្ធនានាទៀតផងដែរ។

តាមរយៈមុខងារដែលបានធ្វើប្រតិភូកម្ម ដូចបានកំណត់ក្នុងប្រកាសមួយនេះ រដ្ឋបាលក្រុងស្រុក ពុំមានតួនាទី និងការទទួលខុសត្រូវច្បាស់លាស់នៅឡើយ។ នៅក្នុងប្រកាសនេះ រដ្ឋបាលក្រុង ស្រុក មានចែងតែនៅក្នុងមាត្រា៣ប៉ុណ្ណោះ ស្តីពី "និយមន័យ" ចំណែកខេត្ត និងក្រុង(ដែលឥឡូវនេះត្រូវបានប្តូរទៅជារដ្ឋបាលខេត្ត និងរាជធានី) មន្ទីរ និងការិយាល័យបរិស្ថានក្រុង ស្រុក និងក្រុមប្រឹក្សាឃុំ សង្កាត់ មានចែងអំពីភារកិច្ចដែលត្រូវបានធ្វើប្រតិភូកម្មរួមមាន ការអប់រំ ការផ្សព្វផ្សាយដល់ប្រជាពលរដ្ឋទាំងអស់ អំពីចំណេះដឹង និងបច្ចេកទេសទុកដាក់សំរាម ការចាក់សំរាម សំណល់រឹង តាមវិធីប្រកដដោយអនាម័យ និងសុវត្ថិភាពបរិស្ថាន ដើម្បីកាត់បន្ថយបរិមាណសំរាម សំណល់រឹងជាដើម។

អនុក្រឹត្យលេខ១១៣ ដែលទើបនឹងទទួលបានការអនុម័តថ្មីនេះ (ខែសីហា ឆ្នាំ២០១៥) បានកំណត់អណត្តិកាន់តែច្បាស់លាស់ និងមានភាពប្រសើរដល់រដ្ឋបាលក្រុង ស្រុក ក្នុងការងារគ្រប់គ្រងសំរាម សំណល់រឹង ប៉ុន្តែអនុក្រឹត្យនេះនៅពុំទាន់បានអនុវត្តនៅឡើយ។ អនុក្រឹត្យលេខ១១៣នេះមានគោលបំណងដូចខាងក្រោម៖

- ពង្រឹងការទទួលខុសត្រូវរបស់ក្រសួង ស្ថាប័ន អង្គភាពជំនាញ រដ្ឋបាលថ្នាក់ក្រោមជាតិ និងភាគីពាក់ព័ន្ធនានា ដែលធ្វើការលើផ្នែកគ្រប់គ្រងសំរាម សំណល់រឹងតាមទីប្រជុំជន
- ប្រគល់ភារកិច្ចគ្រប់គ្រងសំរាម សំណល់រឹងតាមទីប្រជុំជនឱ្យរដ្ឋបាលក្រុង ស្រុក
- កំណត់វិធានការចាំបាច់នានា សំដៅលើកកម្ពស់ប្រសិទ្ធភាព និងសុវត្ថិភាពការងារគ្រប់គ្រងសំរាម សំណល់រឹងតាមទីប្រជុំជន
- លើកកម្ពស់ការយល់ដឹង និងការចូលរួមរបស់ប្រជាពលរដ្ឋក្នុងការអភិវឌ្ឍ និងអនុវត្តការងារគ្រប់គ្រងសំរាម សំណល់រឹងតាមមូលដ្ឋាន។

យោងស្មារតីនៃអនុក្រឹត្យលេខ១១៣នេះ រដ្ឋបាលខេត្ត មានភារកិច្ចគ្រាន់តែជាអ្នកផ្តល់ការគាំទ្រ សម្របសម្រួល និងលើកទឹកចិត្ត ក្នុងការអនុវត្តការគ្រប់គ្រងសំរាម សំណល់រឹងតែប៉ុណ្ណោះ រីឯការងារទាំងឡាយ នឹងត្រូវអនុវត្តផ្ទាល់ដោយរដ្ឋបាលក្រុង ស្រុក។ មានន័យថា ក្រោយពីអនុក្រឹត្យនេះចូលជាធរមាន រដ្ឋបាលក្រុង ស្រុក មានតួនាទីកាន់តែច្បាស់ថែមទៀតលើការងារគ្រប់គ្រងសំរាម សំណល់រឹងនេះ។

### ២.១.២. លិខិតបទដ្ឋានគតិយុត្តថ្នាក់ក្រុង ស្រុក

ដោយសារតែប្រកាសអន្តរក្រសួងលេខ៨០ ពុំបានផ្តល់តួនាទី និងការទទួលខុសត្រូវដល់រដ្ឋបាលក្រុង ស្រុកឱ្យបានច្បាស់លាស់ រដ្ឋបាលក្រុង ស្រុកចំនួន១១(៣១%) ក្នុងចំណោម៣៦ដែលបានបំពេញបញ្ជីសំណួរ បានអះអាងថា រដ្ឋបាលរបស់ខ្លួនបានដាក់ចេញលិខិតបទដ្ឋានមួយចំនួនបន្ថែមលើប្រកាសអន្តរក្រសួងនេះអំពីការងារគ្រប់គ្រងសំរាម សំណល់រឹង។ ក្នុងចំណោមក្រុង ស្រុកទាំង១១នោះ មានក្រុងបាត់ដំបង កំពត និងស្ទឹងត្រែង បានចេញដីកាចំនួន៤។ ទន្ទឹមនឹងនេះ ក្រុមប្រឹក្សាស្រុកប្រាសាទសំបូរ ក្រុងក្រចេះ ក្រុងកំពត ក្រុងកំពង់ចាម និងក្រុងកែប បានដាក់ចេញដីកាយ៉ាងតិចចំនួន១ បន្ថែមលើប្រកាសអន្តរក្រសួងនោះ។ ដើម្បីបង្ហាញបន្ថែម សូមពិនិត្យមើលតារាងមាតិកាខាងក្រោម នូវគំរូដីកាមួយដែលមាន៤មាត្រា ដាក់ចេញដោយក្រុងកំពតស្តីពីការគ្រប់គ្រងសំរាម សំណល់រឹង ដែលក្រុមប្រឹក្សាក្រុងកំពតបានអនុម័តនាឆ្នាំ២០១៤កន្លងមក។

*តារាង១៖ ដីកាចេញដោយសាលាក្រុងកំពត ស្តីពីការញែកសំរាម សំណល់រឹង*

| |
|---|
| មាត្រា១៖ គោលបំណងរបស់ដីកា<br>មាត្រា២៖ វិសាលភាពដែលកំណត់ពីតំបន់ និងទីកន្លែង ដែលប្រជាពលរដ្ឋ និងអង្គភាពនានាត្រូវធ្វើការញែកសំរាម មុននឹងចោលសំរាម សំណល់រឹង<br>មាត្រា៣៖ តួនាទីនៃយន្តការអនុវត្ត<br>▪ ក្រុមប្រឹក្សាក្រុង<br>▪ គណៈអភិបាលក្រុង<br>▪ ក្រុមប្រឹក្សាសង្កាត់<br>មាត្រា៤៖ តួនាទី និងកាតព្វកិច្ចរបស់ប្រជាពលរដ្ឋ និង/ឬអង្គភាពនានា |

រដ្ឋបាលក្រុង ស្រុកភាគច្រើនដែលបានបំពេញបញ្ជីសំណួរ បានរាយការណ៍ថា រដ្ឋបាលរបស់ខ្លួន បានផ្សព្វផ្សាយទាំងឯលិខិតបទដ្ឋានរបស់ថ្នាក់ខេត្ត និងថ្នាក់ជាតិ ដល់ក្រុមប្រឹក្សាឃុំ សង្កាត់ អាជីវករ និងភាគីពាក់ព័ន្ធផ្សេងៗទៀត ក្នុងដែនសមត្ថកិច្ចរបស់ខ្លួន។ ចំពោះរដ្ឋបាលក្រុង ស្រុកខ្លះ ដែលពុំមានការិយាល័យបរិស្ថាន កិច្ចការផ្សព្វផ្សាយព័ត៌មាននេះ ត្រូវបានប្រគល់ជូន និងអនុវត្តដោយការិយាល័យអន្តរវិស័យរបស់ខ្លួន និង/ឬ ការិយាល័យពីរផ្សេងទៀតគឺ៖ ការិយាល័យរដ្ឋបាល និងហិរញ្ញវត្ថុ និងការិយាល័យផែនការ និងគាំទ្រឃុំ សង្កាត់។

## ២.២. ការអនុវត្តជាក់ស្តែង

### ២.២.១. ស្ថានភាពទូទៅនៃការគ្រប់គ្រងសំរាម សំណល់រឹងនៅថ្នាក់ក្រុង ស្រុក

កំណើនសំរាម គឺកើតឡើងដោយសារកំណើនជីវភាពរស់នៅរបស់ប្រជាពលរដ្ឋ។ យោងតាមរដ្ឋបាលក្រុង ស្រុក សំរាមមានប្រភពសំខាន់ៗមកពីលំនៅដ្ឋានប្រជាពលរដ្ឋ ទីផ្សារ ភោជនីយដ្ឋាន តំបន់ទេសចរណ៍ និងរោងចក្រ។ ប្រភពបង្កើតសំរាមបន្ទាប់ គឺតាមទីសាធារណៈ គ្លីនិកឯកជន សហគ្រាស ការិយាល័យរដ្ឋ និងឯកជន សាលារៀន និងតាមតំបន់ប្រាសាទនានា។ល។ ប្រមាណជា៨%នៃក្រុង ស្រុកដែលបានឆ្លើយសំណួរ

បានអះអាងពីប្រភពសំរាមមួយទៀតក្នុងក្រុង ស្រុករបស់ខ្លួនគឺតាមការដ្ឋានសំណង់ និងចំណតរថយន្ត ចំណែក ៣%ទៀត អះអាងថាសំរាមមានប្រភពមកពីការប្រារព្ធពិធីមង្គលការ ពិធីសាសនាម្តងម្កាល និងប្រភពមកពីអ្នកដំណើរជាដើម។

តាមរយៈការអង្កេតនេះ ការអនុវត្តការគ្រប់គ្រងសំរាម សំណល់រឹងនៅថ្នាក់ក្រុង ស្រុក មានលក្ខណៈផ្សេងៗគ្នាគួរឱ្យកត់សម្គាល់។ នៅតាមបណ្តាក្រុង ស្រុកដាច់ស្រយាលភាគច្រើន ការយល់ឃើញអំពីការងារគ្រប់គ្រងសំរាម សំណល់រឹងនេះនៅតែចោទជាបញ្ហា។ រដ្ឋបាលក្រុង ស្រុកភាគច្រើន ព្រមទាំងស្ថាប័នពាក់ព័ន្ធផ្សេងទៀត(បណ្តាការិយាល័យជំនាញថ្នាក់ស្រុកនានា)យល់ថា ប្រជាពលរដ្ឋមានទាំងដី និងមធ្យោបាយក្នុងការទទួលខុសត្រូវបញ្ហាសំរាមដោយខ្លួនឯង។ ម្យ៉ាងទៀត ប្រជាពលរដ្ឋទាំងនោះ យល់ថាការគ្រប់គ្រងសំរាម គួរតែជាការទទួលខុសត្រូវរបស់គ្រួសារនីមួយៗតាមរយៈការកប់ និងដុតសំរាម។ បញ្ហាអនាម័យតាមជនបទដាច់ស្រយាល ត្រូវគេយល់ជាភារកិច្ចរបស់អង្គភាពផ្សេងៗ ដូចជាក្រសួងអភិវឌ្ឍន៍ជនបទ ប៉ុន្តែក្រសួងនេះទូទៅផ្តោតតែទៅលើការសាងសង់បន្ទន់អនាម័យ និងការលាងសម្អាតដៃជាដើម។ ក្រសួងនេះទៀតសោត ត្រូវបានគេដឹងថាពុំមានបុគ្គលិកគ្រប់គ្រាន់ និងកំពុងជួបប្រទះបញ្ហាប្រឈមជាច្រើន ពិសេសរបៀបអនុវត្តតាមបែបមជ្ឈការនៅឡើយ។

ការគ្រប់គ្រងសំរាម សំណល់រឹងតាមទីប្រជុំជននៅថ្នាក់ក្រុង ស្រុក ក៏មានការគ្រប់គ្រងរៀបចំដោយរបៀបផ្សេងៗគ្នាផងដែរ។ នៅតាមទីប្រជុំជន និងទីរួមស្រុកដែលជាកន្លែងប្រកបអាជីវកម្ម និងមានទីផ្សារអ៊ូអរស្ថិតក្រោមការគ្រប់គ្រងត្រួតពិនិត្យដោយផ្ទាល់ពីរដ្ឋបាលខេត្ត មន្ទីរសេដ្ឋកិច្ច និងហិរញ្ញវត្ថុខេត្ត ជាអ្នកចុះហត្ថលេខាឯកភាពជាមួយនឹងក្រុមហ៊ុនប្រមូលសំរាមលើកិច្ចការប្រមូលសំរាម។ អាជីវករ និងពលរដ្ឋដែលមានទីតាំងក្បែរផ្សារ បានពិភាក្សា និងព្រមព្រៀងជាមួយនឹងក្រុមហ៊ុនប្រមូលសំរាម ដែលចុះកិច្ចសន្យាជាមួយនឹងអាជ្ញាធរខាងលើឱ្យមកប្រមូលសំរាម សំណល់រឹងពីទីតាំង និងលំនៅដ្ឋានរបស់ខ្លួន។ ការប្រមូលសំរាមក្នុងរូបភាពបែបនេះកំពុងតែជួបនឹងបញ្ហាប្រឈមជាច្រើន ដោយសារតែកំណើនពលរដ្ឋតាមទីប្រជុំជន។ ក្រុមហ៊ុនប្រមូលសំរាមឯកជនទាំងនោះទៀតសោត ពុំមានជំនាញ សម្ភារៈ និងឧបករណ៍ប្រមូលសំរាមគ្រប់គ្រាន់ឡើយ ដូចនេះជាទូទៅ គេគ្រាន់តែចុះកិច្ចសន្យាប្រមូលកម្រៃសេវាសំរាមតែតាមទីផ្សារតែប៉ុណ្ណោះ។

ក្នុងស្រុកមួយចំនួន ដែលស្ថិតនៅក្បែរទីរួមខេត្ត (ពោលគឺស្ថិតនៅក្បែរក្រុង) ដូចជាស្រុកកំពង់សៀមនៃខេត្តកំពង់ចាម និងស្រុកទឹកឈូនៃខេត្តកំពត ក្រុមហ៊ុនប្រមូលសំរាម ដែលបានទទួលកិច្ចសន្យាប្រមូលសំរាមពីរដ្ឋបាលខេត្តក្នុងការប្រមូលសំរាមតាមបណ្តាតំបន់ផ្សេងៗដែលនៅក្បែរក្រុង(ទីរួមខេត្ត) បានផ្តើមដាក់បញ្ចូលតំបន់ជាយក្រុងទាំងនោះ(ពិសេសតំបន់ទីផ្សារ) ក្នុងផែនការប្រមូលសំរាមផងដែរ។ ការពង្រីកសេវាប្រមូលសំរាមទៅដល់តំបន់ជាយក្រុងទាំងនេះ មិនមែនគ្រាន់តែដោយផ្អែកលើការចរចាររវាងរដ្ឋបាលខេត្ត និងស្រុកជាមួយនឹងក្រុមហ៊ុនប្រមូលសំរាមតែប៉ុណ្ណោះ ប៉ុន្តែក៏អាស្រ័យទៅលើចេតនារបស់ប្រជាពលរដ្ឋក្នុងការបង់ប្រាក់កម្រៃសេវាប្រមូលនេះផងដែរ។

ក្នុងក្រុងភាគច្រើន មុខងារនៃការគ្រប់គ្រងសំរាម សំណល់រឹង ត្រូវបានផ្ទេរឱ្យទៅក្រុមហ៊ុនឯកជន ជាអ្នកប្រមូលសំរាម ដែលក្នុងនោះមានដូចជា ក្រុមហ៊ុនGAEA ក្រុមហ៊ុនCINTRI និងក្រុមហ៊ុនផ្សេងៗទៀត។ ក្រុមហ៊ុនទាំងនេះ តែងរងការចោទប្រកាន់ថាពុំបានផ្តល់សេវាប្រមូលសំរាមបានល្អឡើយ ព្រោះថាគេអាចចូលទៅប្រមូលសំរាមបានតែក្នុងតំបន់មួយចំនួនក្នុងក្រុង ពោលគឺបានតែ១ទៅ២សង្កាត់តែប៉ុណ្ណោះ។ លើសពីនេះទៅ

ទៀត ក្រុមហ៊ុនទាំងនេះ ត្រូវបានគេរិះគន់ថាប្រមូលតែសំរាមក្នុងធុង និងតាមទីផ្សារតែប៉ុណ្ណោះ ដោយពុំបានយកចិត្តទុកដាក់ប្រមូលសំរាមតាមទីសាធារណៈ ឬលើដងផ្លូវសោះឡើយ។ ក្នុងស្ថានភាពបែបនេះ មានក្រុងមួយចំនួន កន្លងមកបានរៀបចំជាក្រុមកម្មករប្រមូលសំរាមដោយសាលាក្រុងខ្លួនឯង ដោយត្រូវប្រមូលសំរាមតាមទីសាធារណៈក្នុងកម្មវិធី"ប្រកួតប្រជែងទីក្រុងស្អាត" ដែលជាកម្មវិធីកំពុងដំណើរការ និងស្ថិតក្រោមការឧបត្ថម្ភពីរាជរដ្ឋាភិបាលកម្ពុជា។

មានក្រុងតិចតួចណាស់ ដូចជាក្រុងស្ទឹងត្រែង និងក្រុងបាត់ដំបងជាដើម បានបង្កើតជាការិយាល័យគ្រប់គ្រងសំរាម-សំណល់រឹងដោយខ្លួនឯង។ ការិយាល័យនេះជាអង្គភាពសាធារណៈ និងមិនសំដៅរកប្រាក់ចំណេញក្នុងការបំពេញការងារគ្រប់គ្រងសំរាម សំណល់រឹងនោះទេ។ ការិយាល័យទាំងនេះ ប្រតិបត្តិការ និងសហការយ៉ាងជិតស្និទជាមួយប្រជាពលរដ្ឋតាមរយៈគម្រោងផ្តួចផ្តើមមួយដោយអង្គការក្រៅរដ្ឋាភិបាល ឬស្ថាប័នផ្តល់ជំនួយខាងក្រៅផ្សេងទៀត (សូមអានករណីសិក្សាទី២ខាងក្រោមបន្ថែម)។

## ២.២.២. តួនាទី និងការទទួលខុសត្រូវរបស់រដ្ឋបាលក្រុង ស្រុក

### ក) ក្រុមប្រឹក្សា (Council)

ក្រុមប្រឹក្សាក្រុង ស្រុក ជាទូទៅត្រូវបានគេបំភ្លេចលើកិច្ចការគ្រប់គ្រងសំរាម សំណល់រឹង។ ទោះបីមានក្រុមប្រឹក្សាក្រុង ស្រុកចំនួន១១(៣១%) ឆ្លើយថាបានចេញលិខិតបទដ្ឋានគតិយុត្តនានា ប៉ុន្តែមានតែរដ្ឋបាលក្រុង ស្រុកចំនួន៤ប៉ុណ្ណោះ បានពាក់ព័ន្ធជាមួយនឹងក្រុមប្រឹក្សារបស់ខ្លួន គ្រាន់តែសុំឱ្យអនុម័តលើលិខិតបទដ្ឋានចំនួន១-២តែប៉ុណ្ណោះ។ លិខិតបទដ្ឋាននានា ដែលទទួលបានការអនុម័តពីក្រុមប្រឹក្សា ជាទូទៅច្រើនតែពាក់ព័ន្ធនឹងលិខិតបទដ្ឋានណែនាំប្រជាពលរដ្ឋក្នុងការប្រមូល ទុកដាក់ ញែកសំរាមតាមលំនៅដ្ឋាន និងកំណត់ទីតាំងធុងសំរាម ទីលានចាក់សំរាម និងកាលវិភាគប្រមូលសំរាមជាដើម។

យ៉ាងណាក្តី ក្រុមប្រឹក្សាក្រុង ស្រុកភាគច្រើន បានលើកឡើងអំពីបញ្ហាការងារគ្រប់គ្រងសំរាម សំណល់រឹងនេះ ហើយក៏បានលើកទឹកចិត្តដល់គណៈអភិបាលក្រុង ស្រុករបស់ខ្លួនឱ្យធ្វើការជាមួយនឹងការិយាល័យរបស់ខ្លួន ព្រមទាំងក្រុមប្រឹក្សាឃុំ សង្កាត់ ក្នុងការអប់រំ និងផ្សព្វផ្សាយដល់សាធារណៈជនអំពីបញ្ហានេះ។

### ខ) គណៈអភិបាល (Board of Governors)

មានរបាយការណ៍ថា គណៈអភិបាលក្រុង ស្រុក ទទួលបានការសហការច្រើនពាក់ព័ន្ធនឹងបញ្ហាគ្រប់គ្រងសំរាម សំណល់រឹងនេះ។ ក្នុងចំណោមក្រុង ស្រុកដែលបានចូលរួមក្នុងការអង្កេត មាន១៣ក្រុង ស្រុក (៣៦%)បានអះអាងថា ពួកគាត់បានអប់រំសហគមន៍ និងសាធារណៈជន អំពីការគ្រប់គ្រងសំរាម សំណល់រឹងតាមទីប្រជុំជន។ ក្រុង ស្រុកចំនួន៣(១៧%) បានបញ្ជាក់បន្ថែមថាបញ្ហាគ្រប់គ្រងសំរាមសំណល់រឹង ត្រូវបានដាក់បញ្ចូលទៅក្នុងផែនការអភិវឌ្ឍ៥ឆ្នាំ និងគម្រោងវិនិយោគ៣ឆ្នាំរំកិលរបស់ក្រុង ស្រុក។ មានក្រុង ស្រុកចំនួន១៧% ក៏បានបង្ហាញថា បានត្រួតពិនិត្យការងារក្រុមហ៊ុនប្រមូលសំរាមយ៉ាងទៀងទាត់។ មានក្រុង ស្រុកចំនួន៤ (១១%) បានពិនិត្យសៀវភៅបន្ទុកអំពីការងាររបស់ក្រុមហ៊ុនឯកជនប្រមូលសំរាម។

ក្រុង ស្រុកដែលបានចូលរួមអង្កេតប្រមាណ២០% បានអះអាងថា ខ្លួនបានរៀបចំទិវាបរិស្ថានប្រចាំឆ្នាំ។ ក្នុងចំនួនក្រុង ស្រុកដូចគ្នានេះដែរ បានជួបប្រជុំជាមួយក្រុមប្រឹក្សាឃុំ សង្កាត់ពាក់ព័ន្ធនឹងការអនុវត្តសកម្មភាព

គ្រប់គ្រងសំរាម សំណល់រឹង។ មានក្រុង ស្រុកតិចតួច ដែលបានធ្វើកាលវិភាគប្រចាំខែ សម្រាប់ធ្វើការយុទ្ធនាការប្រមូលសំរាម (ការចុះប្រមូលសំរាមផ្ទាល់) ជាមួយក្រុមប្រឹក្សាឃុំ។ ក្រុងព្រះសីហនុ បានធ្វើការជាមួយសង្កាត់ទាំង៥របស់ខ្លួន បានអនុវត្តយុទ្ធនាការប្រមូលសំរាមផ្ទាល់នៅតាមសង្កាត់នីមួយៗជារៀងរាល់ចុងសប្តាហ៍។ សង្កាត់នីមួយៗជាអ្នកស្នើ និងកំណត់ទីកន្លែងដែលត្រូវធ្វើយុទ្ធនាការសម្អាត ហើយរដ្ឋបាលក្រុង អញ្ជើញមន្ត្រីចំនួន៤០-៦០នាក់ យុវជន អង្គការក្រៅរដ្ឋាភិបាល ព្រមទាំងតំណាងសមាគមភ្នាក់ងារទេសចរណ៍មកចូលរួមផងដែរ។

ជាចំណុចល្អ ដែលមានក្រុងចំនួន៧(១៩%) នៃក្រុង ស្រុកទាំង៣៦ ដែលបានបំពេញបញ្ជីសំណួរ ឬស្មើ២៧%នៃចំនួនក្រុងទាំង២៦ទូទាំងប្រទេស បានចុះកិច្ចព្រមព្រៀងជាមួយក្រុមហ៊ុនឯកជនក្នុងការប្រមូលសំរាម សំណល់រឹង ឬក្រុមតាស៊ីផ្សារ។ របាយការណ៍ បង្ហាញថា រដ្ឋបាលខេត្តបានផ្ទេរមុខងារចុះហត្ថលេខាលើកិច្ចព្រមព្រៀងឱ្យទៅរដ្ឋបាលក្រុង ដើម្បីធ្វើការពិនិត្យ និងដោះស្រាយដោយផ្ទាល់ជាមួយក្រុមហ៊ុនឯកជន។ ក្នុងចំណោមក្រុងទាំង៧ខាងលើ មានក្រុង១ បានព្រមព្រៀងចុះហត្ថលេខាជាមួយក្រុមហ៊ុនឯកជនប្រចាំឆ្នាំ ខណៈដែលក្រុងដ៏ទៃទៀត ប្រើប្រាស់កិច្ចសន្យារយៈពេលវែងពី១៥-៣០ឆ្នាំ។ យ៉ាងណាក្តី នៅតែមានក្រុង ស្រុកមួយចំនួនបានលើកឡើងថា ការពិនិត្យកិច្ចសន្យាលើការអនុវត្តការគ្រប់គ្រងសំរាម សំណល់រឹង គឺមានតែរដ្ឋបាលខេត្ត ឬអាជ្ញាធរថ្នាក់លើតែប៉ុណ្ណោះទើបអាចមានសិទ្ធិពិនិត្យការងារនេះបាន។

ជាគោលការណ៍ រដ្ឋបាលក្រុង ស្រុក បានអះអាងថា ខ្លួនអាចទទួលខុសត្រូវបានយ៉ាងច្រើន ប្រសិនបើរដ្ឋបាលខេត្ត និងមន្ទីរសេដ្ឋកិច្ច និងហិរញ្ញវត្ថុខេត្ត អនុញ្ញាតិ និងជួយគាំទ្រទាំងផ្នែកថវិកា និងបច្ចេកទេស។ ការទទួលខុសត្រូវទាំងនេះ រួមមានការតាមដាន និងការត្រួតពិនិត្យការអនុវត្តកិច្ចសន្យាផ្តល់សេវាសំរាម សំណល់រឹងដោយក្រុមហ៊ុនឯកជន ដូចជាការពិនិត្យតាមដានលើកាលវិភាគ និងមធ្យោបាយប្រមូលសំរាម ការការពារបរិស្ថានទីលានចាក់សំរាម សកម្មភាពអប់រំ និងផ្សព្វផ្សាយអំពីការគ្រប់គ្រងសំរាម និងបញ្ហាអនាម័យដល់សាធារណៈជន ការសម្របសម្រួលវិវាទ ព្រមទាំងការកៀរគរការចូលរួមពីសហគមន៍ជាដើម។

### គ) ការិយាល័យចំណុះសាលាក្រុង ស្រុក និងការិយាល័យបរិស្ថានក្រុង ស្រុក

នៅថ្នាក់ក្រុង ស្រុក មានការិយាល័យពីរប្រភេទ។ រដ្ឋបាលក្រុង ស្រុក មានការិយាល័យបី ដែលនៅក្រោមរចនាសម្ព័ន្ធរបស់ខ្លួន។ ការិយាល័យទាំងនោះរួមមាន ការិយាល័យរដ្ឋបាលនិងហិរញ្ញវត្ថុ ការិយាល័យផែនការ និងគាំទ្រឃុំ សង្កាត់ និងការិយាល័យអន្តរវិស័យ។ ការិយាល័យអន្តរវិស័យគឺពុំមានបុគ្គលិក និងធនធានគ្រប់គ្រាន់នៅឡើយដែលសង្កេតឃើញស្ទើរគ្រប់រដ្ឋបាលក្រុង ស្រុកនៅទូទាំងប្រទេស។

ប្រភេទមួយទៀតគឺការិយាល័យជំនាញជាខ្សែបណ្តោយរបស់ក្រសួង។ ក្នុងក្របខ័ណ្ឌនៃការងារគ្រប់គ្រងសំរាម សំណល់រឹង មន្ទីរបរិស្ថានខេត្ត អនុវត្តកិច្ចការបរិស្ថានក្នុងនាមជាក្រសួងបរិស្ថាន ដោយពុំបានផ្ទេរមុខងារនេះឱ្យទៅការិយាល័យរបស់ខ្លួននៅតាមថ្នាក់ក្រុង ស្រុកនៅឡើយ។ ការគ្រប់គ្រងការងារបរិស្ថានក្នុងខេត្ត ដែលទទួលខុសត្រូវដោយមន្ទីរបរិស្ថានខេត្ត គឺដោយសារហេតុផលខ្វះខាតបុគ្គលិកមានសមត្ថភាពមកបម្រើការតាមការិយាល័យនៅថ្នាក់ក្រុង ស្រុក។ មានរដ្ឋបាលក្រុងស្រុកចំនួន១៤ក្នុងចំណោម៣៦ បានអះអាងថា រដ្ឋបាលរបស់ខ្លួន មិនមានទាំងការិយាល័យបរិស្ថាន និងបុគ្គលិកផ្នែកបរិស្ថាន ចំណែកក្រុង ស្រុកផ្សេងទៀតមានការិយាល័យបរិស្ថាន ហើយមានបុគ្គលិកតែពី១-៤នាក់ប៉ុណ្ណោះ។ ក្រុង ស្រុក៥ក្នុងចំណោមក្រុង ស្រុកដែលមានបុគ្គលិកបរិស្ថាននេះ បានលើកឡើងថា បុគ្គលិករបស់ខ្លួនពុំមានសមត្ថភាពគ្រប់គ្រាន់ ឯក្រុង ស្រុកខ្លះ

ទៀត បានបញ្ជាក់ថាខ្លួនខ្វះខាតសម្ភារៈការិយាល័យ និងសម្ភារៈសម្រាប់ការងារផ្សេងៗមកបំពាក់ក្នុងការិយាល័យបរិស្ថានខ្លួន។

ការិយាល័យបរិស្ថានដែលបានរៀបរាប់ខាងលើ បានឱ្យដឹងថាខ្លួនគឺជាសេនាធិការឱ្យរដ្ឋបាលក្រុង ស្រុក និងមន្ទីររបស់ខ្លួន ដើម្បីពិនិត្យតាមដានការងារប្រមូលសំរាម សំណល់រឹងដោយក្រុមហ៊ុនឯកជន ព្រមទាំងលើកកម្ពស់ការអប់រំប្រជាពលរដ្ឋ ដាក់ស្លាកសញ្ញាគ្រប់គ្រងបរិស្ថាន និងរៀបចំរបាយការណ៍ពាក់ព័ន្ធនានាជូនរដ្ឋបាលខេត្ត និងមន្ទីរបរិស្ថានខេត្ត។

### <u>២.២.៣. តួនាទី និងការទទួលខុសត្រូវរបស់ក្រុមហ៊ុនឯកជន</u>

ដូចបានពន្យល់ខាងដើមក្នុងចំណុច *១.១.ចំណុចខ្វះខាតនៃការអង្កេតនេះ* យើងពុំបានរាប់បញ្ចូលក្រុមហ៊ុនភាស៊ីផ្សារ និងក្រុមហ៊ុនប្រមូលសំរាម មកក្នុងការពិភាក្សានៃរបាយការណ៍អង្កេតនេះទេ។ ទោះជាយ៉ាងណាក្ដី ដោយសារតែសារសំខាន់នៃតួនាទីរបស់អង្គភាពទាំងនេះ ជាការចាំបាច់ដែលយើងត្រូវលើកឡើងដោយសង្ខេបដែលពាក់ព័ន្ធនឹងក្រុមហ៊ុនឯកជន និងក្រុមហ៊ុនភាស៊ីផ្សារដោយផ្អែកលើទិន្នន័យពីរដ្ឋបាលក្រុង ស្រុក។

ការចូលរួមពីសំណាក់វិស័យឯកជនលើកិច្ចការគ្រប់គ្រងសំរាម សំណល់រឹងតាមទីប្រជុំជន បានក្លាយជាប្រធានបទគួរឱ្យកត់សម្គាល់តាំងពីឆ្នាំ២០០៣មក ពេលគឺក្រោយពីមានប្រកាសអន្តរក្រសួងលេខ៨០ រវាងក្រសួងមហាផ្ទៃ និងក្រសួងបរិស្ថានស្ដីពីការធ្វើប្រតិភូកម្មមុខងារការគ្រប់គ្រងសំរាមទៅឱ្យរដ្ឋបាលខេត្ត ក្រុង (ដែលបច្ចុប្បន្នប្ដូរជារដ្ឋបាលរាជធានី និងខេត្តកែប ប៉ៃលិននិងខេត្តព្រះសីហនុ)។ លើកលែងតែរាជធានីភ្នំពេញដែលកិច្ចការប្រមូលសំរាម ត្រូវបានផ្ដល់កិច្ចសន្យាឱ្យទៅក្រុមហ៊ុនស៊ីនទ្រីក្នុងរយៈពេល៥០ឆ្នាំ ជាកិច្ចសន្យាដែលអនុម័តដោយទីស្ដីការគណៈរដ្ឋមន្ត្រីនាទសវត្សរ៍ឆ្នាំ១៩៩០ ហើយមានប្រភេទកិច្ចសន្យាស្រដៀងគ្នានេះដែលធ្វើឡើងនៅតាមទីក្រុង និងទីប្រជុំជនសំខាន់ៗជាច្រើនទៀត ដែលភាគច្រើនគឺត្រូវបានរៀបចំឡើង នៅចុងទសវត្សរ៍ឆ្នាំ២០០០។

សម្រាប់ទីក្រុងធំៗដូចជា ក្រុងសៀមរាប កំពង់ចាម និងព្រះសីហនុ ក្រុមហ៊ុនប្រមូលសំរាម(ក្រុមហ៊ុនស៊ីនទ្រី និងហ្គាអៀ) បានចុះកិច្ចសន្យាដោយផ្ទាល់ជាមួយនឹងអភិបាលខេត្ត។ បែបបទនៃការចុះកិច្ចសន្យានេះទៀតសោត ត្រូវបានគេដឹងថាធ្វើឡើងដោយពុំមានការប្រកាសដេញថ្លៃជាសាធារណៈទេ។ ផ្ទុយទៅវិញ ជាបែបបទដែលទទួលឥទ្ធិពលខ្លាំងពីថ្នាក់លើ ពិសេសពីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ដែលបានអះអាងថា ខ្លួនអនុវត្តការងារ គឺអាស្រ័យលើសំណើពីអភិបាលខេត្តតែប៉ុណ្ណោះ។ ក្នុងស្ថានភាពជាក់ស្ដែង រដ្ឋបាលក្រោមជាតិ យល់ថាមន្ទីរសេដ្ឋកិច្ច និងហិរញ្ញវត្ថុខេត្ត(នាយកដ្ឋានទ្រព្យសម្បត្តិរដ្ឋ) គឺជាអ្នកសម្រេចចុងក្រោយលើការឯកភាពរាល់កិច្ចសន្យានានា ព្រោះថានាយកដ្ឋាននេះ ធ្វើការពិនិត្យ និងកែប្រែខ្លឹមសារកិច្ចសន្យាគ្រប់គ្រងសំរាមសំណល់រឹងមុនពេលចុះហត្ថលេខា (រវាងអភិបាលខេត្ត និងតំណាងក្រុមហ៊ុន)។

សម្រាប់ទីប្រជុំជនដែលមិនសូវមានភាពអ៊ូអរ ទាំងទីប្រជុំជនក្រុង និងទីរួមស្រុក ការគ្រប់គ្រងសំរាមសំណល់រឹង ត្រូវបានផ្ទេរឱ្យទៅក្រុមហ៊ុនភាស៊ីផ្សារ ដោយមានកិច្ចសន្យាជាមួយនឹងអាជ្ញាធរខេត្ត។ តាមរបាយការណ៍ មន្ទីរសេដ្ឋកិច្ច និងហិរញ្ញវត្ថុខេត្ត ក៏ជាប់ពាក់ព័ន្ធនឹងការចុះហត្ថលេខានេះ ហើយថែមទាំងមានឥទ្ធិពលខ្លាំងផងដែរលើការកំណត់ជ្រើសរើសក្រុមហ៊ុនភាស៊ីផ្សារណាមួយ។

ក្នុងន័យនេះ ក្រុមហ៊ុនភាស៊ី ឬក្រុមហ៊ុនប្រមូលសំរាមឯកជនទាំងនោះ ត្រូវបានផ្ដល់ភារកិច្ចក្នុងការប្រមូលសំរាម សំណល់រឹង ពីកន្លែងស្តុកសំរាមជាក់លាក់ណាមួយ ដោយត្រូវដឹកជញ្ជូនសំរាម និងចោលសំរាម

ទៅក្នុងទីលានចាក់សំរាមដូចដែលបានកំណត់ដោយអាជ្ញាធរខេត្ត។ តួនាទីសំខាន់មួយទៀតរបស់ក្រុមហ៊ុនទាំងនេះគឺ ការប្រមូលកម្រៃសេវាសំរាម ដោយផ្អែកលើគោលការណ៍កំណត់តម្លៃដូចមាននៅក្នុងសៀវភៅបន្ទុក ដែលចេញផ្សាយដោយមន្ទីរសេដ្ឋកិច្ច និងហិរញ្ញវត្ថុខេត្ត។ ក្រុមហ៊ុនប្រមូលសំរាម សំណល់រឹងទាំងនោះ មិនទទួលខុសត្រូវលើការសម្អាត និងប្រមូលសំរាមពីទីធ្លាសាធារណៈ ឬសំរាមតាមដងផ្លូវ, មិនអនុវត្តសកម្មភាពបច្ចេកទេសបរិស្ថាន និងអនាម័យនៅទីលានសំរាម ឬមិនធ្វើយុទ្ធនាការអប់រំដល់សាធារណៈជនជាដើម។ មានន័យថា ក្រុមហ៊ុនទាំងនោះប្រមូលសំរាមតែពីតំបន់ដែលប្រជាពលរដ្ឋយល់ព្រមបង់កម្រៃសេវាសំរាមតែប៉ុណ្ណោះ។

ភាពខុសគ្នាដ៏ខ្លាំង រវាងក្រុមហ៊ុនប្រមូលសំរាម និងក្រុមហ៊ុនភាស៊ីផ្សារនោះ គឺក្រុមហ៊ុនប្រមូលភាស៊ីគិតថាភារកិច្ចប្រមូលសំរាមរបស់ពួកគេធ្វើនៅតាមទីកន្លែងតូចៗគឺតែពីផ្សារ និងបរិវេណជុំវិញផ្សារប៉ុណ្ណោះ។ ផ្អែកលើការយល់ព្រមបង់កម្រៃរបស់ប្រជាពលរដ្ឋ និងការចង់បានចំណូលផងដែរនោះ ក្រុមហ៊ុនភាស៊ីផ្សារ បានពង្រីកវិសាលភាពទីតាំងប្រមូលសំរាមរបស់ខ្លួនបន្ថែម។ ប្រភេទអ្នកផ្តល់សេវាសំរាម ជាទូទៅប្រើប្រាស់សម្ភារៈខ្នាតតូច និងមានកម្លាំងកម្មករតិចតួចក្នុងការប្រមូលសំរាម សំណល់រឹង។

ក្រុមហ៊ុនប្រមូលសំរាម មានឧបករណ៍ល្អប្រសើរជាង ហើយជាទូទៅច្រើនតែចុះកិច្ចសន្យាជាមួយអាជ្ញាធរក្នុងរយៈពេលយូរជាង បើធៀបនឹងក្រុមប្រមូលភាស៊ីផ្សារ។ អ្វីដែលគួរឱ្យកត់សម្គាល់ជាងនេះទៅទៀតនោះ គឺថាមានក្រុមប្រមូលភាស៊ីផ្សារមួយចំនួន បានចុះកិច្ចសន្យាប្រមូលសំរាមជាមួយអាជ្ញាធរក្នុងរយៈពេលវែង (ដូចជាស្រុកប្រាសាទសំបូរ ក្រុងក្រចេះរយៈពេល "១៦ឆ្នាំ" និងស្រុកឈូក ក្រុងកំពតរយៈពេល"២២ឆ្នាំ")។

## ២.២.៤. សង្ខេបអំពីតួនាទី និងការទទួលខុសត្រូវរបស់តួអង្គសំខាន់ៗមួយចំនួន

តារាងទី២៖ តួនាទី និងការទទួលខុសត្រូវ នៃតួអង្គទាំងឡាយ ទៅតាមមុខងាររងនៃការគ្រប់គ្រងសំរាម សំណល់រឹង

| ប្រភេទមុខងាររង | ក្រុមប្រឹក្សា | គណៈអភិបាល | មន្ទីរបរិស្ថាន | មន្ទីរសេដ្ឋកិច្ច | ឯកជន | ផ្សេងៗ |
|---|---|---|---|---|---|---|
| រៀបចំផែនការ | | | | X | XXX | |
| កំណត់ទីលានចាក់សំរាម | | X | X | | | |
| រៀបចំថវិកា | | | | XX | XXX | |
| ចុះកិច្ចសន្យា | | X (7) | | XX | XXX | |
| ការអនុវត្ត | | X | X | XX | XXX | |
| ការកំណត់តម្លៃអតិបរមា & ការប្រមូលកម្រៃ | | X | | XX | XXX | |
| ការគាំទ្រ & សម្របសម្រួល | | XX | XX | XXX | | |
| ការតាមដាន & ការត្រួតពិនិត្យ | | X | X | XXX | | |
| ការវាយតម្លៃ | | X | X | XXX | | |
| ការអប់រំ និងផ្សព្វផ្សាយ | | XX | XX | | | |

XXX: ពាក់ព័ន្ធខ្លាំង

XX: ពាក់ព័ន្ធមធ្យម

X: ពាក់ព័ន្ធតិចតួច

## ២.៣. បែបបទនៃកិច្ចសហការ

២.៣.១. ប្រភេទកិច្ចសន្យា

រដ្ឋបាលក្រុង ស្រុកភាគច្រើន ត្រូវបានផ្ទេរក្នុងកម្រិតតិចតួចនៅឡើយនូវមុខងារនៃការគ្រប់គ្រងសំរាម សំណល់រឹង ហើយដូចអ្វីដែលបានលើកឡើងខាងលើ មុខងារនេះត្រូវបានផ្ទេរប្រគល់ទៅឱ្យក្រុមហ៊ុនឯកជន ឬក្រុមប្រមូលភាស៊ីផ្សារទទួលខុសត្រូវ។ តាមរយៈការអង្កេតនេះ មានក្រុង ស្រុកចំនួន២៦ក្នុងចំណោមក្រុង ស្រុកទាំង៣៦ ឬចំនួន៧២% បានចុះកិច្ចសន្យាប្រភេទនេះ។ ជាងពាក់កណ្ដាលនៃក្រុង ស្រុកទាំង២៦នេះ បានចុះកិច្ចសន្យាជាមួយក្រុមប្រមូលភាស៊ីផ្សារ ចំណែកក្រុមហ៊ុនស៊ីនទ្រី និងហ្គាអៀ គឺក្រុមហ៊ុនប្រមូល បានចុះកិច្ចសន្យាជាមួយរដ្ឋបាលក្រុង ស្រុកលើសពីមួយ។

ភាគច្រើននៃការចុះកិច្ចសន្យាទាំងនេះ សុទ្ធតែធ្វើឡើងជាមួយនឹងរដ្ឋបាលថ្នាក់ខេត្ត។ ជាកិច្ចសន្យាដែលមានរយៈពេលខុសៗគ្នាចន្លោះពី១-៣០ឆ្នាំ។ ក្នុងចំណោមក្រុង ស្រុកទាំង២៦ ដែលមានកិច្ចសន្យាជាមួយក្រុមហ៊ុនឯកជន និងក្រុមប្រមូលភាស៊ីផ្សារ មានក្រុង ស្រុកចំនួន១០ បានចុះកិច្ចសន្យារយៈពេលពី១៥-៣០ឆ្នាំ ខណៈដែលក្រុង ស្រុកចំនួន១១ផ្សេងទៀតចុះកិច្ចសន្យាតែចំនួន១ឆ្នាំតែប៉ុណ្ណោះ។ គួរកត់សម្គាល់ផងដែរ សម្រាប់ក្រុងកំពង់ចាម កិច្ចសន្យាជាមួយក្រុមហ៊ុនស៊ីនទ្រី ក្នុងការប្រមូលសំរាម សំណល់រឹង គឺធ្វើឡើងជារៀងរាល់ឆ្នាំ។ ភាពខុសគ្នានៃរយៈពេលកិច្ចសន្យាពីក្រុង ស្រុកមួយទៅមួយ ត្រូវបានគេដឹងថា អាស្រ័យទៅលើការចរចារ និងការបញ្ចុះបញ្ចូលរវាងក្រុមហ៊ុនឯកជនជាមួយអភិបាលខេត្ត និងមន្ទីរសេដ្ឋកិច្ច និងហិរញ្ញវត្ថុខេត្ត។ ជាក់ស្ដែង ក្រុមហ៊ុនស៊ីនទ្រីបានធ្វើការបញ្ចុះបញ្ចូលរដ្ឋបាលខេត្តព្រះសីហនុ ឱ្យស្នើទៅមន្ទីរសេដ្ឋកិច្ច និងហិរញ្ញវត្ថុខេត្តឱ្យបន្តកិច្ចសន្យាការងារក្នុងរយៈពេល៣០ឆ្នាំ ក្រោយពីកិច្ចសន្យាបច្ចុប្បន្នបានបញ្ចប់នាចុងឆ្នាំ២០១៥កន្លងទៅនេះ។ ក្នុងករណីភាគច្រើន ការផ្ដល់កិច្ចសន្យាជាមួយក្រុមហ៊ុនប្រមូលសំរាមពុំបានធ្វើឡើងដោយភាពបើកចំហទូលំទូលាយឡើយ ហើយក៏ពុំបានផ្ដល់លទ្ធភាពដល់សាធារណៈជនក្នុងការពិនិត្យដឹងឮផងដែរ។

**២.៣.២. កិច្ចសហការជាមួយរដ្ឋបាលខេត្ត**

ចាប់តាំងពីការប្រគល់មុខងារគ្រប់គ្រងសំរាម សំណល់រឹងឱ្យទៅរដ្ឋបាលខេត្ត (យោងតាមប្រកាសអន្តរក្រសួងលេខ៨០ឆ្នាំ២០០៣) រដ្ឋបាលក្រុង ស្រុក ដែលជាអង្គភាពចំណុះឱ្យរដ្ឋបាលខេត្ត តែងតែទទួលបានការណែនាំពីរដ្ឋបាលខេត្ត ឱ្យអនុវត្តកិច្ចការមួយចំនួន។ ក្នុងពេលបច្ចុប្បន្ននេះ រដ្ឋបាលក្រុង ស្រុក គឺជាសមាជិកគណៈកម្មាធិការខេត្តទទួលបន្ទុកសោភ័ណភាពទីប្រជុំជន និងទីផ្សារ អនាម័យ សណ្ដាប់ធ្នាប់សាធារណៈ និងបរិស្ថានផងដែរ។ រដ្ឋបាលក្រុង ស្រុក ទទួលការណែនាំ លើកសំណើ និងបញ្ហានានាទៅរដ្ឋបាលខេត្ត និងទៅគណៈកម្មាធិការខេត្ត។ រដ្ឋបាលក្រុង ស្រុក តែងតែអនុវត្តរាល់សេចក្ដីណែនាំនានា និងថែមទាំងរាយការណ៍មករដ្ឋបាលខេត្ត និងទៅថ្នាក់ជាតិ។ ក្នុងករណីខ្លះ រដ្ឋបាលក្រុង ស្រុក បានបញ្ចុះបញ្ចូលតំណាងរដ្ឋបាលខេត្តរបស់ខ្លួនឱ្យបង្កើតយន្តការការងារថ្នាក់ក្រុង ស្រុក (ដូចជាបង្កើតការិយាល័យគ្រប់គ្រងសំរាម សំណល់រឹង ក្នុងក្រុងស្ទឹងត្រែង និងសហគមន៍ស្ម័គ្រចិត្តប្រមូលសំរាម សំណល់រឹងក្នុងខេត្តកំពតជាដើម) ព្រមទាំងរៀបចំលិខិតបទដ្ឋានគតិយុត្តនានាសម្រាប់អនុវត្តនៅថ្នាក់ក្រុង ស្រុករបស់ខ្លួនផងដែរ។

### ២.៣.៣. កិច្ចសហការជាមួយរដ្ឋបាលថ្នាក់ក្រោមជាតិផ្សេងទៀត

ភាគច្រើននៃក្រុង ស្រុកទាំង៣៦ ដែលបានចូលរួមអង្កេត(មាន១៩ក្រុង ស្រុក ឬ៥៣%) បានផ្តល់ព័ត៌មានថាក្រុង ស្រុករបស់ខ្លួនពុំមានទំនាក់ទំនងឬកិច្ចសហការអ្វីជាមួយនឹងក្រុង ស្រុកដែលនៅជិតគ្នាឡើយ។ មានក្រុងស្រុកចំនួន១០(២៨%) បានបញ្ជាក់ថាកំពុងប្រើប្រាស់ទីលានចាក់សំរាមរួមគ្នាជាមួយនឹងក្រុង ស្រុកជិតខាង។ មានក្រុងស្រុកចំនួន១ក្នុងចំណោម៣៦ បានចូលរួមដោះស្រាយជាមួយនឹងភូមិក្បែរខាងលើបញ្ហាពាក់ព័ន្ធនឹងការបោះចោលសំរាមនៅតាមប្រឡាយឆ្លងព្រំប្រទល់។ សកម្មភាពដោះស្រាយវិវាទមានដូចជា ការជួបប្រជុំពិភាក្សារកដំណោះស្រាយ និងការផ្សព្វផ្សាយរួមគ្នាអំពីផលប៉ះពាល់បរិស្ថាន បណ្តាលពីការបោះចោលសំរាមពាសវាលពាសកាល។

### ២.៣.៤. កិច្ចសហការជាមួយក្រុមប្រឹក្សាឃុំ សង្កាត់នៅក្នុងដែនសមត្ថកិច្ចរបស់ខ្លួន

រដ្ឋបាលក្រុង ស្រុកទាំងឡាយ បានផ្តល់ព័ត៌មានថា ខ្លួនបាន និងកំពុងសហការយ៉ាងជិតស្និទជាមួយនឹងក្រុមប្រឹក្សាឃុំ សង្កាត់ ក្នុងដែនសមត្ថកិច្ចរបស់ខ្លួន។ សកម្មភាពសំខាន់ៗ រវាងភាគីទាំងពីរនេះ រួមមាន៖

- ផ្តល់ការអប់រំ និងសកម្មភាពផ្សព្វផ្សាយដល់ប្រជាពលរដ្ឋ អំពីផលប៉ះពាល់នៃការចាក់សំរាមពាសវាលពាសកាល ការបំពុលបរិស្ថាន និងកាតព្វកិច្ចបង់កម្រៃប្រមូលសំរាម សំណល់រឹង
- ផ្សព្វផ្សាយលិខិតបទដ្ឋានគតិយុត្ត ឬឯកសារច្បាប់នានា
- ដាក់ស្លាកសញ្ញាអប់រំ និងហាមចាក់ និងចោលសំរាមតាមទីសាធារណៈ
- ស្វែងរក និងសហការក្នុងការគ្រប់គ្រងទីលានចាក់សំរាមនិងរៀបចំកន្លែងដាក់សំរាមបណ្តោះអាសន្ន
- ណែនាំក្រុមប្រឹក្សាឃុំ សង្កាត់ ឱ្យត្រួតពិនិត្យការងារក្រុមប្រមូលភាស៊ីផ្សារ លើការអនុវត្ត ការគ្រប់គ្រងសំរាម សំណល់រឹង
- រៀបចំឱ្យមានទិវា និងយុទ្ធនាការប្រមូលសំរាម និងសម្អាតបរិស្ថាន។

សម្រាប់ក្រុងមួយចំនួន ដូចជាក្រុងកំពត និងក្រុងស្ទឹងត្រែង គេបានបង្កើតជាក្រុមសហគមន៍ស្ម័គ្រចិត្តប្រមូលសំរាមសរីរាង្គ ដោយត្រូវធ្វើការយ៉ាងសកម្មជាមួយនឹងក្រុមប្រឹក្សាឃុំ សង្កាត់។ សម្រាប់ក្រុងស្ទឹងត្រែង ការិយាល័យគ្រប់គ្រងសំរាម សំណល់រឹងក្រុង ធ្វើការជាមួយក្រុមប្រឹក្សាឃុំ សង្កាត់ ដើម្បីពិនិត្យ និងធ្វើបច្ចុប្បន្នភាពលើសៀវភៅស្នាក់នៅផងដែរ។ ក្រៅពីនេះមានការផាកពិន័យ ចំពោះការចោលសំរាមតាមទីសាធារណៈក្នុងក្រុង ក្រោមកិច្ចសហការជាមួយក្រុមប្រឹក្សាឃុំ សង្កាត់នីមួយៗ។

### ២.៣.៥. កិច្ចសហការជាមួយក្រុមហ៊ុនឯកជនប្រមូលសំរាម សំណល់រឹង

គេបានដឹងថា កិច្ចសហការជាមួយក្រុមហ៊ុនឯកជនផ្តល់សេវាគ្រប់គ្រងសំរាម សំណល់រឹង គឺតែងតែមានបញ្ហាជាច្រើន។ មានក្រុង ស្រុក២៦ក្នុងចំណោម៣៦(៧២%) បានឱ្យដឹងថា ក្រុង ស្រុករបស់ខ្លួន ពុំដែលមានកិច្ចសហការជាមួយនឹងក្រុមហ៊ុនឯកជនទាល់តែសោះ។ មានក្រុង ស្រុកតែចំនួន៣ប៉ុណ្ណោះ ដែលបានរាយការណ៍ថា ខ្លួនតែងតែបានទទួលរបាយការណ៍សកម្មភាពប្រចាំខែពីក្រុមហ៊ុនឯកជន(ក្រុងកំពត ស្រុកឈូក

ខេត្តកំពត និងស្រុកកំពង់ស្វាយខេត្តកំពង់ធំ) រីឯក្រុង ស្រុកចំនួន២៩ផ្សេងទៀត ពុំដែលធ្លាប់បានទទួលរបាយការណ៍ណាមួយទាល់តែសោះពីក្រុមហ៊ុនឯកជនដែលធ្វើការប្រមូលសំរាម សំណល់រឹងក្នុងក្រុង ស្រុករបស់ខ្លួន។ មានក្រុង ស្រុកចំនួនតិចតួចផ្សេងទៀត បានអះអាងថាខ្លួនមានទំនាក់ទំនងការងារជាមួយនឹងក្រុមហ៊ុនឯកជនតាមរយៈការិយាល័យបរិស្ថានក្រុង ស្រុករបស់ខ្លួន។

ក្រុងមួយចំនួន បានពិភាក្សាអំពីការផាកពិន័យ លើការចោលសំរាមតាមទីសាធារណៈ ជាមួយនឹងក្រុមហ៊ុនប្រមូលសំរាម ប៉ុន្តែពុំបានបង្ហាញអំពីការអនុវត្តវិធានការផាកពិន័យទាំងនោះឡើយ។ ក្រុងកំពង់ចាម បានអះអាងថា ខ្លួនបានទទួលរបាយការណ៍មួយពីក្រុមហ៊ុនឯកជនផ្តល់សេវាគ្រប់គ្រងសំរាម និងអ្នកប្រើប្រាស់សេវាសំរាម ដែលជាសេវារបស់ក្រុមហ៊ុនស៊ីនទ្រី ចំណែកក្រុង ស្រុកផ្សេងទៀតដែលបានឆ្លើយសំណួរ បានឯកភាពថា ពួកគាត់ពុំដែលបានទទួលរបាយការណ៍ហិរញ្ញវត្ថុពីបណ្តាក្រុមហ៊ុនឯកជនផ្តល់សេវាគ្រប់គ្រងសំរាម សំណល់រឹងក្នុងមូលដ្ឋានរបស់ខ្លួននោះឡើយ។

### ២.៣.៦. ជំនួយបច្ចេកទេស និងហិរញ្ញវត្ថុដែលក្រុង/ស្រុកទទួលបាន

រដ្ឋបាលក្រុង ស្រុកកន្លងមកពុំសូវបានទទួលការគាំទ្រលើការងារនេះទេ ដោយសារតែបែបបទការងារគ្រប់គ្រងសំរាម សំណល់រឹង នៅមានលក្ខណៈមជ្ឈការ និងវិសហមជ្ឈការ។ រដ្ឋបាលក្រុង ស្រុកចំនួន២៥ បានឆ្លើយថា ខ្លួនពុំដែលទទួលបានទាំងជំនួយបច្ចេកទេស និងហិរញ្ញវត្ថុឡើយ។ មានក្រុង ស្រុកចំនួន៦ផ្សេងទៀត បានអះអាងថា ធ្លាប់បានទទួលជំនួយបច្ចេកទេសមួយចំនួនពីមន្ទីរ ឬការិយាល័យបរិស្ថានខេត្ត។ មានក្រុង ស្រុកចំនួន៥ផ្សេងទៀតបានបញ្ជាក់ថា បានទទួលទាំងជំនួយបច្ចេកទេស និងហិរញ្ញវត្ថុពីដៃគូអភិវឌ្ឍន៍ និងអង្គការក្រៅរដ្ឋាភិបាល។ ចំពោះក្រុងកំពត ស្រុកឈូក(ខេត្តកំពត) ក្រុងស្ទឹងត្រែង(ខេត្តស្ទឹងត្រែង) និងក្រុងស្ទឹងសែន(ខេត្តកំពង់ធំ) បានបញ្ជាក់ថា ពួកគាត់បានទទួលជំនួយហិរញ្ញវត្ថុ និងការពង្រឹងសមត្ថភាពបច្ចេកទេសធ្វើជីកំប៉ុស្តិ៍ ការញែកសំរាម ការដាក់ធុងសំរាម រថយន្តដឹកជញ្ជូនសំរាម(ក្រុងស្ទឹងត្រែង) និងរៀបចំបង្កើតទីលានចាក់សំរាម។ មានក្រុង ស្រុកមួយចំនួនតូចទៀត បាននិយាយថាខ្លួន ក៏ធ្លាប់បានទទួលការពង្រឹងសមត្ថភាពពីមន្ទីរ ឬការិយាល័យបរិស្ថានស្តីពីការធ្វើកំប៉ុស្តិ៍ និងការអប់រំសាធារណៈជនអំពីសំរាម។

## ២.៤. ថវិកា និងការគណនាតម្លៃភាស៊ី ក្នុងការគ្រប់គ្រងសំរាម-សំណល់រឹង

### ២.៤.១. ថវិកា និងប្រភពថវិកាក្នុងការគ្រប់គ្រងសំរាម-សំណល់រឹង

ជារួម គេបានដឹងថា នៅប្រទេសកម្ពុជា ការផ្តល់ថវិកាដល់វិស័យសាធារណៈមានតិចតួចធៀបនឹងតម្រូវការជាក់ស្តែង។ ប៉ុន្តែ សម្រាប់ការអនុវត្តមុខងារគ្រប់គ្រងសំរាម សំណល់រឹង មានស្ថានភាពខុសគ្នា។ ក្រុមហ៊ុនឯកជនផ្តល់សេវាប្រមូលសំរាមជាច្រើនក្រុមហ៊ុនបានធ្វើការចរចារដោយផ្ទាល់ជាមួយស្ថាប័នថ្នាក់ជាតិ និងរដ្ឋបាលថ្នាក់ក្រោមជាតិ ដោយផ្អែកលើការគណនាប្រាក់ចំណេញរបស់ខ្លួនពីសេវាប្រមូលសំរាម។ ក្នុងការគណនាតម្លៃនេះទៀតសោត ការកំណត់ប្រភពប្រមូលសំរាម គឺជាដំណាក់កាលសំខាន់ មុននឹងធ្វើការព្រមព្រៀងកំណត់តម្លៃនានា។

ក្នុងន័យនេះ គ្រប់ក្រុង ស្រុកទាំងអស់ដែលបានចូលរួមអង្កេត បានរាយការណ៍ថា ថវិកាសម្រាប់គ្រប់គ្រងសំរាម សំណល់រឹង បានមកពីប្រាក់កម្រៃអ្នកប្រើសេវា។ មានក្រុង ស្រុកចំនួន១០ក្នុងចំណោមក្រុង ស្រុក

ទាំង៣៦ បានបញ្ជាក់ថា ពួកគាត់បានទទួលថវិកាមួយចំនួនពីថ្នាក់ជាតិ រីឯក្រុង ស្រុកចំនួន១៧ផ្សេងទៀត បានត្អូញត្អែរថា ពួកគាត់ពុំដែលទទួលបានថវិកាពីរដ្ឋាភិបាលលើការអនុវត្តមុខងារគ្រប់គ្រងសំរាម សំណល់រឹង នៅឡើយ។ យ៉ាងណាក្តី ក្រោយពីក្រុមការងារស្រាវជ្រាវ បានសួរបញ្ជាក់ដល់រដ្ឋបាលក្រុង ស្រុកដែលធ្លាប់បាន ទទួលថវិកាពីថ្នាក់ជាតិ ក្រុង ស្រុកទាំងនោះបានគូសបញ្ជាក់ថា ថវិកានោះជាកញ្ចប់ថវិកាសម្រាប់ឆ្នាំ២០១៥ ប៉ុន្តែពួកគាត់ពុំទាន់បានចំណាយនៅឡើយ។ មានន័យថា ថវិកាដែលក្រុង ស្រុកអះអាងថាខ្លួនទទួលបានពីរដ្ឋាភិបាលនោះ គឺគ្រាន់តែជាតួលេខដូចបានចែងក្នុងប្រកាសអន្តរក្រសួងលេខ០៧៣ នាខែកុម្ភៈ ឆ្នាំ២០១៥ ពោល គឺថវិកានេះ ពុំទាន់បានចំណាយនៅឡើយដោយសារហេតុផលមួយចំនួន។

ចំពោះរដ្ឋបាលក្រុងស្រុកមួយចំនួន ដូចជាក្រុងកំពត ការបង្កើតគម្រោងធ្វើកំប៉ុស្តិ៍ចេញពីសំរាមសរីរាង្គ គឺបានផ្តល់ជាប្រភពថវិកាមួយទៀតសម្រាប់អនុវត្តការងារគ្រប់គ្រងសំរាមនេះ។ សម្រាប់ក្រុង ស្រុកផ្សេងទៀត រួមមានក្រុងស្ទឹងត្រែង និងក្រុងកំពត ទាំងដៃគូអភិវឌ្ឍន៍ ទាំងអង្គការក្រៅរដ្ឋាភិបាល បានជួយបំពេញបន្ថែមលើ ជំនួយហិរញ្ញវត្ថុមួយចំនួន។ ជាក់ស្តែង ក្រុងស្ទឹងត្រែង បានទទួលថវិកាចំនួន៣លានរៀល ជារៀងរាល់ឆ្នាំពី រដ្ឋបាលខេត្តរបស់ខ្លួនតាំងពីឆ្នាំ២០១១-២០១២មក។ ថវិកានេះសម្រាប់ចំណាយប្រតិបត្តិការ ការងារគ្រប់គ្រង សំរាមសំណល់រឹង នៅការិយាល័យគ្រប់គ្រងសំរាម សំណល់រឹងក្រុងរបស់ខ្លួន។

ក្រុង ស្រុកចំនួន១៦ បានបញ្ជាក់ថា គាត់ពុំដែលបានទទួលថវិកាសម្រាប់ការងារគ្រប់គ្រងសំរាម សំណល់រឹងឡើយ ដោយប្រគល់មុខងារនេះទៅក្រុមហ៊ុនឯកជន ឬរដ្ឋបាលខេត្តជាអ្នកអនុវត្ត។ ក្នុងការអនុវត្ត សកម្មភាពគ្រប់គ្រងសំរាម -សំណល់រឹង ក្រុង ស្រុកទាំងនោះ តែងតែចូលរួមតែជាមួយរដ្ឋបាលខេត្តតែប៉ុណ្ណោះ ពេលដែលមានការស្នើសុំពីរដ្ឋបាលខេត្តឱ្យចូលរួម។

### ២.៤.២. ការគណនាតារាងតម្លៃសម្រាប់ការគ្រប់គ្រងសំរាម សំណល់រឹង

ភាគច្រើននៃក្រុង ស្រុកទាំង៣៦ដែលបានចូលរួមការអង្កេត បានរាយការណ៍ថា ពួកគាត់ពុំដែលបាន ចូលរួមក្នុងការកំណត់ថ្លៃសេវាប្រមូលសំរាម សំណល់រឹងឡើយ ដោយបានបញ្ជាក់ថា នេះជាការងាររបស់មន្ទីរ សេដ្ឋកិច្ច និងហិរញ្ញវត្ថុខេត្ត និងក្រុមហ៊ុនទទួលសិទ្ធិប្រមូលសំរាម សំណល់រឹងតែប៉ុណ្ណោះ។ មានក្រុង ស្រុកមួយ ចំនួនតូច បានសង្កេតឃើញថា មានការចរចាររវាងពលរដ្ឋជាមួយក្រុមហ៊ុនគ្រប់គ្រងសំរាម។ ក្រុងក្រចេះ បាន បញ្ជាក់ថាក្រុមប្រឹក្សាសង្កាត់ បានធ្វើការពិភាក្សាកំណត់កម្រៃអតិបរមាជាមួយពលរដ្ឋ មុននឹងបង្កើតគម្រោង សំណើតារាងតម្លៃទៅឱ្យមន្ទីរសេដ្ឋកិច្ច និងហិរញ្ញវត្ថុខេត្ត ក្នុងការពិនិត្យសម្រេចចុងក្រោយ លើការកំណត់ប្រាក់ កម្រៃអតិបរមានេះ។ ក្រុងស្ទឹងត្រែង ក៏បានរាយការណ៍ថា ក្រុមប្រឹក្សាក្រុងរបស់ខ្លួនបានពិគ្រោះយោបល់ ជាមួយនឹងប្រជាពលរដ្ឋមុននឹងសម្រេចកំណត់កម្រៃអតិបរមាលើការងារគ្រប់គ្រងសំរាម សំណល់រឹង ហើយ បន្ទាប់មកទើបអភិបាលក្រុងចុះហត្ថលេខា និងបានឯកភាពយល់ព្រមដោយអភិបាលខេត្តក្នុងឆ្នាំ២០១០។

ក្រុងស្ទឹងត្រែង បានអះអាងថា គាត់បានគណនាប្រាក់កម្រៃគ្រប់គ្រងសំរាម ដោយផ្អែកលើបរិមាណ សំរាមដែលបានផលិត។ យ៉ាងណាក៏ដោយ យោងតាមការប្រមូលសំរាមក្នុងក្រុងនេះ ពុំមាន"រូបមន្តជាក់លាក់" ណាមួយក្នុងការកំណត់កម្រៃសេវាគ្រប់គ្រងសំរាមឡើយ។ ជាក់ស្តែង របៀបនៃការបង់ថ្លៃសេវាសំរាមបច្ចុប្បន្ន គឺ ត្រូវបង់ចន្លោះពី០,៨ទៅ៣០ដុល្លារអាមេរិកក្នុងមួយខែសម្រាប់ក្រុងស្ទឹងត្រែង។ ចំពោះការគណនាតារាងតម្លៃ សេវាសំរាមនៅក្រុង ស្រុកដ៏ទៃទៀត គឺធ្វើឡើងដោយផ្អែកទៅលើប្រភេទអាជីវកម្ម និងលំនៅដ្ឋានតែប៉ុណ្ណោះ។ ក្នុងករណីណាមួយដ៏ដោយ កម្រៃពីសេវាប្រមូលសំរាម សំណល់រឹង ត្រូវបានគេដឹងថា មានការកំណត់ខ្ពស់ជាង

កម្រៃដែលបានដាក់ក្នុង"សៀវភៅបន្ទុក"។ សម្រាប់ក្រុងទីប្រជុំជនភាគច្រើន កម្រៃនៃការប្រមូលសំរាមពីសណ្ឋាគារលំដាប់ផ្កាយ៤-៥ អាចថ្លៃលើសពីចំនួនដែលបានកំណត់ក្នុង"សៀវភៅ"បន្ទុក រហូតដល់ទៅ២០ដងឯណោះ។

## ២.៤.៣. ការប្រមូលកម្រៃពីសេវាសំរាម សំណល់រឹង

ដោយសារ ប្រាក់កម្រៃបានពីការប្រមូលសំរាម គឺជាប្រភពថវិកាចម្បងក្នុងការអនុវត្តមុខងារប្រមូលសំរាម សំណល់រឹង វិធីសាស្ត្រនៃការប្រមូលកម្រៃ និងកម្រិតនៃការចំណាយលើសេវាប្រមូលសំរាម គឺមានសារសំខាន់ណាស់។ ដូចអ្វីដែលរដ្ឋបាលក្រុង ស្រុកបានលើកឡើង ក្រុមហ៊ុនប្រមូលសំរាមជាទូទៅតែងតែបន្ទោសប្រជាពលរដ្ឋ ដែលពុំបានបង់ថ្លៃសេវាសំរាម ហើយតែងតែលើកឡើងថានេះជាមូលហេតុសំខាន់ដែលធ្វើឱ្យក្រុមហ៊ុនខ្លួនពុំបានអនុវត្តការងារប្រមូលសំរាម-សំណល់រឹងបានល្អ។

ដើម្បីជំរុញឱ្យពលរដ្ឋបំពេញកាតព្វកិច្ចបង់ថ្លៃសេវាសំរាម កម្រៃប្រមូលសំរាមត្រូវបានគេដាក់បញ្ចូលទៅក្នុងវិក័យបត្រអគ្គិសនី។ គោលបំណងនៃការធ្វើបែបនេះ គឺដើម្បីកាត់ផ្តាច់ចរន្តអគ្គិសនីនៅពេលដែលប្រជាពលរដ្ឋណាពុំបានបង់ថ្លៃសេវាសំរាម។ យ៉ាងណាក៏ដោយ យន្តការនៃការប្រមូលកម្រៃសំរាមរបៀបនេះ ត្រូវគេយល់ថា មិនគួរប្រើក្នុងរយៈពេលយូរឡើយ។ រដ្ឋបាលខេត្ត និងរាជធានី បានឈប់ប្រើយន្តការប្រមូលកម្រៃតាមរបៀបនេះហើយ ដោយសារតែមានការត្អូញត្អែរពីសំណាក់ប្រជាពលរដ្ឋ ថាក្រុមហ៊ុនប្រមូលសំរាម ពុំបានអនុវត្តការងារខ្លួនឱ្យបានល្អឡើយ។ បច្ចុប្បន្ននេះ ស្ទើរតែគ្រប់ក្រុង ស្រុកដែលបានផ្តល់ចម្លើយ បានគូសបញ្ជាក់ថាក្រុមហ៊ុនដែលមានកិច្ចសន្យាប្រមូលសំរាម បានសម្រេចជួលបុគ្គលិកបន្ថែម ដើម្បីប្រមូលកម្រៃសេវាប្រមូលសំរាម។ ក្នុងក្រុងស្ទឹងសែននៃខេត្តកំពង់ធំ គេបានផ្តល់ព័ត៌មានមកថា អាជ្ញាធរភូមិ ក៏បានចូលរួមក្នុងការប្រមូលកម្រៃសេវាសំរាមនេះដែរ ក្នុងគោលបំណងដើម្បីធ្វើឱ្យអ្នកប្រើប្រាស់សេវាប្រមូលសំរាមអាចអនុវត្តតាមនូវកាតព្វកិច្ចបង់កម្រៃសេវាប្រមូលសំរាម។

## ២.៤.៤. ផែនការពង្រីកសេវាគ្រប់គ្រងសំរាម សំណល់រឹង

ដោយសារកំណើននៃការរីកចម្រើនយ៉ាងឆាប់រហ័សតាមទីក្រុង និងទីប្រជុំជន បានបណ្តាលឱ្យមានផលប៉ះពាល់ដល់សុខភាពដោយបញ្ហាអនាម័យកខ្វក់នៅតាមទីប្រជុំជនទាំងនោះ ការប្រមូលសំរាម បានក្លាយជាប្រធានបទ"ដ៏ក្តៅគគុក"មួយសម្រាប់រដ្ឋបាលក្រុង ស្រុកភាគច្រើន។ ដូចបានបង្ហាញនៅខាងដើមនៃជំពូកនេះ បញ្ហាគ្រប់គ្រងសំរាម សំណល់រឹង បានក្លាយជាប្រធានបទដែលតែងតែលើកមកពិភាក្សាជាញឹកញាប់ក្នុងរបៀបវារៈនៃកិច្ចប្រជុំរបស់ក្រុមប្រឹក្សាក្រុង ស្រុកចាប់តាំងពីការបង្កើតក្រុមប្រឹក្សាក្រុង ស្រុកនៅឆ្នាំ២០០៩មក។ ក្នុងស្ថានភាពដែលការគ្រប់គ្រងសំរាម សំណល់រឹង មិនមានប្រសិទ្ធភាព និងពុំទាន់មានមុខងារច្បាស់លាស់ផងនោះ ក្រុមប្រឹក្សាក្រុង ស្រុក តែងតែជំរុញដល់គណៈអភិបាលរបស់ខ្លួន ឱ្យធ្វើការជាមួយនឹងការិយាល័យជំនាញ ព្រមទាំងជាមួយក្រុមប្រឹក្សាឃុំ សង្កាត់ លើសកម្មភាពអប់រំសាធារណៈ លើកកម្ពស់ការយល់ដឹងដល់ប្រជាពលរដ្ឋ និងតាមដានការងាររបស់ក្រុមហ៊ុនឯកជនប្រមូលសំរាម សំណល់រឹង។

ផែនការពង្រីកតំបន់ប្រមូលសំរាម ក៏ត្រូវបានរដ្ឋបាលក្រុង ស្រុកភាគច្រើន លើកយកមកពិភាក្សាផងដែរ។ យ៉ាងណាក៏ដោយ ការអង្កេតនេះមិនអាចស្វែងរកភស្តុតាងអំពីការអនុវត្តផែនការពង្រីកតំបន់ប្រមូលសំរាមនេះនៅឡើយ។ ជាងនេះទៅទៀត មានក្រុង ស្រុកចំនួន៧ ដែលបានឆ្លើយសំណួរ បានបញ្ជាក់ថា ក្រុង ស្រុករបស់

ខ្លួន បានទុកបញ្ហាផែនការពង្រីកតំបន់ប្រមូលសំរាមឱ្យទៅក្រុមហ៊ុនឯកជន ដែលតែងតែអះអាងថា ក្រុមហ៊ុនខ្លួន បានត្រៀមរួចជាស្រេច សម្រាប់រាល់ផែនការពង្រីកតំបន់ណាមួយបើសិនជាមានតម្រូវការ និងយល់ព្រមបង់ថ្លៃសេវាប្រមូលសំរាម។

## ២.៥. ករណីសិក្សា

### ២.៥.១. ករណីសិក្សា ១៖ ការគ្រប់គ្រងសំរាម សំណល់រឹង នៅក្រុងព្រះសីហនុ

| *ស្ថិតិក្រុង (ទិន្នន័យស្ថិតិឆ្នាំ២០១៤)* | |
|---|---|
| ចំនួនសង្កាត់៖ | 05 |
| ចំនួនប្រជាជន៖ | ជាង 80,000 |
| # លំនៅដ្ឋាន៖ | ជាង 17,000 |
| # ភោជនីយដ្ឋាន សណ្ឋាគារ និងកន្លែងកំសាន្តផ្សេងទៀត៖ | ជាង 1,600 |
| # ភ្ញៀវទេសចរណ៍ជាតិ ឆ្នាំ ២០១៤៖ | 1.3 លាននាក់ |
| # ភ្ញៀវទេសចរណ៍ អន្តរជាតិ (២០១៤) ៖ | ប្រមាណជា 390,000 នាក់ |
| *លក្ខណៈពិសេសនៃការគ្រប់គ្រងសំរាម សំណល់រឹង* | |
| បរិមាណសំរាម (ថ្ងៃធម្មតា)៖ | 110-120 តោន |
| បរិមាណសំរាម (ថ្ងៃពិសេស)៖ | 120-140 តោន |
| ក្រុមហ៊ុនប្រមូលសំរាម៖ | ក្រុមហ៊ុនឯកជន ឈ្មោះ CINTRI |
| រយៈពេលកិច្ចសន្យា៖ | 15 ឆ្នាំ |
| កាលផុតកំណត់កិច្ចសន្យា៖ | 31 ធ្នូ 2015 |
| អ្នកគ្រប់គ្រងកិច្ចសន្យា៖ | រដ្ឋបាលខេត្ត (PA) |
| # ចំនួនមន្ត្រីមន្ទីរបរិស្ថាន (DoEnv) ៖ : | 22 |
| # ចំនួនមន្ត្រីការិយាល័យបរិស្ថានក្រុង (Municipality Office Env) ៖ | 0 |
| ចំនួនតំបន់ដែលអាចផ្តល់សេវាប្រមូលសំរាម៖ | 04 សង្កាត់ |
| ទីលានចាក់សំរាម៖ | 62 ហិតា |
| ចម្ងាយទីកាន់ទីលានចាក់សំរាម៖ | 23 គីឡូម៉ែត្រ |

**បញ្ហានានា ដែលមានជាមួយក្រុមហ៊ុនប្រមូលសំរាម ( សង្ខេបតាមរដ្ឋបាលខេត្ត រដ្ឋបាលក្រុង )**

អភិបាលខេត្ត បានចុះហត្ថលេខរយៈពេល១៥ឆ្នាំជាមួយក្រុមហ៊ុនឯកជនមួយផ្សេងទៀត( មិនមែនក្រុមហ៊ុនស៊ីនទ្រី )ដែលក្រោយមក ក្រុមហ៊ុននោះបានផ្ទេរការងារប្រមូលសំរាមនេះ ឱ្យទៅក្រុមហ៊ុនស៊ីនទ្រីវិញក្នុងឆ្នាំ២០០៥។ ដោយសារមានការផ្លាស់ប្តូរអភិបាលខេត្ត ក្រុមហ៊ុនស៊ីនទ្រី បានប្រតិបត្តិការការងារប្រមូលសំរាមនេះរយៈកាល១០ឆ្នាំមកហើយ ដោយមានទំនាក់ទំនងតិចតួចបំផុតជាមួយនឹងអាជ្ញាធរខេត្ត និងស្ទើរតែគ្មានទំនាក់ទំនងទាល់តែសោះជាមួយនឹងរដ្ឋបាលក្រុង។ បញ្ហាសំខាន់ៗដែលបានជួបប្រទះរួមមាន៖

- សេវាប្រមូលសំរាម សំណល់រឹង មិនបានគ្របដណ្តប់គ្រប់សង្កាត់ និងគ្រប់ដងផ្លូវសារធារណៈក្នុងក្រុងឡើយ
- ពុំបានប្រមូលគ្រប់ប្រភេទសំរាម សំណល់រឹងទាំងអស់ ហើយប្រមូលក៏ពុំបានស្អាត

- ប្រមូលសំរាម សំណល់រឹងនៅពេលថ្ងៃ(មិនប្រមូលពេលយប់) ពុំមានកំណត់ពេលវេលាប្រមូល និង ប្រមូលសំរាមយឺតយ៉ាវ(ចាប់ពី១ថ្ងៃដល់១សប្តាហ៍ក៏មាន)
- មធ្យោបាយដឹកជញ្ជូនសំរាម ពុំមានសភាពល្អ(រថយន្តដឹកសំរាមទាំង១៣ ជាទូទៅតែងតែខូច ហើយ ធ្លាយលិចកាកសំណល់ សំរាម ចេញតាមដងផ្លូវ)
- ពុំមានកិច្ចសហការជាមួយអាជ្ញាធរមូលដ្ឋាន។ ការគ្រប់គ្រងការងារធ្វើពីការិយាល័យនៅភ្នំពេញដោយ ផ្ទាល់(ពិសេសការងារគ្រប់គ្រងថវិកា)
- ប្រមូលកម្រៃសេវាគ្រប់គ្រងសំរាមបានតែពីប្រមាណ៣០-៤០%នៃលំនៅដ្ឋានប្រជាពលរដ្ឋដែលប្រើសេវា តែប៉ុណ្ណោះ។ ម្យ៉ាងទៀត ប្រាក់កម្រៃពីសេវាប្រមូលសំរាមតាមសណ្ឋាគារ ត្រូវបានបង់ថ្លៃលើសពីការ កំណត់ក្នុងសៀវភៅ "បន្ទុក" យ៉ាងច្រើន។ ដូចគណៈអភិបាល និងក្រុមប្រឹក្សាក្រុង បានលើកឡើង មាន សណ្ឋាគារលំដាប់ផ្កាយ៤-៥មួយចំនួន បានបង់ថ្លៃប្រមូលសំរាមរហូតដល់ទៅ៣,០០០ដុល្លារមួយខែ ចំណែកក្នុងសៀវភៅ "បន្ទុក"កំណត់តែនៅពី១០០-១៥០ដុល្លារក្នុងមួយខែ។ បញ្ហានេះ ធ្វើឱ្យក្រុមហ៊ុន មិនបានបំពេញភារកិច្ចឱ្យបានល្អ(សម្រាប់ការប្រមូលសំរាមតាមទីសាធារណៈ) ដោយសារតែក្រុមហ៊ុន ប្រមូលសំរាម ខិតខំប្រមូលសំរាមតែតាមសណ្ឋាគារ និងភោជនីយ៍ដ្ឋានធំៗទាំងនោះតែប៉ុណ្ណោះ។
- បច្ចុប្បន្ននេះ នៅដំណាក់ចុងក្រោយនៃកិច្ចសន្យារយៈពេល១៥ឆ្នាំរបស់ខ្លួន ក្រុមហ៊ុនស៊ីនទ្រី ពុំបាន ប្រគល់រថយន្តដឹកសំរាមចំនួន៥គ្រឿង ធុងសំរាមចំនួន១,០០០ធុង (និងទីតាំងស្តុកសំរាមបណ្តោះ អាសន្ន ទីលានចាក់សំរាម និងញែកសំរាម) ជូនទៅរដ្ឋបាលខេត្ត ឬរដ្ឋបាលក្រុង ដូចអ្វីដែលបានកំណត់ ក្នុងកិច្ចសន្យានោះឡើយ។
- ការផ្តល់សេវាគ្រប់គ្រងសំរាម-សំណល់រឹងរបស់ក្រុមហ៊ុនស៊ីនទ្រី នឹងត្រូវចប់កិច្ចសន្យានៅថ្ងៃ៣១ ខែធ្នូ ឆ្នាំ ២០១៥នេះ។ មកដល់ថ្ងៃទី២០ ខែវិច្ឆិកា ឆ្នាំ២០១៥ (ពេលកំពុងសរសេររបាយការណ៍នេះ) គេពុំទាន់ ឃើញថា នឹងមានក្រុមហ៊ុនណាមកជំនួសក្រុមហ៊ុនស៊ីនទ្រីនៅឡើយ។

### ផែនការ និងការអនុវត្តជាក់ស្តែង

នៅពេលដែលអនុក្រឹត្យលេខ១១៣ចូលជាធរមាន និងស្របពេលដែលបញ្ហាសំរាម ត្រូវបានកំណត់ជា អាទិភាពខ្ពស់ រដ្ឋបាល ក្រុង បានអនុវត្តសកម្មភាពសំខាន់ៗជាច្រើន ចាប់តាំងពីខែកញ្ញា ឆ្នាំ២០១៥មក។ សកម្មភាពដំបូងគឺ បញ្ហាគ្រប់គ្រងសំរាម សំណល់រឹង បានក្លាយជារបៀបវារៈស្ទើរតែគ្រប់កិច្ចប្រជុំនៃក្រុមប្រឹក្សា ក្រុងទាំងអស់។ រដ្ឋបាលក្រុង សហការជាមួយនឹងមន្ទីរបរិស្ថានខេត្ត និងមន្ទីរសេដ្ឋកិច្ច និងហិរញ្ញវត្ថុខេត្ត បាន បើកកិច្ចប្រជុំជាច្រើន ដើម្បីពិភាក្សាអំពីបញ្ហាក្រុមហ៊ុនស៊ីនទ្រី ហើយថែមទាំងបានរៀបចំផែនការ និងកំណត់ ថវិកា(ចំនួន២២៥លានរៀល ឬ៥៦,០០០ដុល្លារអាមេរិក) សម្រាប់វិភាជន៍ដល់រដ្ឋបាលក្រុង ស្របតាម ប្រកាសអន្តរក្រសួងលេខ០៧៣ (រវាងក្រសួងមហាផ្ទៃ ក្រសួងបរិស្ថាន និងក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ) ចុះ ថ្ងៃទី០៦ ខែកុម្ភៈ ឆ្នាំ២០១៥។

សកម្មភាពទីពីរ ទាំងរដ្ឋបាលក្រុង ទាំងមន្ទីរបរិស្ថាន បានសហការជាមួយសង្កាត់ទាំង៥ ក្នុងការជ្រើស រើសបុគ្គលិកចំនួន៦៥នាក់ពីគ្រួសារទីទ័លក្រមកធ្វើជាអ្នកសម្អាត និងប្រមូលសំរាម តាមទីសាធារណៈ និងតាម ដងផ្លូវនានា យកមកទុកនៅតំបន់ប្រមូលសំរាមរបស់ក្រុមហ៊ុនស៊ីនទ្រី។ សង្កាត់នីមួយៗទាំង៥នោះ បានជ្រើស រើសកម្មករពី០៦-២០នាក់(អាស្រ័យលើតម្រូវការជាក់ស្តែង)។ កម្មករម្នាក់ៗ ទទួលបាលប្រាក់កម្រៃប្រចាំខែ

ចំនួន៤៧០,០០០រៀល(ឬ១១៧ដុល្លារអាមេរិក) សម្រាប់ការងារគ្រប់គ្រងសំរាម ចាប់តាំងពីថ្ងៃ២៥ ខែកញ្ញា ឆ្នាំ២០១៥មក។ ប្រាក់កម្រៃប្រចាំខែរបស់កម្មករទាំងនោះ គឺជាកញ្ចប់ថវិកាជាតិឆ្នាំ២០១៥ ដែលជាកញ្ចប់ថវិកា ២២៥លានរៀលសម្រាប់ក្រុងនីមួយៗ។ កិច្ចសន្យាចំណាយលើកម្មករទាំងនោះ ត្រូវបានចុះហត្ថលេខាដោយ អភិបាលក្រុង និងប្រធានមន្ទីរបរិស្ថានខេត្ត។ ប្រធានមន្ទីរសេដ្ឋកិច្ច និងហិរញ្ញវត្ថុខេត្ត ព្រមទាំងប្រធានរតនាគារ ខេត្ត គឺជាសាក្សីយល់ព្រមលើការចុះហត្ថលេខាការងារនេះ។ ដំណើរការការងារនេះទាំងមូល ត្រូវបានតាមដាន និងឯកភាពដោយក្រុមប្រឹក្សាក្រុង។

សកម្មភាពទីបី រដ្ឋបាលក្រុង បានធ្វើការកៀគរធនធាននានាពីសប្បុរសជនទាំងឡាយ មកទិញសម្ភារៈ និងឧបករណ៍សម្អាតចំនួន១៣គ្រឿង(ដូចជាម៉ាស៊ីនកាត់ស្មៅ រទេះប្រមូលសំរាម និងឯកសណ្ឋានកម្មករជា ដើម) សម្រាប់ផ្តល់ដល់កម្មករទាំងនោះ ក្នុងការបំពេញការងារប្រមូលសំរាម សំណល់រឹងន។

សកម្មភាពទី៤ ដោយមានកិច្ចសហការជាមួយរដ្ឋបាលក្រុង សង្កាត់នីមួយៗ តែងតែរៀបចំយុទ្ធនាការ សម្អាតទីក្រុងជារៀងរាល់សប្តាហ៍។ យុទ្ធនាការនេះ តែងតែទទួលបានការចូលរួមពីសំណាក់មន្ត្រីប្រមាណជា ៤០-៦០នាក់ រួមមានយុវជន បុគ្គលិកអង្គការក្រៅរដ្ឋាភិបាល និងសមាគមភ្នាក់ងារទេសចរណ៍ផងដែរ។

## ភាពរាំងស្ទះក្នុងការអនុវត្តការងារ

ជាការពិត អាជ្ញាធររដ្ឋបាលគ្រប់ជាន់ថ្នាក់ បានខិតខំដោះស្រាយបញ្ហាគ្រប់គ្រងសំរាម សំណល់រឹងក្នុង ដែនសមត្ថកិច្ចរបស់ខ្លួន។ នៅថ្នាក់ខេត្ត និងក្រុង រដ្ឋបាលក្រុងព្រះសីហនុ មន្ទីរបរិស្ថាន មន្ទីរសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ និងរតនាគារខេត្ត ដោយមានកិច្ចសហការយ៉ាងជិតស្និតពីអាជ្ញាធរខេត្ត កម្មករប្រមូលសំរាមទាំង៦៥ នាក់ ត្រូវបានជ្រើសរើស និងជួលយកមកធ្វើការប្រចាំថ្ងៃក្នុងការគ្រប់គ្រងសំរាមនេះ។ រដ្ឋបាលក្រុង គួរកៀគរ ប្រភពជំនួយបន្ថែមពីសំណាក់សប្បុរសជនទូទៅ សម្រាប់គាំទ្រជាឧបករណ៍ និងសម្ភារៈប្រមូលសំរាមជាដើម។ នៅថ្នាក់ជាតិវិញ ការអនុម័តលើប្រកាសលេខ០៧៣នាខែកុម្ភៈ ឆ្នាំ២០១៥ និងអនុក្រឹត្យលេខ១១៣នាខែសីហា ឆ្នាំ២០១៥កន្លងទៅនេះ គឺសុទ្ធតែជាមានគោលបំណងគាំទ្រលើសកម្មភាពទាំងអស់នេះ។

យ៉ាងណាក៏ដោយ នៅមានបញ្ហាជាច្រើនទៀត។ បញ្ហាដ៏លំបាកបំផុតមួយនោះ គឺរាល់មុខងារ និងថវិកា សម្រាប់ការងារគ្រប់គ្រងសំរាម សំណល់រឹង ដែលបានផ្តល់ទៅឱ្យរដ្ឋបាលក្រុងនោះ នៅពុំទាន់មានគោលការណ៍ ណែនាំ ឬការគាំទ្របច្ចេកទេសជាក់លាក់ឡើយក្នុងការរៀបំធ្វើផែនការសកម្មភាព និងផែនការថវិកា។ ទិដ្ឋភាព ជាវិជ្ជមាននោះ គឺការផ្ទេរមុខងារការគ្រប់គ្រងសំរាម សំណល់រឹង និងការផ្តល់កញ្ចប់ថវិកានេះ បានធ្វើឱ្យរដ្ឋបាល ក្រុងព្រះសីហនុ និងភាគីពាក់ព័ន្ធនានា ខិតខំពុំះពារស្វែងយល់ពីតួនាទី និងការទទួលខុសត្រូវរបស់ខ្លួនហើយផ្តួច ផ្តើមសកម្មភាពការងារបានយ៉ាងលឿន។ កិច្ចខិតខំទាំងនេះ បានទទួលការកោតសរសើរយ៉ាងខ្លាំងពី សំណាក់សាធារណៈជនទូទៅក្នុងខេត្តព្រះសីហនុ ព្រមទាំងពីសំណាក់ក្រសួងបរិស្ថានដែលជាអ្នកទទួលបន្ទុក ការងារនេះ។ យ៉ាងណាក៏ដោយ ក៏មានទិដ្ឋភាពជាឧបសគ្គផងដែរ ដែលការរៀបចំផែនការការងារដោយរដ្ឋបាល ក្រុង តាមរយៈមន្ទីរបរិស្ថានខេត្ត លើការចំណាយសម្រាប់កម្មករទាំង៦៥នាក់នោះ គឺត្រូវបានជាប់គាំង ដោយសារសារាចរណ៍លេខ៨០០ ចុះខែកក្កដា ឆ្នាំ២០១៥របស់អគ្គនាយកដ្ឋានរតនាគារជាតិនៃក្រសួងសេដ្ឋ កិច្ច និងហិរញ្ញវត្ថុ។ ការជាប់គាំង លើបញ្ហាថវិកានេះ គឺផ្អែកលើការហាមឃាត់ថាមិនឱ្យមានការចុះកិច្ចសន្យា រវាងអង្គភាពរដ្ឋជាមួយអង្គភាពរដ្ឋដូចគ្នា។

ភាពរាំងស្ទះមួយនេះ បានធ្វើឱ្យរដ្ឋបាលក្រុង និងបណ្ដាភាគីពាក់ព័ន្ធនានាថ្នាក់ខេត្ត បានឯកភាពជាបណ្ដោះអាសន្ន លើការផ្ទេលកម្មករសម្អាតសំរាម ដោយប្រើថវិការដ្ឋបាលផ្ទាល់ខ្លួន ចាប់តាំងពីថ្ងៃទី២៥ ខែតុលា ឆ្នាំ២០១៥មកម្ល៉េះ។ នេះ ជាករណីកម្រ ដែលរដ្ឋបាលក្រុង និងខេត្តសម្រេចក្នុងការអនុវត្តទោះបីមានមិនច្បាស់លាស់ក្នុងការផ្ដល់ថវិកាក៏ដោយ។ ការជំទាស់របស់រតនាគារជាតិនៃក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុដែលមិនអនុញ្ញាត្តឱ្យមានការទូទាត់សងនូវការចំណាយរួចហើយដោយរដ្ឋបាលក្រុង គឺជាបទពិសោធន៍គួរឱ្យព្រួយបារម្ភជាខ្លាំងសម្រាប់រដ្ឋបាលក្រុង ហើយថែមទាំងបានបង្អាក់ទឹកចិត្តដល់បណ្ដាជួបាលក្រុងទាំង២៥ផ្សេងទៀតមិនហ៊ានអនុវត្តនូវមុខងារដែលបានធ្វើប្រតិភូកម្មនៃការគ្រប់គ្រងសំរាម-សំណល់រឹងតាមទីប្រជុំជនផងដែរ។

## ២.៥.២. ករណីសិក្សា ២៖ ការគ្រប់គ្រងសំរាមក្នុងក្រុងស្ទឹងត្រែង

| | |
|---|---|
| *ស្ថិតក្រុង (ទិន្នន័យស្ថិតិឆ្នាំ២០១៤)* | |
| ចំនួនសង្កាត់៖ | 04 |
| ចំនួនប្រជាជន៖ | ជាង 30,400 |
| # លំនៅដ្ឋាន៖ | ជាង 5,600 |
| # ភោជនីយដ្ឋាន សណ្ឋាគារ និងកន្លែងកំសាន្តផ្សេងទៀត៖ | ជាង 75 |
| # ភ្ញៀវទេសចរណ៍ជាតិ ឆ្នាំ ២០១៤៖ | 114,467 |
| # ភ្ញៀវទេសចរណ៍ អន្តរជាតិ (២០១៤)៖ | 8,745 |
| *លក្ខណៈពិសេសនៃការគ្រប់គ្រងសំរាម សំណល់រឹង* | |
| បរិមាណសំរាម៖ | ប្រមាណជា 30 តោន |
| អ្នកផ្ដល់សេវាប្រមូលសំរាម៖ | ការិ.រដ្ឋគ្រប់គ្រងសំរាម-សំណល់រឹង |
| ផ្ដើមប្រតិបត្តិការគ្រប់គ្រងសំរាម៖ | ខែមករា ឆ្នាំ 2011 |
| ការទទួលស្គាល់ការិយាល័យគ្រប់គ្រងសំរាមដោយក្រសួងមហាផ្ទៃ៖ | ខែសីហា ឆ្នាំ 2013 |
| ខ្សែគណនេយ្យភាពរបស់ការិ.គ្រប់គ្រងសំរាម៖ | រដ្ឋបាលក្រុង និងរដ្ឋបាលខេត្ត (MA & PA) |
| # បុគ្គលិករដ្ឋនៅការិ.គ្រប់គ្រងសំរាម៖ | 2 (1 មកពីរដ្ឋបាលក្រុង 1មកពីមន្ទីបរិស្ថា) |
| # បុគ្គលិកជាប់កិច្ចសន្យារបស់ការិ.គ្រប់គ្រងសំរាម៖ | 13 (06 ស្ត្រី) |
| ចំនួនតំបន់ដែលអាចផ្ដល់សេវាប្រមូលសំរាម៖ | 02 សង្កាត់ (ក្នុងចំណោម 4) |
| ការប្រមូលកម្រៃប្រចាំខែ | ចន្លោះពី 3,500 ដុល្លារទៅ 3,750 ដុល្លារ |
| ទីលានចាក់សំរាម៖ | 147 ហិតា |
| ចម្ងាយទៅកាន់ទីលានចាក់សំរាម៖ | 12 គីឡូម៉ែត្រ |

### ការិយាល័យគ្រប់គ្រងសំរាម សំណល់រឹងក្រុង

ក្រុងស្ទឹងត្រែង គឺក្រុងមួយក្នុងចំណោមក្រុងតិចតួចប៉ុណ្ណោះ ដែលបានធ្វើការគ្រប់គ្រងសំរាម សំណល់រឹងដោយខ្លួនឯងផ្ទាល់ តាមរយៈការបង្កើតការិយាល័យគ្រប់គ្រងសំរាម សំណល់រឹងក្រុងរបស់ខ្លួន ពោលគឺមិនមានក្រុមហ៊ុនប្រមូលសំរាមឯកជន(គ្មានការចុះកិច្ចសន្យាជាមួយក្រុមហ៊ុនប្រមូលសំរាម សំណល់រឹង ឬក្រុមប្រមូលភាស៊ីផ្សារ)ឡើយ។ គួរកត់សម្គាល់ថា មុននឹងមានការបង្កើតជាការិយាល័យគ្រប់គ្រងសំរាម សំណល់រឹងក្រុងដើមឆ្នាំ២០១១ ហើយមានការទទួលស្គាល់ពីក្រសួងមហាផ្ទៃក្នុងឆ្នាំ២០១៣ ការគ្រប់គ្រងសំរាម សំណល់

រឹងក្នុងក្រុងស្ទឹងត្រែង គឺបានធ្វើឡើងដោយចុះកិច្ចសន្យាជាមួយក្រុមហ៊ុនឯកជនប្រមូលសំរាម សំណល់រឹង។ ក្រោមកិច្ចសន្យាប្រមូលសំរាមជាមួយក្រុមហ៊ុនឯកជននាគ្រានោះ ការងារប្រមូលសំរាមក្នុងក្រុង គឺពុំបានអនុវត្តឱ្យបានត្រឹមត្រូវឡើយ ហើយថែមទាំងបានទទួលរងការរិះគន់ជាប្រចាំពីប្រជាពលរដ្ឋ។ រហូតមកដល់ដើមឆ្នាំ២០១០ មានអង្គការក្រៅរដ្ឋាភិបាលរបស់ប្រទេសអេស្ប៉ាញឈ្មោះIPAD បានសហការការងារជាមួយនឹងអង្គការស្ការ៉ូ(SCARO) បានខិតខំសហការគ្នាដោះស្រាយបញ្ហាគ្រប់គ្រងសំរាមក្នុងក្រុងស្ទឹងត្រែង។ ទោះមានការប្រឹងប្រែងប្រមូលសំរាមក៏ដោយ ក៏នៅមានបញ្ហាច្រើនកើតឡើង។

ចាប់តាំងពីខែកុម្ភៈ ឆ្នាំ២០១១ អង្គការ IPAD បានសម្រេចធ្វើការជាមួយក្រុងស្ទឹងត្រែង តាមរយៈការបង្កើតឱ្យមានជាគណៈកម្មការគ្រប់គ្រងសំរាម សំណល់រឹងក្រុង ហើយក្រោយមកបង្កើតជាការិយាល័យគ្រប់គ្រងសំរាម សំណល់រឹង ដែលបានទទួលស្គាល់ដោយរដ្ឋបាលខេត្តនាខែសីហា ឆ្នាំ២០១២ និងក្រសួងមហាផ្ទៃ នាខែសីហា ឆ្នាំ២០១៣។

បច្ចុប្បន្ននេះ ក្រោយពីជំនួយអង្គការអេស្ប៉ាញបានបញ្ចប់ ការិយាល័យគ្រប់គ្រងសំរាម-សំណល់រឹងក្រុង នៅបន្តប្រតិបត្តិការការងាររបស់ខ្លួន ជាអង្គភាពពាក់កណ្តាលរដ្ឋ ដោយមានបុគ្គលិករដ្ឋចំនួន២នាក់៖ ១នាក់មកពីរដ្ឋបាលក្រុង និង១នាក់ទៀតមកពីមន្ទីរបរិស្ថានខេត្ត រួមនឹងបុគ្គលិកជាប់កិច្ចសន្យា និងកម្មករចំនួន១៣នាក់ ដែលបានទទួលបទពិសោធន៍កាលពីបម្រើការជាមួយអង្គការក្រៅរដ្ឋាភិបាលកន្លងមក និងមានមន្ត្រីមួយចំនួនទើបនឹងជ្រើសរើសថ្មី(មកជំនួសអ្នកចាស់)។ ក្នុងចំណោមបុគ្គលិកទាំងអស់ចំនួន១៥នាក់ មាន៤នាក់ជាបុគ្គលិកការិយាល័យ ៣នាក់ជាអ្នកប្រមូលកម្រៃសេវា ២នាក់ជាអ្នកបើកបរ និង៥នាក់ទៀតជាកម្មករ។ ការិយាល័យនេះ មានរថយន្តដឹកសំរាម(សល់ពីមុនមកជារថយន្តចាស់)ចំនួន២គ្រឿង និងរថយន្តឈូសសំរាម១គ្រឿង (សម្រាប់ទីលានចាក់សំរាម)។ ចំណូលពីការសេវាគ្រប់គ្រងសំរាម(ប្រមាណជា៣,៦០០ដុល្លារ/ខែ) រួមនឹងថវិកាប្រចាំឆ្នាំ ដែលផ្តល់ដោយរដ្ឋបាលខេត្ត(ប្រមាណជា៣លានរៀល ឬ៧៥០ដុល្លារអាមេរិក) គឺជាប្រភពថវិកាចម្បងសម្រាប់ប្រតិបត្តិការការងាររបស់ការិយាល័យនេះ។

ក្នុងកិច្ចប្រឹងប្រែងរបស់រាជរដ្ឋាភិបាលកម្ពុជា នាឆ្នាំ២០១៥ ចំពោះការធ្វើប្រតិភូកម្មមុខងារទៅឱ្យរដ្ឋបាលក្រុង ក្នុងការគ្រប់គ្រងសំរាម សំណល់រឹង ដោយផ្តល់ធនធានផងនោះ ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុបានធ្វើការណែនាំដល់គ្រប់រដ្ឋបាលក្រុងទាំងអស់ ឱ្យចុះកិច្ចសន្យាតែជាមួយក្រុមហ៊ុនឯកជនប៉ុណ្ណោះចំពោះកិច្ចការប្រមូលសំរាម សំណល់រឹង។ ចំណុចនេះ រដ្ឋបាលក្រុងកន្លងមក បានជួបប្រជុំជាច្រើនលើកជាមួយនឹងបណ្តាមន្ទីរពាក់ព័ន្ធនៅថ្នាក់ខេត្ត និងដៃគូពាក់ព័ន្ធនានាឱ្យស្វែងរកដំណោះស្រាយ បែងចែកការទទួលខុសត្រូវរវាងក្រុមហ៊ុនដៃគូឯកជន និងការិយាល័យគ្រប់គ្រងសំរាម សំណល់រឹងក្រុង។ បច្ចុប្បន្ន មានការឯកភាពថា ក្រុមហ៊ុនឯកជនត្រូវទទួលប្រមូលសំរាម -សំណល់រឹងតាមទីសាធារណៈនានា រួមទាំងតាមទីផ្សារ ចំណែកការិយាល័យគ្រប់គ្រងសំរាម សំណល់រឹងក្រុង គឺជាអ្នកប្រមូលសំរាម សំណល់រឹងតាមបណ្តាលំនៅដ្ឋានប្រជាពលរដ្ឋ និងក្រុមហ៊ុនអាជីវកម្មផ្សេងៗ។ យ៉ាងណាក៏ដោយ វិធីសាស្ត្រថ្មីនេះនៅមិនទាន់យកមកអនុវត្តនៅឡើយ។

## ភាពរាំងស្ទះក្នុងការអនុវត្តការងារ

ដោយមិនគិតពីប្រភេទនៃអ្នកផ្តល់សេវាប្រមូលសំរាម(អ្នកប្រមូលសំរាម)បញ្ហាពាក់ព័ន្ធនឹងការប្រមូលសំរាម សំណល់រឹង នៅតាមបណ្តាក្រុងផ្សេងៗទៀតមានលក្ខណៈស្ទើរប្រហាក់ប្រហែលគ្នាដូចខាងក្រោម៖

- ប្រជាពលរដ្ឋ ជាទូទៅមានចំណេះដឹងតិចតួចអំពីបញ្ហាបរិស្ថានក្រុង ពិសេសការគ្រប់គ្រងទុកដាក់សំរាមនេះតែម្តង។ ជាលទ្ធផល ពុំសូវមានការចូលរួមបានល្អពីសំណាក់ប្រជាពលរដ្ឋអំពីបញ្ហានេះឡើយ។
- ប្រជាពលរដ្ឋប្រមាណជា៤០% ពុំបានបង់ថ្លៃប្រមូលសំរាមប្រចាំខែ។ ពួកគាត់ភាគច្រើនរស់នៅឆ្ងាយពីផ្លូវសំខាន់ៗក្នុងក្រុង ឬរស់នៅតាមផ្លូវតូចៗ។ ប្រជាពលរដ្ឋទាំងនោះ បោះចោលសំរាមនៅតាមទីសាធារណៈក្បែរតំបន់ខ្លួនរស់នៅ ចោលសំរាមតាមដងផ្លូវ តាមសួនច្បារសាធារណៈ ជិតទីផ្សារ ក្នុងទន្លេ ឬតាមដងទន្លេ តាមគំនរសំរាមនានា ហើយពុំបានទុកដាក់សំរាមតាមតំបន់ដែលតម្រូវសម្រាប់ប្រមូលឡើយ។
- កង្វះខាតសេចក្តីណែនាំឬនីតិវិធីនានា ចំពោះការចោលសំរាមអាណាធិបតេយ្យ និងតាមទីសាធារណៈ
- ការអភិវឌ្ឍផ្នែកនគរូបនីយកម្មយ៉ាងឆាប់រហ័ស និងកំណើនប្រជាពលរដ្ឋក្នុងក្រុង បានធ្វើឱ្យបរិមាណផលិតសំរាម -សំណល់រឹង កាន់តែកើនឡើង ដោយគ្មានវិធានការញែក និងកែច្នៃសំរាម។
- ដោយសារសមត្ថភាពមានកម្រិត ការិយាល័យគ្រប់គ្រងសំរាម សំណល់រឹងក្រុង អាចប្រមូលតែសំរាមពីតាមលំនៅដ្ឋានរបស់ប្រជាពលរដ្ឋ និងតាមទីផ្សារប៉ុណ្ណោះ គឺពុំអាចប្រមូលតាមទីសាធារណៈ ដូចជាតាមដងផ្លូវ សួនច្បារ និងកន្លែងសាធារណៈនានាឡើយ។
- យន្តការសម្របសម្រួលជាមួយនឹងស្ថាប័ន អង្គភាពនានានៅមានកម្រិត
- ការប្រមូលកម្រៃ គឺតែងតែចោទជាបញ្ហា ពិសេសជាមួយនឹងអាជីវករ ដូចជារោងចក្រក្តារបន្ទះ និងសហគ្រាសផលិតដែកថែបជាដើម ដោយសារតែបរិមាណសំរាមច្រើនពេក(ពុំមានវិធានការសមស្របដែលអាចដោះស្រាយបាន ដូចជាខ្វះរថយន្តដឹកសំរាម) ហើយក្រុមអាជីវករទាំងនោះបដិសេធមិនព្រមបង់កម្រៃ(ដោយផ្អែកលើបរិមាណសំរាមរបស់ខ្លួន)។
- ការកំណត់កម្រៃអតិបរិមា ដែលឯកភាពដោយអភិបាលក្រុង និងខេត្ត កាលពីខែឧសភា ឆ្នាំ២០១០កន្លងមក គឺមានកម្រិតទាបពេក ហើយមិនសមស្របទៅនឹងស្ថានភាពជាក់ស្តែង។ ដូចនេះការពិនិត្យកែសម្រួលកម្រៃអតិបរមាឡើងវិញ គឺជាការចាំបាច់ដែលត្រូវធ្វើ។
- អត្រាឈប់ពីការងាររបស់កម្មករមានកម្រិតខ្ពស់ ដោយសារតែពុំមានសេវាធានារ៉ាប់រងសុខភាពដល់ពួកគាត់
- កិច្ចសហការ និងការចូលរួមរបស់ប្រជាពលរដ្ឋ និងក្រុមអាជីវករ មានកម្រិតទាប និងតិចតួច (ក្នុងការអនុវត្តនូវលើបទបញ្ជា និងសេចក្តីណែនាំនានា ព្រមទាំងកាលវិភាគប្រមូលសំរាមផងដែរ)
- ខណៈដែលកិច្ចប្រឹងប្រែងរបស់រាជរដ្ឋាភិបាលក្នុងការគ្រប់គ្រងសំរាម សំណល់រឹង ដោយមានការផ្តល់ធនធាន ទៅឱ្យរដ្ឋបាលថ្នាក់ក្រុង មានលក្ខណៈវិជ្ជមាន ការហាមឃាត់លើការចំណាយ និងភាពត្រឹមត្រូវក្នុងការចំណាយលើថវិកានោះ(ចំណាយបានតែចុះកិច្ចសន្យាជាមួយក្រុមហ៊ុនឯកជន) បានក្លាយជាកត្តារាំងសម្រាប់ការិយាល័យគ្រប់គ្រងសំរាម សំណល់រឹងនៃក្រុងស្ទឹងត្រែង មិនអាចប្រើប្រាស់ថវិកានេះបាន ជាហេតុពុំអាចពង្រីកវិសាលភាពផ្តល់សេវាគ្រប់គ្រងសំរាមរបស់ខ្លួនបាន៕

# ជំពូក៣ បញ្ហាប្រឈម

បញ្ហាសំរាម សំណល់រឹង និងបរិស្ថានតាមទីប្រជុំជន បានក្លាយជាកង្វល់ចម្បងក្នុងចំណោមបញ្ហានានាដទៃទៀត(ក្នុងនោះរួមមានបញ្ហាគ្រោះថ្នាក់ចរាចរណ៍ និងគ្រឿងញៀន) ហើយជាប្រធានបទក្នុងការជជែកពិភាក្សាប្រចាំថ្ងៃ ក្នុងចំណោមសាធារណជន លើទំព័រសារព័ត៌មាន បណ្តាញសង្គម និងកិច្ចពិភាក្សាផ្នែកគោលនយោបាយនានា។ ដោយបន្ទោសលើការអភិវឌ្ឍយ៉ាងឆាប់រហ័សដែលជាប្រភពនៃបញ្ហានេះក្តី ដំណោះស្រាយបញ្ហាគ្រប់គ្រងសំរាម សំណល់រឹង មិនអាចធ្វើឡើងដោយការពន្យឺតល្បឿនការអភិវឌ្ឍនោះទេ។ តាមលទ្ធផលអង្កេត មានបញ្ហាប្រឈមចម្បងៗជាច្រើន ដែលចាំបាច់ត្រូវយកចិត្តទុកដាក់ រួមការអនុវត្តការផ្ទេរមុខងារគ្រប់គ្រងសំរាម សំណល់រឹង។ បញ្ហាប្រឈមសំខាន់ៗទាំងនោះ រួមមានយន្តការគ្រប់គ្រងការងារតាមបែបមជ្ឈការ ក្របខ័ណ្ឌគតិយុត្តមិនទាន់គ្រប់គ្រាន់ និងមិនទាន់សមស្រប ការពង្រឹងការអនុវត្តលិខិតបទដ្ឋាននានាមិនទាន់មានប្រសិទ្ធភាព និងការខ្វះខាតធនធានមនុស្ស និងថវិកា ជាដើម។

## ៣.១. ការគ្រប់គ្រងសំរាម សំណល់រឹងតាមបែបមជ្ឈការ

ទោះបីការអនុវត្តកំណែទម្រង់វិមជ្ឈការ ត្រូវបានលើកកម្ពស់អស់រយៈកាលជាច្រើនឆ្នាំក្តី កម្ពុជានៅតែមានបញ្ហាប្រឈមមួយចំនួន ក្នុងការលើកកម្ពស់គំនិតផ្តួចផ្តើមពីមូលដ្ឋាន ព្រមទាំងលើកកម្ពស់វិធានការការងារក្នុងការដោះស្រាយបញ្ហានានានៅមូលដ្ឋាន។ ពាក់ព័ន្ធនឹងការគ្រប់គ្រងសំរាម សំណល់រឹង រដ្ឋបាលក្រុង ស្រុកដែលបានឆ្លើយបញ្ជីសំណួរភាគច្រើន នៅតែយល់ថា រដ្ឋបាលខេត្ត គឺជាអ្នកទទួលខុសត្រូវចំពោះបញ្ហានេះ ហើយបានលើកឡើងថាមន្ទីរសេដ្ឋកិច្ច និងហិរញ្ញវត្ថុខេត្ត ឬក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ជាអ្នកទទួលខុសត្រូវក្នុងការកំណត់កម្រៃអតិបរមា ហើយក្រសួងបរិស្ថានជាបានដាក់ចេញលិខិតបទដ្ឋានមួយចំនួននៅមិនទាន់ច្បាស់លាស់ពាក់ព័ន្ធនឹងការគ្រប់គ្រងសំរាម ក្រុមហ៊ុនឯកជនប្រមូលសំរាម ពុំបាន ឬមានកិច្ចសហការតិចតួចជាមួយអាជ្ញាធរមូលដ្ឋាន(ដោយសាររបៀបគ្រប់គ្រងចាត់ចែងបែបមជ្ឈការ គឺអ្វីៗទាំងអស់ជាការសម្រេចរបស់ថ្នាក់លើនៅការិយាល័យកណ្តាលនៅឯភ្នំពេញ)។ ក្រៅពីនេះ ការចូលរួមតិចតួចពីសំណាក់ប្រជាពលរដ្ឋ (មួយផ្នែកដោយសារប្រជាពលរដ្ឋយល់ថាអាជ្ញាធរថ្នាក់ជាតិ និងថ្នាក់មូលដ្ឋានយល់ដឹងពីការងារនេះដែរ)។

ដោយសារតែផ្នត់គំនិតថ្នាក់លើជាធំ និងការស្តាប់បង្គាប់នេះ រដ្ឋបាលក្រុង ស្រុក ស្ទាក់ស្ទើរក្នុងផ្តួចផ្តើម និងបង្ហាញពីភាពសកម្ម ឬទទួលយកការទទួលខុសត្រូវនានារបស់ខ្លួន។ *ដូចគេបានលើកឡើងថា "ហេតុអ្វីបានជា គេប្រើគម្រោងទីក្រុងស្អាត មកវាយតម្លៃការងាររដ្ឋបាលក្រុង ខណៈដែលអំណាចនានា ឋិតក្នុងដៃរដ្ឋបាលខេត្ត និងក្រសួង ស្ថាប័នថ្នាក់ជាតិ?"*។ មានរដ្ឋបាលក្រុង ស្រុកមួយចំនួន បានត្អូញត្អែថា គាត់មានតួនាទីត្រឹមតែចុះហត្ថលេខាកិច្ចសន្យាជាមួយក្រុមហ៊ុនឯកជនប្រមូលសំរាមទៅតាមការណែនាំរបស់រដ្ឋបាលខេត្តប៉ុណ្ណោះ ហើយតែងតែប្រាប់ឱ្យខ្លួនឯងថា ត្រូវធ្វើតាមអ្វីដែលថ្នាក់លើប្រាប់តែប៉ុណ្ណោះមុននឹងអនុវត្តភារកិច្ចអ្វីមួយ។ បញ្ហាប្រឈមទាំងនេះ ស្តែងចេញពីភាពមិនច្បាស់លាស់នៃតួនាទី និងការទទួលខុសត្រូវនៃអង្គភាពផ្សេងៗរបស់ រដ្ឋាភិបាល ដែលនាំឱ្យរដ្ឋបាលថ្នាក់ក្រោមជាតិទាំងនោះ ចាំតែទទួលយកគោលការណ៍ណែនាំ និងនីតិវិធីទាំងឡាយមុននឹងបំពេញភារកិច្ចរបស់ខ្លួន។

ទន្ទឹមនឹងនេះ គោលការណ៍ណែនាំ និងនីតិវិធីកាន់តែលម្អិត មានន័យថាកាន់តែធ្វើឱ្យសមត្ថភាពរបស់រដ្ឋបាលថ្នាក់ក្រោមជាតិ កាន់តែមានកម្រិតក្នុងការស្វែងរកដំណោះស្រាយសមស្របនានា សម្រាប់មូលដ្ឋានរបស់ខ្លួនផងដែរ។ និយាយម្យ៉ាងទៀត នីតិវិធីនានាពីថ្នាក់ជាតិ គឺជាការរារាំងដល់គំនិតផ្តួចផ្តើមរបស់រដ្ឋបាលថ្នាក់ក្រោមជាតិទៅវិញ ដែលដាក់កំហិតដល់រដ្ឋបាលថ្នាក់ក្រោមជាតិក្នុងការរើសយកសិទ្ធិអភិវឌ្ឍន៍មូលដ្ឋានដ៏ត្រឹមត្រូវស្របតាមតម្រូវការមូលដ្ឋានរបស់ខ្លួនទាំងបញ្ហាមធ្យោបាយ បញ្ហាសេដ្ឋកិច្ច និងឱកាសនានាផងដែរ(ឧទាហរណ៍៖ តើថ្នាក់ជាតិអាចកំណត់កម្រៃអតិបរមាដូចម្តេច ឱ្យបានសមស្របទាំងសម្រាប់ក្រុងព្រះសីហនុដែលសេវាទេសចរណ៍លំដាប់ខ្ពស់មានរហូតដល់ទៅជាង១.៦០០ បើធៀបនឹងក្រុងស្ទឹងត្រែងដែលចំនួនសេវាលំដាប់ទាបៗមានត្រឹមតែ៧៥ប៉ុណ្ណោះ)។

## ៣.២. លិខិតបទដ្ឋានគតិយុត្តមិនគ្រប់គ្រាន់ ឬមិនទាន់សមស្រប

ដើម្បីចៀសផុតពីការមានកំហុស រដ្ឋបាលក្រុង ស្រុក ត្រូវរង់ចាំគោលការណ៍ណែនាំ និងលិខិតបទដ្ឋាននានានូវរាល់ដំណាក់កាលអនុវត្តការងារទាំងឡាយ។ រាល់ចេតនាដែលរដ្ឋបាលក្រុង ស្រុកបានផ្តួចផ្តើមដោះស្រាយ តែងជួបប្រទះនឹងបញ្ហាផ្សេងទៀត។ ដូចករណីសិក្សានៅក្នុងក្រុងព្រះសីហនុ រាល់ចេតនាក្នុងការអនុវត្តថវិកាសម្រាប់ការគ្រប់គ្រងសំរាម សំណល់រឹងឆ្នាំ២០១៥ ដូចបានកំណត់ក្នុងប្រកាសអន្តរក្រសួងលេខ០៧៣ ខែកុម្ភៈ ឆ្នាំ២០១៥ តែងត្រូវបានហាមឃាត់ដោយក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ដោយផ្អែកលើសារាចរណ៍លេខ៨០០ ចុះខែកក្កដា ឆ្នាំ២០១៥។

បញ្ហានេះ បង្ហាញពីរបៀបដែលថ្នាក់ជាតិ តាមឃ្លាំមើលការចំណាយរបស់រដ្ឋបាលថ្នាក់ក្រោមជាតិដោយប្រើប្រាស់លិខិតបទដ្ឋានគតិយុត្តរបស់ខ្លួន។ ករណីនេះ ក៏ត្រូវបានយកមកប្រើប្រាស់ក្នុងការបង្កើតអនុក្រឹត្យថ្មីលេខ១១៣នេះដែរ។ នីតិវិធីនៃការឃ្លាំមើលមួយក្នុងចំណោមនីតិវិធីទាំង៣នោះគឺការកំណត់កម្រៃអតិបរមា។ បើសិនជាអ្វីដែលមានក្នុងសេចក្តីព្រាង ត្រូវបានអនុម័តចេញជានីតិវិធីមែននោះ កម្រៃសេវាអតិបរមាប្រចាំខែសម្រាប់ការប្រមូលសំរាម សំណល់រឹង គឺតម្លៃ១៥០ដុល្លារអាមេរិក។ នេះមានន័យថា សណ្ឋាគារលំដាប់ផ្កាយ៥មួយចំនួន ក្នុងក្រុងព្រះសីហនុ ដែលកំពុងបង់ប្រាក់កម្រៃរហូតដល់ទៅពីរ បីពាន់ដុល្លារអាមេរិក ជាថ្នូរនឹងការផ្តល់សេវាប្រមូលសំរាមបានល្អប្រសើរនោះ នឹងត្រូវតែបង់តាមតម្លៃកំណត់ថ្មីចំនួន១៥០ដុល្លារអាមេរិក ហើយព្រមទទួលយកគុណភាពសេវាមិនល្អផងដែរ។

ក្នុងលក្ខ័ណ្ឌនៃការពិនិត្យតាមដាន ពីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុបែបនេះ ទើបរដ្ឋបាលក្រុង ស្រុកបានបន្ទោសថា មានចំណុចខ្វះខាតខាងផ្នែកលិខិតបទដ្ឋានគតិយុត្ត ក្នុងកិច្ចការផ្ទេរមុខងារគ្រប់គ្រងសំរាម និងសំណល់រឹង។ ផ្ទុយមកវិញ មានក្រុង ស្រុកមួយចំនួន យល់ឃើញថា ពួកគាត់មានសមត្ថភាពក្នុងការស្វែងយល់និងអនុវត្តតាមឯកសារច្បាប់នានា (ដូចជាប្រកាសលេខ០៧៣ និងអនុក្រឹត្យលេខ១១៣) បើសិនជាពុំមានលិខិតបទដ្ឋានគតិយុត្តណាដែលផ្ទុយពីនេះ។ តាមរយៈភាពមិនច្បាស់លាស់នៃគោលការណបែបនេះ រដ្ឋបាលក្រុង ស្រុកមួយចំនួន ជឿថានីតិវិធីទាំងឡាយ(ដូចជានីតិវិធីពាក់ព័ន្ធនឹងហិរញ្ញវត្ថុ និងគណនេយ្យ ជាដើម) ពុំមានជាឯកសារជាលាយល័ក្ខអក្សរនៅឡើយ គ្រាន់តែជានីតិវិធីដែលនិយាយតគ្នារវាងមន្ទីរសេដ្ឋកិច្ច និងហិរញ្ញវត្ថុ និងរតនាគារខេត្ត។ ប្រសិនបើនីតិវិធីទាំងឡាយ ត្រូវបានកំណត់ឱ្យបានច្បាស់លាស់(ជាលាយល័ក្ខអក្សរ) ព្រមគ្នានឹងការបណ្តុះបណ្តាលឱ្យបានសមស្រប នោះកំហុសទាំងឡាយនឹងមិនអាចកើតឡើងនោះឡើយ។

## ៣.៣. យន្តការពង្រឹងការអនុវត្តលិខិតបទដ្ឋាននៅពុំទាន់មានប្រសិទ្ធិភាព

ជាទូទៅ ការអនុវត្តខុសនីតិវិធី និងខុសពីសេចក្តីណែនាំនានា គឺជារឿងធម្មតាទៅហើយសម្រាប់ស្ថានភាពក្នុងប្រទេសកម្ពុជា ដូចគ្នាទៅនឹងករណីសាមញ្ញនៃគ្រោះថ្នាក់ចរាចរណ៍ និងអវត្តមានពីការងារដូច្នេះដែរ។ ប្រជាពលរដ្ឋទូទៅ រួមទាំងមន្ត្រីរាជការ សុទ្ធតែបានទទួលស្គាល់ការពិតនៃបែបបទការរស់នៅរបៀបនេះ។ ចំពោះករណីគ្រប់គ្រងសំរាម សំណល់រឹង ការយកកម្រៃលើសពីចំនួនកំណត់ ការមិនបង់ប្រាក់កម្រៃ ការគេចវេសពីការផាកពិន័យដោយសារមិនចង់គោរពតាមគោលការណ៍ច្បាប់ និងប្រព័ន្ធត្រួតពិនិត្យនានា ឬចរចារឱ្យផាកពិន័យតិចតួច ព្រមទាំងការយល់ដឹងអំពីនីតិវិធី និងបទបញ្ញាទាំងឡាយនៅមានកម្រិត សុទ្ធសឹងតែជាបញ្ហាបន្តចោទមានយ៉ាងច្រើន។ ស្ថានភាពនយោបាយ ក៏ជាហេតុផលមួយផ្សេងទៀត(អាចថាជាលេស)ក្នុងការដែលមិនបានពង្រឹងការអនុវត្តច្បាប់។ ដូចគេតែងលើកឡើងថា *"ប្រជាពលរដ្ឋនឹងមិនសប្បាយចំពោះការគ្រប់គ្រងរបស់គណបក្សយើងឡើយ បើយើងបង្ខំប្រជាពលរដ្ឋបង់ថ្លៃសំរាម ឬហាមឃាត់ពួកគាត់មិនឱ្យដុតសំរាមនៅតាមលំនៅដ្ឋានរបស់ខ្លួន"*។

មានរបាយការណ៍ថា ក្រុមហ៊ុនប្រមូលសំរាម តែងតែមិនយកចិត្តទុកដាក់ចំពោះបញ្ហាច្បាប់ឡើយ។ ដូចក្នុងករណី ក្រុមហ៊ុនប្រមូលសំរាមនៅក្រុងព្រះសីហនុ ទាំងរថយន្តដឹកសំរាម ធុងសំរាម និងទីកន្លែងស្តុកសំរាមបណ្តោះអាសន្ន ប្រហែលមិនបានប្រគល់មករដ្ឋវិញឡើយ ក្រោយពីកិច្ចសន្យារយៈពេល១៥ឆ្នាំបានបញ្ចប់។ វិធានការទាំងឡាយ ដែលអាចយកមកប្រើប្រាស់ចំពោះក្រុមហ៊ុនប្រមូលសំរាមទាំងនេះ ចាំបាច់ត្រូវមានពិគ្រោះយោបល់ជាមួយថ្នាក់លើ ដោយសារតែក្រុមហ៊ុនប្រមូលសំរាមទាំងនោះមានទំនាក់ទំនងជិតស្និទជាមួយមន្ត្រីថ្នាក់លើ។ ក្នុងស្ថានភាពបែបនេះ ការពង្រឹងច្បាប់គឺពិតជាចោទជាបញ្ហាគួរឱ្យព្រួយបារម្ភ។

## ៣.៤. កង្វះធនធានមនុស្ស និងហិរញ្ញវត្ថុ

ដូចបានលើកឡើងក្នុងលទ្ធផលនៃការអង្កេតដូចបង្ហាញខាងលើ ក្រុង ស្រុកចំនួន១៤ ពុំមានបុគ្គលិកផ្ទាល់ខ្លួន ឬពុំមានសម្ភារៈការិយាល័យឡើយក្នុងពេលកំពុងដំណើរការអង្កេតនេះ។ ចំពោះរដ្ឋបាលក្រុង ស្រុកណាដែលមានការិយាល័យបរិស្ថាន មានបុគ្គលិកពី១ទៅ៤នាក់ ក្នុងបញ្ជីវត្តមានប្រាក់បៀវត្ស ចំណែកវត្តមានជាក់ស្តែងនៃបុគ្គលិកទាំងនោះមានភាពមិនច្បាស់លាស់ទាល់តែសោះ។ ក្រុង ស្រុកផ្សេងទៀត បានត្អូញត្អែរអំពីសមត្ថភាពនៅមានកម្រិតរបស់បុគ្គលិកខ្លួន ព្រមទាំងកង្វះខាតសម្ភារៈការិយាល័យ និងសម្ភារៈប្រតិបត្តិការការិយាល័យទូទៅ។ នេះគឺជាបញ្ហាប្រឈមយ៉ាងខ្លាំងសម្រាប់រដ្ឋបាលក្រុង ស្រុកទាំងអស់នៅពេលទទួលយកការផ្ទេរមុខងារគ្រប់គ្រងសំរាមនេះ។ បច្ចុប្បន្ន មន្ទីរបរិស្ថានខេត្ត បានផ្តល់គាំទ្របច្ចេកទេស ដោយផ្អែកលើការណែនាំពីរដ្ឋបាលខេត្តរបស់ខ្លួន។

បញ្ហាកង្វះថវិកា ក្លាយជារឿងធម្មតា។ បច្ចុប្បន្ននេះ ក្រុមហ៊ុនប្រមូលសំរាម តែងតែត្អូញត្អែរថាប្រជាពលរដ្ឋមួយចំនួនពុំបានបង់ថ្លៃសេវាឱ្យបានពេញលេញឡើយ ប៉ុន្តែក្រុមហ៊ុនក៏នៅតែបន្តយកកម្រៃខ្ពស់ពីអាជីវករ ឬបុគ្គលមួយចំនួនទៀត។ មិនថាក្រុមហ៊ុននោះទទួលបានប្រាក់កម្រៃច្រើនប៉ុណ្ណាក៏ដោយ សេវាប្រមូលសំរាម ការដឹកជញ្ជូនចេញពីទីតាំងដាក់លាក់ណាមួយ ការមិនបានសម្អាតតាមទីសាធារណៈ ការមិនជំរុញការចូលរួមពីប្រជាពលរដ្ឋ និង/ឬសកម្មភាពការពារបរិស្ថានក្នុងពេលយុទ្ធនាការប្រមូល ដឹកជញ្ជូន និងនៅទីលានចោលសំរាម នៅមានកម្រិតទាបណាស់។

ជាមួយការគាំទ្រថវិកាបន្ថែមពីរាជរដ្ឋាភិបាលកម្ពុជានាឆ្នាំ២០១៥ រដ្ឋបាលក្រុង ស្រុកបានដាក់ផែនការឱ្យមានជាសកម្មភាពបន្ថែមមួយចំនួនទៀត។ មិនត្រឹមតែថវិកាមានតិចប៉ុណ្ណោះទេ ការទូទាត់ចំណាយថវិកានេះនៅតែចោទជាបញ្ហា ដែលតម្រូវឱ្យមានដំណោះស្រាយជាបន្ទាន់។

# ជំពូក៤ សេចក្តីសន្និដ្ឋាន និងអនុសាសន៍

តាមរយៈការអង្កេត និងការពិភាក្សាជាមួយបណ្តារដ្ឋបាលក្រុង ស្រុកដែលពាក់ព័ន្ធ ការសន្និដ្ឋាន ព្រមគ្នានឹងអនុសាសន៍សំខាន់ៗមួយចំនួន ត្រូវបានបង្ហាញសម្រាប់សម្ព័ន្ធភាពជាតិក្នុងការចាត់វិធានការបន្ថែម។

## ៤.១. សេចក្តីសន្និដ្ឋាន

ដំបូង យើងបានលើកយកក្របខ័ណ្ឌគតិយុត្តនានា ពាក់ព័ន្ធនឹងការងារគ្រប់គ្រងសំរាម សំណល់រឹងមក សិក្សាសម្រាប់ការអង្កេតនេះ។ ក្នុងនោះរួមមានប្រកាសអន្តរក្រសួងលេខ៨០ (រវាងក្រសួងមហាផ្ទៃ និងក្រសួង បរិស្ថាន)ដែលកំពុងមានសុពលភាព ព្រមទាំងអនុក្រឹត្យលេខ១១៣ ដែលកំពុងស្ថិតក្នុងភាពសកាពទ្រឹងនៅ ឡើយ។ មានរដ្ឋបាលក្រុងស្រុក មួយចំនួន បានខិតខំអនុវត្តតាមក្រមខ័ណ្ឌគតិយុត្តនេះ ដោយពុំចង់ពន្យាពេល ឡើយ។ យ៉ាងណាក៏ដោយ រដ្ឋបាលក្រុង ស្រុកទាំងនោះ បានប្រឈមនឹងបញ្ហាចំបងៗជាច្រើន ក្នុងការបេក ស្រាយខ្លឹមសារ និងកៀរគរការគាំទ្រនានា ពិសេសការគាំទ្រពីរដ្ឋបាលខេត្ត និងមន្ទីរសេដ្ឋកិច្ច និងហិរញ្ញវត្ថុខេត្ត ឬក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុតែម្តង ដែលពីមុនជាអ្នកអនុវត្តមុខងារនេះ។ ទន្ទឹមនឹងនេះ ក៏នៅមានរដ្ឋបាល ក្រុង ស្រុកជាច្រើនផ្សេងទៀត នៅរង់ចាំនីតិវិធី និងសេចក្តីណែនាំនានាពីថ្នាក់ជាតិពាក់ព័ន្ធការអនុវត្តមុខងារ ដែលបានផ្ទេរនេះ។

ជាការជាក់ស្តែង គោលនយោបាយ និងក្របខណ្ឌ័គតិយុត្តដែលមានភាពទូលំទូលាយ(លិខិតបទដ្ឋាន ដែលមិនលម្អិតពេក) បានផ្តល់ជាគន្លឹះសម្រាប់បណ្តុះគំនិតផ្តួចផ្តើមនានាផងដែរ។ ដូចបានបង្ហាញក្នុងករណី ក្រុងព្រះសីហនុ ក្រោយពីមានបញ្ហាបានផ្ទុះឡើង គោលនយោបាយ និងក្របខ័ណ្ឌគតិយុត្ត ដែលមានសភាព ទូលំទូលាយ បានដាក់សម្ពាធទៅលើរដ្ឋបាលក្រុង ស្រុក(ដែលសកម្ម) ឬដល់រដ្ឋបាលក្រោមជាតិទាំងឡាយ ឱ្យ ព្យាយាមខិតខំស្វែងយល់អំពីគោលនយោបាយ និងក្របខ័ណ្ឌច្បាប់នានាដែលកំពុងនៅជាធរមាន។ ជាក់ស្តែង រាល់កិច្ចពិភាក្សានានាភាគច្រើនលើកឡើងថា"តើមានលិខិតបទដ្ឋានណាមួយហាមឃាត់ មិនអនុញ្ញាតឱ្យយើង អនុវត្តភារកិច្ចនេះឬទេ"។ នេះបញ្ជាក់ឱ្យឃើញថា ដោយមានការប្រឹក្សាយោបល់លើលិខិតបទដ្ឋានល្អៗ រដ្ឋបាល ក្រុងស្រុក នឹងទទួលបានឱកាស និងលទ្ធភាពអាចបត់បែនមួយចំនួនសម្រាប់យកមកអនុវត្តភារកិច្ចនេះ។

មានក្រុមហ៊ុនផ្តល់សេវាប្រមូលសំរាម ជាច្រើនប្រភេទផ្សេងៗ ពិសេសពាក់ព័ន្ធនឹងរយៈពេលនៃកិច្ច សន្យារបស់ក្រុមហ៊ុនទាំងនោះ។ រដ្ឋបាលក្រុង ស្រុកភាគច្រើន ដែលបានផ្តល់ចម្លើយ បានព្យាយាមស្វែងរក ដំណោះស្រាយឱ្យផុតពីក្រុមហ៊ុនជាប់កិច្ចសន្យាទាំងនោះ ទាំងតាមរយៈការបញ្ចប់កិច្ចសន្យា និងតាមការផ្លាស់ ប្តូរអាជ្ញាធរពាក់ព័ន្ធ(ប្តូរពីរដ្ឋបាលខេត្ត មករដ្ឋបាលក្រុង ស្រុក)។ សម្រាប់កិច្ចសន្យាទាំងឡាយណាដែលមាន សុពលភាព១ឆ្នាំ ឬនឹងចប់ក្នុងរយៈពេលឆាប់ៗខាងមុខ ជម្រើសសម្រាប់ក្រុង ស្រុកនោះ ហាក់ដូចជាមាន សភាពប្រសើរច្រើន និងមានក្ខណៈទូលំទូលាយ ក្នុងការទទួលយកភារកិច្ចផ្ទេរការងារគ្រប់គ្រងសំរាម។

ច្បាស់ណាស់ដែលថា ការអនុវត្តការងារមានស្ថានភាពខុសៗគ្នា តាំងពីក្នុងរូបភាពជាការចុះកិច្ចសន្យា ជាមួយក្រុមហ៊ុនឯកជន រហូតដល់ការអនុវត្តការងារដោយការិយាល័យរបស់ខ្លួនផ្ទាល់(ក្រុងស្ទឹងត្រែង) និង/ឬ សម្រាប់ក្រុង ស្រុកខ្លះ គឺការអនុវត្តការងាររួមគ្នា ទាំងអាជ្ញាធររដ្ឋ និងក្រុមហ៊ុនឯកជន(ក្រុងកំពត ក្រុងព្រះសីហនុ និងក្រុងបាត់ដំបងជាដើម)។ មិនថាក្នុងករណីណាឡើយ ការចុះកិច្ចសន្យាការងារជាមួយក្រុមហ៊ុនឯកជន លើ

ការគ្រប់គ្រងសំរាម សំណល់រឹង គឺមានលក្ខណៈចង្អៀត រីឯអាជ្ញាធរមូលដ្ឋាន មានការទទួលខុសត្រូវច្រើនជាង ហើយជាទូទៅច្រើនតែជាអ្នករងការស្តីបន្ទោសពីសាធារណៈអំពីការងារមិនល្អ។

របៀបអនុវត្តខុសៗគ្នាបែបនេះ បានជំរុញឱ្យរដ្ឋបាលក្រុង ស្រុកទាំងឡាយ ទទួលបានសមត្ថភាពខុសៗគ្នាផងដែរ(ទាំងបទពិសោធន៍ការរៀបចំចេញដីកា ឬការរៀបចំក្របខ័ណ្ឌគតិយុត្តថ្នាក់ក្រោមជាតិជាដើម)។ បទពិសោធន៍ផ្សេងគ្នាទាំងនេះ ក៏បានជម្រុញជាលទ្ធផលខុសៗគ្នាផងដែរ(ស្តែងឡើងតាមរយៈការកំណត់ចំណាត់ថ្នាក់លើការប្រកួតប្រជែងទីក្រុងស្អាត ការកៀរគរជំនួយហិរញ្ញវត្ថុផ្នែកបច្ចេកទេសធ្វើជីកំប៉ុស្តិ៍)។ សំខាន់ជាងនេះទៀត រដ្ឋបាលក្រុង ស្រុក(ដោយមានតម្រូវការផ្សេងគ្នាពីមួយទៅមួយ) មានគំនិតផ្តួចផ្តើមការងារផ្សេងៗគ្នាដែរ (ឧ. ក្រុងព្រះសីហនុ មានបរិមាណសំរាមប្រចាំឆ្នាំមានប្រភពពីភ្ញៀវទេសចរណ៍ចំនួន១,៣លាននាក់ អាចពង្រឹងនូវវិធានការនានាជាច្រើន ដើម្បីថែរក្សា និងពង្រឹងស្ថានភាពអនាម័យក្រុង)។

ចំណុចខ្វះខាត និងសមត្ថភាពមានកម្រិត ទាំងផ្នែកធនធានមនុស្ស និងធនធានហិរញ្ញវត្ថុ ក៏បានចោទជាបញ្ហាប្រឈមផ្សេងទៀតដែរ។ ផ្អែកលើលទ្ធផលនៃការអង្កេតនេះ កិច្ចខិតខំប្រឹងប្រែងស្វែងរកដំណោះស្រាយផ្សេងៗគ្នា ព្រមជាមួយនឹងធន្ទះការបង់កម្រៃសេវាសំរាម បានក្លាយជាឱកាសយ៉ាងប្រសើរ ក្នុងការពង្រឹងទំនុកចិត្តផ្នែកហិរញ្ញវត្ថុផ្ទាល់ខ្លួន។ ដោយមានបទពិសោធន៍ពីបណ្តាប្រទេសនានាផងដែរនោះ រដ្ឋបាលក្រុង ស្រុកទាំងឡាយ អាចនឹងមានសមត្ថភាពគ្រប់គ្រាន់ក្នុងពេលឆាប់ៗនេះ ក្នុងការបំពេញមុខងារគ្រប់គ្រងសំរាម សំណល់រឹងប្រកបដោយប្រសិទ្ធភាព និងភាពស័ក្តសិទ្ធ។

## ៤.២. អនុសាសន៍

មានអនុសាសន៍ពីរប្រភេទ ត្រូវបានស្នើឡើង៖ ទី១ សំដៅដល់ការចងក្រងឯកសារពីបទពិសោធន៍ល្អៗ និងការអនុវត្តផែនការហិរញ្ញវត្ថុឆ្នាំ២០១៥របស់រាជរដ្ឋាភិបាល និងទី២ ជាអនុសាសន៍សម្រាប់ជាផែនការសកម្មភាពរបស់*សម្ព័ន្ធភាពជាតិសមាគមក្រុមប្រឹក្សាក្រុង ស្រុក ខណ្ឌ ឃុំ សង្កាត់* ដើម្បីបញ្ចុះបញ្ចូលលើការគ្រប់គ្រងសំរាម សំណល់រឹងតាមបែបវិមជ្ឈការ។

សម្រាប់ការចងក្រងឯកសារពីបទពិសោធន៍ល្អៗ និងការអនុវត្តផែនការហិរញ្ញវត្ថុឆ្នាំ២០១៥របស់រាជរដ្ឋាភិបាល ក្រុមការងារអន្តរក្រសួង(រវាងលេខាធិការដ្ឋានគ.ជ.អ.ប. ក្រសួងមហាផ្ទៃ ក្រសួងបរិស្ថាន និងក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ) គួរអនុវត្តចំណុចទាំងឡាយដូចខាងក្រោម៖

- សិក្សាឱ្យបានស៊ីជម្រៅ ទៅលើការអនុវត្តល្អ (Good Practice) និងបញ្ហាប្រឈមនានា ដែលបានជួបប្រទះកន្លងមក។ ផ្អែកលើលទ្ធផលនៃការអង្កេតនេះ យើងគួរតែយកករណីក្រុងស្ទឹងត្រែង មកសិក្សាបន្ថែម អំពីការរៀបចំការិយាល័យគ្រប់គ្រងសំរាម សំណល់រឹងក្រុង យន្តការកំណត់កម្រៃអតិបរមាដំណើរការ និងប្រសិទ្ធភាពការងារ។ ក្រុងស្ទឹងសែន និងក្រុងក្រចេះ ក៏គួរយកមកពិភាក្សាបន្ថែមផងដែរ ពិសេសពាក់ព័ន្ធនឹងយន្តការកំណត់កម្រៃអតិបរមា និងវិធីសាស្ត្រនៃការប្រមូលកម្រៃ ជាដើម។
- ការសិក្សាបន្ថែមអំពីការអនុវត្តល្អ នៅតាមបណ្តាប្រទេសក្នុងតំបន់ និងប្រទេសដទៃទៀត ក៏ជាមេរៀនបន្ថែមទៀតសម្រាប់ជំរុញការគ្រប់គ្រងសំរាមឱ្យកាន់តែមានប្រសិទ្ធភាព។
- កៀរគរក្រុមការងារបច្ចេកទេសពីក្រសួងសេដ្ឋកិច្ច និងហរិញ្ញវត្ថុ រតនាគារជាតិ ក្រសួងបរិស្ថាន និងលេខាធិការដ្ឋានគ.ជ.អ.ប ដើម្បីជួយគាំទ្រ និងសម្របសម្រួលរាល់ឧបសគ្គនានា ដែលរដ្ឋបាលក្រុង ស្រុក បានជួបប្រទះនាឆ្នាំ២០១៥កន្លងមក។

- ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ និងក្រសួងបរិស្ថាន គួរណែនាំដល់មន្ត្រីជំនាញរបស់ខ្លួន នៅថ្នាក់ខេត្ត ដោយជួយគាំទ្រការងារមន្ត្រីទាំងនោះឱ្យបានពេញលេញ ក្នុងដំណើរការធ្វើផែនការសកម្មភាព និង ផែនការហិរញ្ញវត្ថុក្រុង ស្រុក និងការចំណាយថវិកាទាំងនេះ។

ដើម្បីលើកកម្ពស់កិច្ចការផ្ទេរមុខងារគ្រប់គ្រងសំរាម សំណល់រឹង *សម្ព័ន្ធភាពជាតិសមាគមក្រុមប្រឹក្សា ក្រុង ស្រុក ខណ្ឌ ឃុំ សង្កាត់* ចាំបាច់ត្រូវសហការការងារយ៉ាងជិតស្និតជាមួយងក្រុមការងារបច្ចេកទេស ដែល មានលេខាធិការដ្ឋានគ.ជ.អ.ប. ក្រសួងមហាផ្ទៃ ក្រសួងបរិស្ថាន និងក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ។ សម្ព័ន្ធភាព ជាតិនេះ ក៏ចាំបាច់ត្រូវធ្វើការបញ្ចុះបញ្ចូល ដើម្បីសម្រេចបាននូវការផ្ទេរមុខងារពិតប្រាកដ តាមរយៈការប្រគល់ ការធ្វើសេចក្តីសម្រេចចិត្តនានាឱ្យទៅរដ្ឋបាលក្រុង ស្រុក ជាអ្នកគ្រប់គ្រងបញ្ហានៅមូលដ្ឋាន ដូចជាសំរាម សំណល់រឹង និងបញ្ហាផ្សេងទៀតពាក់ព័ន្ធនឹងបរិស្ថានទីក្រុង ទីប្រជុំជន។

គួរកត់សម្គាល់ផងដែរថា ក្នុងចំណោមគោលបំណងទាំងឡាយនៃការអង្កេតនេះ គឺដើម្បីបង្ហាញលទ្ធ ផលដល់ទៅក្រុមការងាររៀបចំគោលនយោបាយនៅថ្នាក់ជាតិ ក្នុងការគាំទ្ររៀបចំឱ្យមាននូវគោលនយោបាយ គ្រប់គ្រងសំរាម សំណល់រឹង ឱ្យបានសមស្រប ពិសេសគោលនយោបាយនានាពាក់ព័ន្ធនឹងក្របខ័ណ្ឌគតិយុត្ត និងសេចក្តីណែនាំបច្ចេកទេសលើការអនុវត្តអនុក្រឹត្យលេខ១១៣។ ក្នុងន័យនេះ សម្ព័ន្ធភាពជាតិ គួរពាំនាំ អនុសាសន៍នានាដូចខាងក្រោម ទៅពិភាក្សាជាមួយក្រុមការងារបច្ចេកទេសអន្តរក្រសួង (លេខាធិការដ្ឋាន គ.ជ.អ.ប. ក្រសួងមហាផ្ទៃ ក្រសួងបរិស្ថាន និងក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ) ដើម្បីចាត់វិធានការសមស្រប នានារួមមាន៖

- **ជំរុញការអនុវត្តការងារតាមបែបវិមជ្ឈការ (ទាំងការរៀបចំលិខិតបទដ្ឋានគតិយុត្ត ទាំងការអនុវត្ត)**

ខណៈដែលការពន្លឿន ដំណើរការក្នុងការរៀបចំគោលការណ៍ណែនាំទាំងឡាយ ពាក់ព័ន្ធនឹងការអនុវត្ត ការផ្ទេរមុខងារគ្រប់គ្រងសំរាម ឱ្យទៅរដ្ឋបាលក្រុងស្រុកមានភាពចាំបាច់នោះ គេគួរតែពិចារណាអំពីការផ្តល់ លទ្ធភាពដល់រដ្ឋបាលមូលដ្ឋាន ក្នុងរិះរកដំណោះស្រាយផ្សេងៗដោយខ្លួនឯង។ គួរកត់សម្គាល់ថា ដំណើរការ វិមជ្ឈការផ្នែកផ្តល់សេវាដល់ទៅឱ្យរដ្ឋបាលថ្នាក់ក្រោមជាតិ ជាទូទៅកើតឡើងដោយសារភាពទន់ខ្សោយនៃការ អនុវត្តការងាររបស់រដ្ឋបាលថ្នាក់ជាតិ ព្រោះតែការយល់ដឹងពីស្ថានភាពមូលដ្ឋាននៅមានកម្រិត។ ក្នុងការ ស្រាវជ្រាវមួយចំនួន ការធ្វើវិមជ្ឈការនៃការផ្តល់សេវាសាធារណៈ គឺជាគោលបំណងដ៏ចម្បងមួយ ក្នុងការពង្រឹង ការផ្តល់សេវា តាមរយៈពង្រឹងគណនេយ្យភាពតាមបែបប្រជាធិបតេយ្យ។ សម្រាប់ការអនុវត្តជាក់ស្តែង ករណី នេះ គឺដោយសាររដ្ឋបាលថ្នាក់ជាតិមានសមត្ថភាពនៅមានកម្រិត ក្នុងការផ្តល់សេវា និងការធ្វើឱ្យមានភាពពេញ ចិត្តពីសាធារណៈជនលើការបម្រើសេវាជាក់លាក់ណាមួយ។ ក្នុងន័យសាមញ្ញ យើងអាចនិយាយបានថា រដ្ឋបាល ថ្នាក់ជាតិ លែងយល់ដឹងតើត្រូវធ្វើដូចម្តេច ដើម្បីធ្វើឱ្យប្រសើរនូវការផ្តល់សេវាសាធារណៈ។ មានន័យថា តើរដ្ឋ បាលទាំងនោះ ត្រូវការការគាំទ្រជាគំនិតយោបល់ទៀតឬទេ? បើពិតជាដូចនេះមែន ហេតុអ្វីរដ្ឋបាលថ្នាក់ជាតិ នៅតែព្យាយាមផ្តល់ការណែនាំលម្អិតទៀត ចំពោះអ្វីដែលពួកគេមិនទាំងដឹងផងនោះ?

ក្នុងករណីមួយណាក៏ដោយ ការផ្តល់ឱកាស និងលទ្ធភាពអាចបត់បែនបានដល់រដ្ឋបាលក្រុង ស្រុកក្នុង ការបំពេញភារកិច្ចគ្រប់គ្រងសំរាម សំណល់រឹង(រួមទាំងសិទ្ធិសម្រេចជ្រើសរើសក្រុមហ៊ុនឯកជន ការកំណត់ កម្រៃអតិបរមា "ផ្អែកលើការពិគ្រោះយោបល់ជាមួយប្រជាពលរដ្ឋ" និងការបង្កើតយន្តការសមស្របដើម្បីពង្រឹង គណនេយ្យភាពក្រុមហ៊ុនឯកជនចំពោះក្រុង ស្រុក) គួរតែជំរុញឱ្យបានសកម្ម។ ទន្ទឹមនឹងនេះ ក្រុមការងារអន្តរ

ក្រសួង គួរតែពង្រឹងសមត្ថកិច្ច/ដែនកំណត់របស់ខ្លួន ព្រមគ្នានឹងការងារប្រមូលបទពិសោធន៍ ដាក់ស្តែងនានាផងដែរ។ បើស្ថានការណ៍ណាតម្រូវ ឱ្យមានគោលការណ៍ណែនាំលម្អិត រាល់បទពិសោធន៍ក្នុងស្រុក នឹងផ្តល់ជាធាតុចូលសំខាន់ៗ សម្រាប់បង្កើតគោលនយោបាយ និងគោលការណ៍ណែនាំទាំងនោះ។

ការត្រួតពិនិត្យ និងការធ្វើនីត្យានុកូលភាពរបស់ក្រុមការងារអន្តរក្រសួង ចាំបាច់តម្រូវឱ្យមានការកសាងសមត្ថភាពសមស្របដល់រដ្ឋបាលថ្នាក់ក្រោមជាតិផងដែរ។ ក្រុមប្រឹក្សាក្រុង ស្រុក ចាំបាច់ត្រូវយល់ដឹងបន្ថែមអំពីគោលនយោបាយវិមជ្ឈការ និងបណ្តាគោលការណ៍លិខិតបទដ្ឋានពាក់ព័ន្ធផ្សេងៗទៀត មុននឹងណែនាំដល់រដ្ឋបាលរបស់ខ្លួនក្នុងការអនុវត្តការងារ។ ក្នុងការគ្រប់គ្រងសំរាម សំណល់រឹង រដ្ឋបាលក្រុង ស្រុក ចាំបាច់ត្រូវយល់ដឹងឱ្យយ៉ាងពេញលេញអំពីខ្លឹមសារនៃអនុក្រឹត្យលេខ១១៣ ប្រកាសអន្តរក្រសួងលេខ០៧៣ សារាចរណ៍លេខ៨០០ របស់ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ និងគោលការណ៍ណែនាំផ្សេងៗទៀតពាក់ព័ន្ធនឹងការផ្ទេរមុខងារនេះ។ ព្រមជាមួយនេះ រដ្ឋបាលក្រុង ស្រុក ត្រូវការជាចាំបាច់នូវការប្រឹក្សាយោបល់ផ្នែកច្បាប់ និងការការពារនានា ពេលចុះសន្យាជាមួយនឹងក្រុមហ៊ុនឯកជន(ផ្តល់សេវាប្រមូល និងកែច្នៃសំរាម)។ ក្នុងន័យនេះ ក្រសួង ស្ថាប័នថ្នាក់ជាតិ គួរផ្តល់ភាពងាយស្រួលដល់រដ្ឋបាលក្រុងស្រុក ក្នុងការជ្រើសរើសជួលអ្នកមានជំនាញផ្នែកវិមជ្ឈការ ផ្នែកច្បាប់ ឬ/និងត្រូវផ្តល់យោបល់អំពីលិខិតបទដ្ឋាននានាពាក់ព័ន្ធនឹងការងារនេះ។

- **ធនធានមនុស្ស និងធនធានហិរញ្ញវត្ថុ**

តម្រូវការផ្នែកសមត្ថភាពប្រតិបត្តិការការងាររបស់រដ្ឋបាលក្រុងស្រុកជាចាំបាច់ណាស់ ទន្ទឹមនឹងតម្រូវការឱ្យមានក្របខ័ណ្ឌគតិយុត្តដែលត្រឹមត្រូវ និងគ្រប់គ្រាន់ដើម្បីឱ្យកាន់តែមានភាពច្បាស់លាស់នៃតួនាទី និងការទទួលខុសត្រូវ ព្រមទាំងកាតព្វកិច្ចរបស់តួអង្គពាក់ព័ន្ធ។ ដូចបានបង្ហាញក្នុងលទ្ធផលអង្កេតនេះ រដ្ឋបាលក្រុង ស្រុកភាគច្រើន ពុំមានធនធានមនុស្ស ឬជំនាញបច្ចេកទេសគ្រប់គ្រាន់ឡើយ។ ក្នុងករណីនេះ ការផ្ទេរមុខងារគ្រប់គ្រងសំរាម សំណល់រឹង ទៅឱ្យរដ្ឋបាលក្រុងស្រុក ចាំបាច់ត្រូវការការអភិវឌ្ឍធនធានមនុស្សនៅថ្នាក់ក្រុងស្រុក។ ជាឧទាហរណ៍ គួរពិចារណាបទពិសោធន៍របស់រដ្ឋបាលក្រុងស្ទឹងត្រែង មកធ្វើជាមេរៀនសម្រាប់ដោះស្រាយបញ្ហាការគ្រប់គ្រងសំរាមនៅថ្នាក់ក្រុង ស្រុក នាពេលអនាគតនោះ ដូច្នេះក្រសួង ស្ថាប័នថ្នាក់ជាតិ គួរតែអនុញ្ញាតិឱ្យរដ្ឋបាលក្រុង ស្រុក បង្កើតការិយាល័យ ឬអង្គភាពសមស្រប ហើយជ្រើសរើសបុគ្គលិកជំនាញក្នុងមូលដ្ឋានរបស់ខ្លួន ដូចជាពីបុគ្គលិកអង្គការក្រៅរដ្ឋាភិបាលដែលមានពិសោធន៍ ពីក្រុមហ៊ុនឯកជន និង/ឬ ពីស្ថាប័នរដ្ឋជាដើម។ ចំពោះរដ្ឋបាលក្រុង ស្រុកណា ដែលបានសហការជាមួយក្រុមហ៊ុនឯកជនប្រមូលសំរាម រដ្ឋបាលក្រុង ស្រុកនោះ គួរមានសមត្ថភាពគ្រប់គ្រង តាមដាន និងវាយតម្លៃការងាររបស់ក្រុមហ៊ុនឯកជន។ ការកសាងសមត្ថភាពនេះ គួរតែស្ថិតក្រោមការគាំទ្រពីសម្ព័ន្ធភាពជាតិ ដោយមានការរៀបចំជាទស្សនៈកិច្ចសិក្សាទាំងក្នុងប្រទេស និងបណ្តាប្រទេសក្នុងតំបន់។

រដ្ឋបាលក្រុងស្រុក ចាំបាច់ត្រូវមានធនធានហិរញ្ញវត្ថុ។ នៅពេលដែលមុខងារគ្រប់គ្រងសំរាម សំណល់រឹង អាចផ្តល់ជាប្រភពចំណូលបន្ថែម(ទទួលបានពីការប្រមូលកម្រៃសេវា ការផាកពិន័យ ការកែច្នៃ និងពីប្រភពចំណូលផ្ទាល់ខ្លួន)ក្តី កញ្ចប់ថវិកាជាតិពីរាជរដ្ឋាភិបាល ក្នុងការអនុវត្តមុខងារនេះ នឹងនៅតែត្រូវការជាចាំបាច់។ សមាមាត្រទំហំថវិកាផ្ទេរបែបអន្តររដ្ឋបាលបែបនេះ ចាំបាច់ត្រូវតែវិភាជន៍ឱ្យបានគ្រប់គ្រាន់ផ្អែកលើរូបមន្តប្រកបដោយសមធម៌សម្រាប់រដ្ឋបាលក្រុង ស្រុក ដែលមានប្រភពចំណូលតិចតួច(មូលដ្ឋានចំណូល) ដើម្បីបង្កើនទំហំថវិកាដែលត្រូវផ្ទេរឱ្យ។